**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

# សារណាបញ្ចប់ការសិក្សា

# ការអភិវឌ្ឍរមណីយដ្ឋានទេសចរណ៍ ប្រកបដោយនិរន្តរភាព

## ករណីសិក្សា៖ រមណីយដ្ឋានភ្នំកំពង់ត្រាច (ខេត្តកំពត)

ស្រាវជ្រាវពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧

តាក់តែងឡើងដោយ
និស្សិតឈ្មោះ **ខុឡី បញ្ញារតន៍**
**មាស នីភា**

សាស្ត្រាចារ្យណែនាំ
បណ្ឌិត **ហុង វណ្ណៈ**

ថ្នាក់បរិញ្ញាបត្រ ទេសចរណ៍ និងបដិសណ្ឋារកិច្ច
ជំនាន់ទី ៣

ឆ្នាំចូលសិក្សា ២០១៣
ឆ្នាំសរសេរសារណា ២០១៧

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

## សារណាបញ្ចប់ការសិក្សា

# ការអភិវឌ្ឍរមណីយដ្ឋានទេសចរណ៍ ប្រកបដោយនិរន្តរភាព

### ករណីសិក្សា៖ រមណីយដ្ឋានភ្នំកំពង់ត្រាច (ខេត្តកំពត)

ស្រាវជ្រាវពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧

តាក់តែងឡើងដោយ
និស្សិតឈ្មោះ **ខុឡ្លី បញ្ញារតន៍**
**មាស នីកា**

សាស្ត្រាចារ្យណែនាំ
បណ្ឌិត **ហុង វណ្ណៈ**

ថ្នាក់បរិញ្ញាបត្រ ទេសចរណ៍ និងបដិសណ្ឋារកិច្ច
ជំនាន់ទី ៣

ឆ្នាំចូលសិក្សា ២០១៣
ឆ្នាំសរសេរសារណា ២០១៧

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ វុឌ្ឍី បញ្ញារតន៍ និង មាស នីកា ជានិស្សិតឆ្នាំទី៤ ជំនាន់ទី៣ ថ្នាក់បរិញ្ញាបត្រ គ្រប់គ្រងទេសចរណ៍ និងបដិសណ្ឋារកិច្ច នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច សូមសម្តែងការដឹងគុណយ៉ាងជ្រាលជ្រៅ និងថ្លែងអំណរគុណចំពោះ៖

- លោកអ្នកមានគុណរបស់យើងទាំងពីរ ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាយើងខ្ញុំតាំងពីតូចរហូតដល់ធំដឹងក្តី។ លោកទាំងពីរបានខិតខំប្រឹងប្រែងពុះពាររាល់ឧបសគ្គក្នុងការប្រកបរបរ ដើម្បីរកប្រាក់កម្រៃក្នុងការផ្គត់ផ្គង់ដល់ការសិក្សារបស់យើងខ្ញុំ ក្នុងគោលបំណងដើម្បីឲ្យយើងខ្ញុំទទួលបានចំណេះដឹងជ្រៅជ្រះ ដែលជាទុនដ៏ចាំបាច់សម្រាប់ជីវភាពរស់នៅក្នុងសង្គម។
- លោកសាស្រ្តាចារ្យបណ្ឌិត ហុង វណ្ណៈ ដែលជួយណែនាំពីរបៀបនៃការសរសេរសារណា និងបានផ្តល់នូវចំណេះដឹងជាច្រើន ដើម្បីឲ្យពួកខ្ញុំសម្រេចនូវកិច្ចការនេះបាន។
- លោក គឹម ប៊ុនថន ប្រធានការិយាល័យផែនការអភិវឌ្ឍន៍ទេសចរណ៍វប្បធម៌ និងលោក កែវ សំអាន ប្រធានសហគមន៍ទេសចរណ៍ ស្រុកកំពង់ត្រាច ដែលបានផ្តល់នូវបទសម្ភាសន៍ ក៏ដូចជាឯកសារណែនាំសម្រាប់ការស្រាវជ្រាវសារណាបញ្ចប់ការសិក្សានេះ។
- ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និងលោក លោកស្រីសាស្រ្តាចារ្យទាំងអស់ដែលបានផ្តល់នូវចំណេះដឹងដែលកាត់ថ្លៃពុំបាន និងចែកចាយនូវរាល់បទពិសោធន៍ដែលលោកធ្លាប់បានឆ្លងកាត់ដល់យើងខ្ញុំ។

# អារម្ភកថា

បច្ចុប្បន្ននេះ វិស័យទេសចរណ៍ត្រូវបានគេចាត់ទុកជាវិស័យអទិភាពមួយក្នុងការជំរុញអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម ក៏ដូចជាបង្កើននូវរូបិយប័ណ្ណអន្តរជាតិ បង្កើតការងារជូនប្រជាពលរដ្ឋ កាត់បន្ថយភាពក្រីក្រ អភិរក្សធនធានដែលមាន ដើម្បីទប់ស្កាត់នូវផលប៉ះពាល់អវិជ្ជមានទៅលើបរិស្ថានធម្មជាតិ និងវប្បធម៌ ហើយជួយផ្សព្វផ្សាយពីវប្បធម៌ប្រទេសនីមួយៗលើឆាកអន្តរជាតិ។ ដូច្នេះហើយ ទើបយើងខ្ញុំបានធ្វើការស្រាវជ្រាវសារណាបញ្ចប់ការសិក្សា និងចុះស្រាវជ្រាវដោយផ្ទាល់ទៅលើប្រធានបទ "**ការអភិវឌ្ឍរមណីយដ្ឋានទេសចរណ៍ប្រកបដោយនិរន្តរភាព ករណីសិក្សារមណីយដ្ឋានភ្នំកំពង់ត្រាច (ខេត្តកំពត)**"។ តាមរយៈការស្រាវជ្រាវនេះ យើងខ្ញុំបានរកឃើញនូវទស្សនទានរបស់អ្នកប្រាជ្ញជាច្រើន ដែលទាក់ទងនឹងការអភិវឌ្ឍទេសចរណ៍ ក៏ដូចជាបទពិសោធន៍បរទេសក្នុងការចូលរួមអភិវឌ្ឍន៍ទេសចរណ៍ប្រកបដោយនិរន្តរភាព។ មួយវិញទៀត យើងក៏បានរកឃើញនូវបញ្ហាប្រឈមផ្សេងៗ ដែលនាំឲ្យការអភិវឌ្ឍទេសចរណ៍មានការរាំងស្ទះ ក៏ដូចជាវិធានការដោះស្រាយមួយចំនួនតាមរយៈការរួមចំណែករបស់សហគមន៍ ដើម្បីជំរុញកិច្ចការអភិវឌ្ឍន៍ទេសចរណ៍នៅរមណីយដ្ឋានភ្នំកំពង់ត្រាច។

ថ្វីត្បិតតែការស្រាវជ្រាវរបស់យើងខ្ញុំ មិនទាន់មានលក្ខណៈល្អគ្រប់ជ្រុងជ្រោយនៅឡើយ ប៉ុន្តែវាក៏អាចជាជំនួយដល់និស្សិតជំនាន់ក្រោយៗ ដែលសិក្សាលើជំនាញគ្រប់គ្រងទេសចរណ៍ និងការអភិវឌ្ឍរមណីយដ្ឋានដែលមានភាពស្រដៀងគ្នានៅក្នុងប្រទេសកម្ពុជា ឲ្យយល់ដឹងពីដំណើរការនៃការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព។

យើងខ្ញុំសង្ឃឹមថា អត្ថបទនេះជាចំណែកមួយក្នុងការបង្កើនចំណេះដឹង ព្រមទាំងបទពិសោធន៍សម្រាប់មិត្តអ្នកអាន សិស្សនិស្សិត ជាពិសេសអ្នកពាក់ព័ន្ធក្នុងការអភិវឌ្ឍទេសចរណ៍នៅតំបន់គោលដៅទេសចរណ៍។ យើងខ្ញុំនឹងរង់ចាំទទួលនូវការរិះគន់ កែលម្អប្រកបដោយន័យស្ថាបនាពីគ្រប់មជ្ឈដ្ឋានក៏ដូចជាអធ្យាស្រ័យរាល់កំហុសឆ្គងដោយអចេតនា។

# មាតិកា


បញ្ជីអក្សរកាត់....................iii

បញ្ជីក្រាហ្វិក....................iv

បញ្ជីឧបសម្ព័ន្ធ....................v


## សេចក្ដីផ្ដើម


១. ប្រវត្តិបញ្ហា....................១

២. ចំណោទបញ្ហា....................៣

៣. គោលបំណងនៃការស្រាវជ្រាវ....................៣

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ....................៣

៥. វិធីសាស្ត្រនៃការស្រាវជ្រាវ....................៣

៦. សារៈសំខាន់នៃការស្រាវជ្រាវ....................៥

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ....................៦


## ជំពូកទី១

## ទ្រឹស្ដីនៃការអភិវឌ្ឍទេសចរណ៍


១.១ ទេសចរណ៍គឺជាអ្វី?....................៧

១.២ ប្រភេទទេសចរណ៍....................៨

១.៣ ការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព....................១០

១.៤ ផលប៉ះពាល់អវិជ្ជមាននៃការអភិវឌ្ឍទេសចរណ៍....................១២

១.៥ បទពិសោធន៍បរទេសទាក់ទងនឹងការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព....................១៤


## ជំពូកទី២

## ស្ថានភាពទូទៅនៃទេសចរណ៍ខេត្តកំពត


២.១ ស្ថានភាពទូទៅនៃខេត្តកំពត....................១៨

២.១.១ ទីតាំងភូមិសាស្ត្រ....................១៨

២.១.២ វិស័យនានាក្នុងខេត្តកំពត....................១៨

២.២ ស្ថានភាពទេសចរណ៍ខេត្តកំពត....................១៩

២.២.១ សក្ដានុពលទេសចរណ៍ខេត្តកំពត....................១៩

២.២.២ ទីផ្សារទេសចរណ៍ និងមូលដ្ឋានស្នាក់នៅទេសចរណ៍....................២៣

២.៣ ស្ថានភាពនៃរមណីយដ្ឋានភ្នំកំពង់ត្រាច....................២៤

២.៣.១ ស្ថានភាពទូទៅ និងប្រវត្តិ ..........២៤
២.៣.២ សក្តានុពលភ្នំកំពង់ត្រាច ..........២៨
២.៣.៣ បញ្ហាប្រឈម ..........២៩

## ជំពូកទី៣

## ទស្សនទានក្នុងការអភិវឌ្ឍរមណីយដ្ឋានភ្នំកំពង់ត្រាច

៣.១ ការកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈ .......... ៣៣
៣.២ ការបង្កើនគុណភាពអាហារ និងភេសជ្ជៈ (គុណភាព អនាម័យ និងបដិសណ្ឋារកិច្ច ..........៣៧
៣.២.១ ការរៀបចំតូបអង្គុយ និងតូបលក់ដូរ ..........៣៧
៣.២.២ អាជីវករ ..........៣៧
៣.២.៣ ប្រភពគ្រឿងផ្សំ ..........៤០
៣.២.៤ ឧបករណ៍ក្នុងការចម្អិន ..........៤២
៣.៣ បង្កើនការគ្រប់គ្រងផ្នែកបរិស្ថាន និងអនាម័យ ..........៤២
៣.៤ ពង្រឹងផ្នែកសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ ..........៤៥
៣.៥ ការលើកទឹកចិត្តផ្នែកឯកជន និងអង្គការក្រៅរដ្ឋាភិបាល ..........៤៦
៣.៦ បង្កើនការផ្សព្វផ្សាយ ..........៤៨
៣.៧ ការរៀបចំព្រឹត្តិការណ៍ និងសេវាកម្មទេសចរណ៍ ..........៤៩

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

១. សេចក្តីសន្និដ្ឋាន ..........៥២
២. ការផ្តល់អនុសាសន៍ ..........៥២

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

UNWTO: United Nation World Tourism Organization

ASI: Archaeological Survey of India

JICA: Japan International Cooperation Agency

# បញ្ជីក្រាហ្វិក

ទំព័រ

ក្រាហ្វិកទី១. ការយល់ឃើញរបស់ប្រជាជនអំពីប្រព័ន្ធអគ្គិសនី ............................................... ៣៥
ក្រាហ្វិកទី២. ការយល់ឃើញពីប្រព័ន្ធទឹកស្អាតរបស់ប្រជាជន ................................................ ៣៦
ក្រាហ្វិកទី៣. ប្រជាជនចេះរបៀបចម្អិនអាហារតាមរយៈ........................................................ ៣៨
ក្រាហ្វិកទី៤. ការយល់ឃើញរបស់ទេសចរចំពោះការផ្គត់ផ្គង់អាហារក្នុងរមណីយដ្ឋាន ............. ៣៩
ក្រាហ្វិកទី៥. ការយល់ឃើញរបស់ទេសចរអំពីការបម្រើសេវាកម្ម ........................................... ៣៩
ក្រាហ្វិកទី៦. ប្រភពគ្រឿងផ្សំដែលអាជីវករយកទៅចម្អិនអាហារ ..............................................៤១
ក្រាហ្វិកទី៧. ការយល់ឃើញរបស់ទេសចរពីការទុកដាក់កាកសំណល់.................................... ៤៣
ក្រាហ្វិកទី៨. ការយល់ឃើញរបស់ទេសចរអំពីបង្គន់អនាម័យ ................................................ ៤៣
ក្រាហ្វិកទី៩. ការយល់ឃើញរបស់ទេសចរលើសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ ...............៤៥
ក្រាហ្វិកទី១០. ផ្នែកឯកជន និងអង្គការក្រៅរដ្ឋាភិបាលដែលអភិវឌ្ឍន៍ភ្នំកំពង់ត្រាច ....................៤៦
ក្រាហ្វិកទី១១. បណ្តាញដែលទេសចរស្គាល់រមណីយដ្ឋាន .....................................................៤៩

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១៖ កម្រងសំណួរ

ឧបសម្ព័ន្ធទី២៖ រូបភាពដែលផ្តិតយកនៅរមណីយដ្ឋានភ្នំកំពង់ត្រាច

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. ប្រវត្តិបញ្ហា

នៅក្នុងបរិបទសង្គមយុគសម័យសកលភាវូបនីយកម្ម ស្ទើរតែគ្រប់វិស័យត្រូវបានអភិវឌ្ឍន៍ ក្នុងនោះដែរវិស័យទេសចរណ៍ជាវិស័យដែលមានអាទិភាពសម្រាប់បណ្តាប្រទេសនានាលើសកលលោកធ្វើការអភិវឌ្ឍដើម្បីទ្រទ្រង់សេដ្ឋកិច្ចរបស់ខ្លួន។ សកម្មភាពទេសចរណ៍នៅតាមតំបន់នីមួយៗបានបង្ហាញច្បាស់អំពីកត្តាសន្តិសុខ សុវត្ថិភាព ទិដ្ឋភាពជាក់ស្តែងរបស់ប្រជាជនក្នុងស្រុក របៀបរបបនៃការរស់នៅពេលភ្ញៀវចូលមកទស្សនា។

នៅលើពិភពលោកសព្វថ្ងៃនេះ ប្រជាជនដែលបានធ្វើដំណើរទៅក្រៅប្រទេសមានការកើនឡើងជាលំដាប់ ហើយក្នុងប្រទេសនីមួយៗកំពុងពិចារណាចំពោះការអភិវឌ្ឍវិស័យទេសចរណ៍ដែលជាវិស័យមួយដ៏សំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។ ប្រមាណជាជាងពាក់កណ្តាលទសវត្សកន្លងមកនេះ វិស័យទេសចរណ៍មានការវិវត្តយ៉ាងខ្លាំងក្លានៅលើពិភពលោក។ មនុស្សភាគច្រើនក៏មានលទ្ធភាព និងមធ្យោបាយគ្រប់គ្រាន់ក្នុងការធ្វើដំណើរផងដែរ មិនត្រឹមតែប៉ុណ្ណោះវិមាត្រនៃទំហំទេសចរណ៍ក៏មានការលូតលាស់យ៉ាងខ្លាំងដូចគ្នា។ ក្នុងឆ្នាំ ២០១៦ ចំនួនទេសចរអន្តរជាតិដែលបានធ្វើដំណើរកម្សាន្តក្នុងពិភពលោកមានចំនួនសរុប ១,២៣៥ លាននាក់[1]។ ក្នុងនោះដែរប្រទេសកម្ពុជាក៏បានស្រូបទាញយកទេសចរ ដែលចូលមកកម្សាន្តក្នុងតំបន់ទេសចរណ៍មានចំនួន ៥,០១១,៧១២ នាក់[2]។

ប្រទេសកម្ពុជា ជាប្រទេសមួយដែលសម្បូរទៅដោយសក្តានុពលទេសចរណ៍ធនធានធម្មជាតិ វប្បធម៌ ប្រវត្តិសាស្ត្រ ដែលក្នុងនោះមានប្រាង្គប្រាសាទបុរាណរាប់ពាន់ពាសពេញផ្ទៃប្រទេសកម្ពុជាត្រូវបានសាងសង់ឡើងដោយបុព្វបុរសខ្មែរជាមួយនឹងក្បូរក្បាច់រចនាដ៏រស់រវើក ថែមទាំងមានតំបន់ឆ្នេរ តំបន់ភូមិភាគខ្ពង់រាប ដែលជាពិសេសនោះគឺប្រាសាទអង្គរវត្តដែលត្រូវបានគេស្គាល់ពាសពេញពិភពលោកថាជាសម្បត្តិបេតិកភណ្ឌរបស់ប្រទេសកម្ពុជា។ ម្យ៉ាងវិញទៀតប្រទេសកម្ពុជាយើងក៏សម្បូរទៅដោយតំបន់ទាក់ទាញទេសចរជាច្រើនផ្សេងទៀតផងដែរ អាស្រ័យហេតុនេះហើយ ទើបក្រសួងទេសចរណ៍ដែលជាសេនាធិការផ្ទាល់បានធ្វើការកំណត់នូវប៉ូលអភិវឌ្ឍន៍តំបន់ទេសចរណ៍ចំនួន៤ ធំៗគឺ៖

[1] http://statistics.unwto.org/publication/yearbook-tourism-statistics-2017-edition ចូលទស្សនាថ្ងៃទី១២ កក្កដា ឆ្នាំ ២០១៧

[2] http://www.tourismcambodia.org/mot/index.php?view=statistic_report ចូលទស្សនាថ្ងៃទី២២ ឧសភា ឆ្នាំ២០១៧

- ទីក្រុងភ្នំពេញ និងតំបន់ជុំវិញ ជារាជធានីមួយដ៏ល្បីល្បាញនៅអាស៊ីអាគ្នេយ៍ និងជាមជ្ឈមណ្ឌលនយោបាយ វប្បធម៌ ពាណិជ្ជកម្ម ទេសចរណ៍ ហើយក៏ជាទីតាំងប្រសព្វនៃទន្លេមេគង្គបែកជាមុខបួន និងសក្តានុពលទេសចរណ៍ (តំបន់ជុំវិញបឹងទន្លេសាប ព្រះបរមរាជវាំង សារមន្ទីរជាតិ)
- អង្គរ និងតំបន់ជុំវិញ ជាតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រដែលមានភាពល្បីល្បាញនៅលើពិភពលោក (ប្រាសាទអង្គរវត្ត ប្រាសាទបាយ័ន និងប្រាសាទជាច្រើនផ្សេងទៀត)
- តំបន់ឆ្នេរ ជាតំបន់អេកូទេសចរណ៍ ដែលមានភាពទាក់ទាញខ្លាំង (ខេត្តកំពត ខេត្តកោះកុង ខេត្តកែប និងខេត្តព្រះសីហនុ
- តំបន់ភូមិភាគឦសាន ជាតំបន់អេកូទេសចរណ៍ដែលរំលេចទៅដោយភាពទោល ជាពិសេសសត្វផ្សោត ទន្លេមេគង្គ ទេសភាពធម្មជាតិ និងវប្បធម៌ប្រពៃណីរបស់ជនជាតិភាគតិច (ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តមណ្ឌលគិរី និងខេត្តរតនគិរី)[3]។

ដោយសារតែកត្តានៃតំបន់ទាក់ទាញទាំងអស់នេះហើយ ទើបមានការរីកចម្រើននៃវិស័យទេសចរណ៍នេះដែលបានបង្កើតនូវប្រាក់ចំណូល និងការងារដល់ប្រជាពលរដ្ឋក្នុងតំបន់ឲ្យមានជីវភាពធូរធារក៏ដូចជាជួយកាត់បន្ថយភាពក្រីក្រផងដែរ។ លើសពីនេះទេសចរណ៍ គឺជាការនាំចេញ រួមចំណែកក្នុងការទប់ស្កាត់តុល្យភាពនៃជញ្ជីងពាណិជ្ជកម្ម និងការលើកកម្ពស់គុណភាពដើម្បីប្រកួតប្រជែងលើឆាកអន្តរជាតិ។

ក្នុងចំណោមតំបន់ទាក់ទាញទេសចរណ៍សំខាន់ៗខាងលើនេះដែរខេត្តកំពត ជាខេត្តមួយស្ថិតនៅក្នុងតំបន់ឆ្នេរដែលសម្បូរទៅដោយធនធានធម្មជាតិ ប្រវត្តិសាស្ត្រ ផលិតផលដំណាំ ផ្លែឈើ ក៏ដូចជាមានរមណីយដ្ឋានជាច្រើនដែលស្ថិតក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល បានធ្វើឲ្យខេត្តនេះមានការរីកចម្រើនជាលំដាប់ទៅលើគ្រប់វិស័យរួមមានសាលារៀន មន្ទីរពេទ្យ ស្ពាន ផ្លូវថ្នល់ជាដើម។ ក្នុងនោះដែររមណីយដ្ឋានភ្នំកំពង់ត្រាច ក៏ជាតំបន់ទេសចរណ៍ដែលមានភាពទាក់ទាញមួយក្នុងខេត្តកំពត ដែលមានធនធានធម្មជាតិ វប្បធម៌ ប្រវត្តិសាស្ត្រ រូងភ្នំ ព្រៃឈើ និងល្អាងជាច្រើនផងដែរ។ តាមការចុះត្រួតពិនិត្យផ្ទាល់យើងសង្កេតឃើញថា រមណីយដ្ឋានភ្នំកំពង់ត្រាចមានការរៀបចំប៉ុន្តែតាមការអង្កេតឃើញមិនមានការអភិវឌ្ឍ និងមិនទាន់មានអ្នកសិក្សាស្រាវជ្រាវនៅឡើយទេ ហើយនៅមានបញ្ហាប្រឈមជាច្រើនទៀតដែលមិនទាន់បានដោះស្រាយដូចជាកង្វះបរិស្ថាន និងអនាម័យ គុណភាពចំណីអាហារ ខ្វះការគ្រប់គ្រងសន្តិសុខ និងសុវត្ថិភាពផ្សេងទៀត។

[3] ក្រសួងទេសចរណ៍, *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ ២០១២-២០២០*, ថ្ងៃទី២០ កក្កដា ២០១២, ១៣

ហេតុនេះហើយទើបក្រុមយើងខ្ញុំ បានសម្រេចចិត្តជ្រើសរើសយកតំបន់មួយនេះមកធ្វើការស្រាវជ្រាវក្រោមប្រធានបទ "ការអភិវឌ្ឍរមណីយដ្ឋានទេសចរណ៍ប្រកបដោយនិរន្តរភាព" ករណីសិក្សារមណីយដ្ឋានភ្នំកំពង់ត្រាច (កំពត)"។

## ២. ចំណោទបញ្ហា

រមណីយដ្ឋានភ្នំកំពង់ត្រាចមានសក្តានុពល និងមានការរៀបចំអភិវឌ្ឍន៍សមរម្យទាក់ទាញទេសចរជាតិ និងអន្តរជាតិឲ្យមកទស្សនាកម្សាន្តនៅទីនេះមិនដាច់ឡើយ។ តើស្ថានភាពនៃការអភិវឌ្ឍទេសចរណ៍ និងបញ្ហាប្រឈមអ្វីខ្លះដែលកើតមាននៅក្នុងរមណីយដ្ឋានភ្នំកំពង់ត្រាច? តើគួរមានយុទ្ធសាស្ត្រអ្វីខ្លះ ដើម្បីរៀបចំអភិវឌ្ឍន៍រមណីយដ្ឋានភ្នំកំពង់ត្រាចឲ្យកាន់តែមានភាពទាក់ទាញទេសចរជាតិនិងអន្តរជាតិមកកម្សាន្តនៅរមណីយដ្ឋាននេះ។

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងចម្បងនៃការស្រាវជ្រាវ គឺរួមចំណែកផ្តល់ជាទស្សនទាន គំនិតបន្ថែម ក្នុងការកែលម្អ អភិវឌ្ឍន៍ផលិតផលទេសចរណ៍ សេវាកម្មក្នុងតំបន់រមណីយដ្ឋានភ្នំកំពង់ត្រាចឲ្យមានភាពល្អប្រសើរដើម្បីបង្កើនភាពទាក់ទាញទាំងភ្ញៀវជាតិ និងអន្តរជាតិបន្ថែមទៀត។ ដើម្បីសម្រេចគោលបំណងនេះ ការស្រាវជ្រាវត្រូវបានកំណត់ចេញនូវកម្មវត្ថុសម្រាប់ការសិក្សាដូចខាងក្រោម៖

- ទ្រឹស្តីនានាទាក់ទងនឹងបញ្ញត្តិទេសចរណ៍ និងការអភិវឌ្ឍទេសចរណ៍
- ស្ថានភាពទូទៅនៃទេសចរណ៍ខេត្តកំពត
- ទស្សនទានក្នុងការអភិវឌ្ឍរមណីយដ្ឋានភ្នំកំពង់ត្រាច

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

វិសាលភាពនៃការសិក្សានេះ ផ្តោតសំខាន់ទៅលើរមណីយដ្ឋានភ្នំកំពង់ត្រាច សហគមន៍ និងតំបន់ជុំវិញមួយចំនួនរួមមានភូមិដំណាក់កន្ទួត ឃុំដំណាក់កន្ទួតខាងត្បូង ស្រុកកំពង់ត្រាច។ រីឯឯកសារដែលត្រូវយកមកសិក្សា គឺត្រូវបានកំណត់យកត្រឹមឆ្នាំ ២០១៤-២០១៦ ហើយឯកសារមុនឆ្នាំនៃដែនកំណត់នេះក៏ត្រូវលើកយកមកស្រាវជ្រាវ ដើម្បីឲ្យកាន់តែងាយស្រួលក្នុងការវិភាគទិន្នន័យផងដែរ។

## ៥. វិធីសាស្ត្រស្រាវជ្រាវ

ដើម្បីសម្រេចបាននូវលទ្ធផលល្អនៃការស្រាវជ្រាវ វិធីសាស្ត្រមួយចំនួនត្រូវបានលើកយកមកប្រើប្រាស់រួមមានប្រភេទ និងប្រភពទិន្នន័យ ការប្រមូលទិន្នន័យ និងការវិភាគទិន្នន័យ។

### ក. ប្រភព និងប្រភេទទិន្នន័យ

ក្នុងការស្រាវជ្រាវលើប្រធានបទនេះ ការប្រមូលទិន្នន័យត្រូវបានកំណត់ប្រមូលយកទាំងទុតិយាទិន្នន័យ និងបឋមទិន្នន័យ។

ទុតិយាទិន្នន័យដែលយកមកប្រើប្រាស់សម្រាប់ការស្រាវជ្រាវនេះ មានលក្ខណៈជាភាសាជាតិដែលមានគោលដៅ និងទីកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា។ ឯកសារទុតិយាទិន្នន័យមួយចំនួនត្រូវបានប្រមូលយកពីមន្ទីរទេសចរណ៍ខេត្តកំពត បណ្ណាគារ បណ្ណាល័យសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច វចនានុក្រមខ្មែរសម្តេចសង្ឃរាជ ជួន ណាត ។ ឯកសារប្រមូលទាំងនោះមានច្រើនប្រភេទដូចជា របាយការណ៍ ឯកសារជាស្នាដៃ ឯកសារនិពន្ធជាភាសាខ្មែរ និងភាសាអង់គ្លេស ឯកសារផ្សេងទៀតយកចេញពីបណ្តាញ Internet តាមរយៈគេហទំព័ររបស់ក្រសួងទេសចរណ៍ និងគេហទំព័រផ្សេងៗទៀត។

ចំណែក បឋមទិន្នន័យសម្រាប់ការស្រាវជ្រាវនេះវិញ គឺការចុះអង្កេតផ្ទាល់ពីស្ថានភាពតំបន់ជាក់ស្តែង ដើម្បីប្រមូលពត៌មានលម្អិត និងពិតប្រាកដតាមរយៈការប្រើប្រាស់កម្រងសំណួរ និងការចុះសម្ភាសន៍ជាមួយទេសចរ និងប្រជាពលរដ្ឋក្នុងតំបន់នោះ ព្រមទាំងការថតរូបផ្តិតយកទិដ្ឋភាពទូទៅនៃរមណីយដ្ឋានភ្នំកំពង់ត្រាចផងដែរ។

### ខ. ការប្រមូលទិន្នន័យ

ការប្រមូលទិន្នន័យដែលយើងយកមកអនុវត្ត ក្នុងការស្រាវជ្រាវសម្រាប់ប្រធានបទនេះមានដូចជា ការកំណត់គំរូតាង កម្រងសំណួរ ការចុះអង្កេត និងការសម្ភាស។

**ការកំណត់គំរូតាង:** ជាការប្រមូលទិន្នន័យ ដែលបានមកពីការសម្ភាសដោយធ្វើការចែកនូវគំរូតាងជា ៣ប្រភេទមានដូចជាទេសចរ (ចំនួន៥0) អាជីវករ (ចំនួន២0) និងអាជ្ញាធរ (ចំនួន១0) ដែលមានចំនួនសរុប ៨0គំរូតាង។

**កម្រងសំណួរ:** សំណួរដែលត្រូវបានរៀបចំមានចំនួនសរុប ២២សំណួរ ក្នុងនោះដែរយើងបានធ្វើការបែងចែកកម្រងសំណួរចេញជា ៤ ប្រភេទ៖

- ពី ១-៣ ផ្តោតទៅលើភេទ និងមុខរបរនៃគំរូតាង
- ពី ៤-១៤ សម្រាប់សួរទេសចរមានចំនួន ១១សំណួរ
- ពី ១៥-២0 សម្រាប់សួរទៅកាន់ទេសចរមានចំនួន ៦សំណួរ
- ពី ២១-២២ សម្រាប់សួរអាជ្ញាធរមានចំនួន ២សំណួរ

**ការចុះអង្កេត:** ការចុះអង្កេតត្រូវបានធ្វើឡើង តាមរយៈការចុះត្រួតពិនិត្យមើលធនធានធម្មជាតិ វប្បធម៌ និងបន្ទាប់បន្សំគួបផ្សំជាមួយនឹងបញ្ហាប្រឈម និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងភូមិដំណាក់កន្ទួត ឃុំដំណាក់កន្ទួតខាងត្បូង ស្រុកកំពង់ត្រាច ខេត្តកំពត។

**ការសម្ភាស:** រាល់បទសម្ភាសន៍នីមួយៗត្រូវបានធ្វើការសាកសួរពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត តាមលំនៅដ្ឋានរបស់ប្រជាពលរដ្ឋ ប្រធានការិយាល័យនៃផែនការអភិវឌ្ឍន៍ទេសចរណ៍វប្បធម៌ ដោយបានធ្វើការណាត់ជួបលោកប្រធានសហគមន៍ទេសចរណ៍ក្នុងស្រុកកំពង់ត្រាចជាមុន និងទេសចរដែលកំពុងទស្សនាកម្សាន្តនៅក្នុងរមណីយដ្ឋានភ្នំកំពង់ត្រាចនោះផងដែរ។

### គ. ការវិភាគទិន្នន័យ

ការវិភាគទិន្នន័យត្រូវបានធ្វើឡើង តាមរយៈការប្រមូលចម្លើយពីការសម្ភាសចំនួនគំរូតាងទាំង៨០ ដោយគណនាជាភាគរយនៃចម្លើយគំរូតាងទាំងអស់ប្រើប្រាស់កម្មវិធី Microsoft Excel លើក្រាបផ្លិត។ ដូចនេះលទ្ធផលនៃគំរូតាងទាំងអស់ត្រូវបានគិតជាភាគរយ ហើយភាគរយដែលលេចធ្លោរជាងគេ យើងទាញយកមកធ្វើការវិភាគឲ្យស្របទៅតាមអថេរដែលយើងបានកំណត់។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

ប្រធានបទនៃការស្រាវជ្រាវនេះ ជាប្រធានបទមួយដែលអាចចូលរួមផ្តល់ជាទ្រឹស្តី និងការអនុវត្តជាក់ស្តែងក្នុងការអភិវឌ្ឍទេសចរណ៍ ដែលមានការចូលរួមពីប្រជាជនក្នុងតំបន់ អាជីវករ និងស្ថាប័នពាក់ព័ន្ធនានា ដោយយោងតាមឯកសារសម្អាងជាច្រើន ការចុះអង្កេត និងការសម្ភាសផ្ទាល់ជាមួយសហគមន៍ក្នុងតំបន់គោលដៅអភិវឌ្ឍទេសចរណ៍។ ប្រធានបទនេះបានផ្តល់ជាប្រយោជន៍ដូចខាងក្រោម៖

- ជាឯកសារសម្រាប់ជំនួយដល់អ្នកសិក្សាទេសចរណ៍ ដែលចង់សិក្សាស្វែងយល់ពីទ្រឹស្តីនៃការអភិឌ្ឍទេសចរណ៍ ក៏ដូចជាការអភិវឌ្ឍវិស័យទេសចរណ៍ ដើម្បីឲ្យវិស័យនេះមានការរីកចម្រើន និងប្រកបដោយនិរន្តរភាព។
- ផ្តល់ជាគំនិត ក៏ដូចជាទស្សនៈមួយចំនួនក្នុងការចូលរួមលើកស្ទួយវិស័យទេសចរណ៍ក្នុងតំបន់អភិវឌ្ឍទេសចរណ៍ និងជំរុញឲ្យកាន់តែមានភាពរីកចម្រើន។
- ផ្តល់ជាគម្រោងក្នុងការរៀបចំអភិវឌ្ឍន៍ទេសចរណ៍ ក្នុងគោលបំណងលើកស្ទួយអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងជីវភាពប្រជាពលរដ្ឋម្ចាស់ស្រុក។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណានេះត្រូវបានរៀបចំជា ៥ ផ្នែកធំៗដូចខាងក្រោម ៖

**ផ្នែកទី១:** សេចក្តីផ្តើម ផ្តោតទៅលើចំណុចចំនួន ៧ដូចជា ប្រវត្តិបញ្ហា ចំណោទបញ្ហា គោលបំណងនៃការស្រាវជ្រាវ ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ វិធីសាស្ត្រស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវនេះ។

**ផ្នែកទី២:** បង្ហាញអំពីខ្លឹមសារនៃសារណាដែលរួមមាន ៣ជំពូកធំៗដូចខាងក្រោម ៖

ជំពូក១. ទ្រឹស្តីនានាទាក់ទងនឹងបញ្ញត្តិទេសចរណ៍ និងការអភិវឌ្ឍទេសចរណ៍ ជាគន្លឹះដែលរំលឹករាល់ទ្រឹស្តីទាក់ទងនឹងប្រធានបទតាមរយៈការធ្វើសំយោគពាក្យនីមួយៗ ចេញពីអត្ថន័យដែលត្រូវបានកំណត់ដោយក្រសួងទេសចរណ៍ អ្នកនិពន្ធពីប្រភពផ្សេងៗគ្នា និងធ្វើការសន្និដ្ឋានអំពីអត្ថន័យនៃប្រធានបទជារួម។

ជំពូក២. ស្ថានភាពទូទៅនៃទេសចរណ៍ខេត្តកំពត ជាជំពូកស្នូលមួយដែលរៀបរាប់អំពីស្ថានភាពជាក់ស្តែងនៅតំបន់រមណីយដ្ឋាន សក្តានុពល ក៏ដូចជាបញ្ហាប្រឈមនានាក្នុងការអភិវឌ្ឍរមណីយដ្ឋាន និងបង្ហាញពីក្រាបទិន្នន័យដែលត្រូវបានវិភាគ។

ជំពូក៣. ទស្សនទានក្នុងការអភិវឌ្ឍរមណីយដ្ឋានភ្នំកំពង់ត្រាច ជាជំពូកដ៏សំខាន់ដែលបង្ហាញពីការរកឃើញនូវគន្លឹះថ្មីៗ និងទ្រឹស្តីអភិវឌ្ឍន៍រមណីយដ្ឋានភ្នំកំពង់ត្រាចប្រកបដោយនិរន្តរភាព។ ជារួមតាមការថ្លឹងថ្លែងវិភាគទិន្នន័យចម្បង និងទិន្នន័យបន្ទាប់បន្សំដែលបានប្រមូលទាក់ទងនឹងទ្រឹស្តីត្រូវបានរៀបរាប់ក្នុងជំពូកពីរខាងលើ រួមផ្សំជាមួយនឹងសំណុំឯកសារអភិវឌ្ឍន៍របស់ខេត្ត និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត។

**ផ្នែកទី៣:** សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ជាការសរុបសេចក្តីអំពីសារណា និងធ្វើការផ្តល់អនុសាសន៍ជាយោបល់បន្ថែមពីអ្វីដែលបានបកស្រាយ និងស្រាវជ្រាវឃើញ។

**ផ្នែកទី៤:** ឯកសារយោង ជាផ្នែកមួយដែលផ្ទុកនូវរាល់ប្រភពសំណុំឯកសារពាក់ព័ន្ធនៅក្នុងកិច្ចការស្រាវជ្រាវទាំងមូល។

**ផ្នែកទី៥:** ឧបសម្ព័ន្ធ សំដៅដល់ភស្តុតាងជាលិខិតរដ្ឋបាលពាក់ព័ន្ធ ឯកសារស្រាវជ្រាវ កម្រងសំណួរ និងកម្រងរូបភាពដែលទាក់ទងនឹងស្ថានភាពនៃទីតាំងរបស់ប្រធានបទ។

# ជំពូកទី ១
# ទ្រឹស្តីនៃការអភិវឌ្ឍ
# ទេសចរណ៍

# ជំពូកទី ១

# ទ្រឹស្តីនៃការអភិវឌ្ឍទេសចរណ៍

## ១.១ ទេសចរណ៍គឺជាអ្វី?

តាមរយៈការសិក្សា និងការស្រាវជ្រាវអំពីនិយមន័យទេសចរណ៍ ត្រូវបានអ្នកប្រាជ្ញជាច្រើនធ្វើការកំណត់និយមន័យដែលមានដោយផ្អែកតាមទស្សនៈផ្សេងៗគ្នា។

យោងតាមវចនានុក្រម Oxford Leaner's Pocket Dictionary ទេសចរណ៍ គឺជាសកម្មពភាពជំនួញដែលទាក់ទងនឹងការផ្តល់ទីកន្លែងស្នាក់នៅ សេវាផ្សេងៗ និងការកម្សាន្តសម្រាប់មនុស្សដែលទៅទស្សនាកន្លែងណាមួយដើម្បីភាពសប្បាយរីករាយ[4]។

ចំណែកឯច្បាប់ទេសចរណ៍របស់សាធារណៈរដ្ឋបារាំង និយមន័យទេសចរណ៍គឺ ជាការធ្វើដំណើរក្នុងរយៈពេលមួយរបស់ប្រជាពលរដ្ឋ ឬមហាជនពីទីស្នាក់នៅជាអចិន្ត្រៃយ៍របស់ខ្លួនទៅកាន់ប្រទេសណាមួយ ឬតំបន់ណាមួយក្នុងប្រទេស នៅពេលទំនេរក្រៅពីការងារក្នុងគោលបំណងទទួលបានការសប្បាយរីករាយ សម្រាក ព្យាបាល ទស្សនកិច្ច ស្វែងយល់ សាសនា និងអាជីវកម្ម តែមិនបានត្រូវអនុញ្ញាតឲ្យបំពេញការងារ ដែលទទួលបាននូវប្រាក់កម្រៃក្នុងតំបន់ដែលបានទៅដល់ឡើយ[5]។

ផ្អែកតាមច្បាប់ព្រះរាជាណាចក្រកម្ពុជា "ទេសចរណ៍" សំដៅដល់សកម្មភាពទាំងឡាយរបស់បុគ្គលដែលធ្វើដំណើរ និងស្នាក់នៅកន្លែងផ្សេងៗក្រៅពីបរិយាកាសប្រក្រតីរបស់ពួកគេសម្រាប់រយៈពេលកំណត់ណាមួយ ដែលមិនលើសពីមួយឆ្នាំជាប់ៗគ្នាដើម្បីសម្រាកលំហែ កម្សាន្ត ធុរកិច្ច និងគោលបំណងទេសចរណ៍ស្របច្បាប់ផ្សេងៗទៀត[6]។

វាមានភាពខុសគ្នាមែន ប៉ុន្តែអត្ថន័យជារួមមកនៃនិយមន័យខាងលើមានភាពប្រហាក់ប្រហែលគ្នា ដូចនេះនិយមន័យទេសចរណ៍ សំដៅដល់ ការសម្រាកលំហែកម្សាន្ត សកម្មភាពកីឡា សកម្មភាពសាសនា ធុរកិច្ច សួរសុខទុក្ខសាច់ញាតិ ព្យាបាលសុខភាព និងគោលបំណងស្របច្បាប់ផ្សេងៗ ដើម្បីគេចចេញពីជីវភាពដដែលៗប្រចាំថ្ងៃ ដែលសកម្មភាពនេះមិនតិចជាងមួយថ្ងៃ និងមិនលើសពីមួយឆ្នាំ ហើយមិនមែនក្នុងគោលបំណងស្វែងរកប្រាក់ចំណូល។

[4] វចនានុក្រម "Oxford Learner's Pocket Dictionary"

[5] ហុង វណ្ណៈ ជា ស៊ីថា និងសហការី ,សេចក្តីផ្តើមទេសចរណ៍ (ភ្នំពេញ:១០ តុលា ២០១៤), ៥៥

[6] ក្រសួងទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា ,ច្បាប់ស្តីពីទេសចរណ៍ (ក្នុងឧបសម្ព័ន), ៣១

## ១.២ ប្រភេទទេសចរណ៍

យោងតាមការសិក្សា គេសង្កេតឃើញថាទេសចរណ៍ត្រូវបានបែងចែកជាច្រើនប្រភេទ ប៉ុន្តែក្នុងឯកសារនេះយើងបានលើកយកតែពាក្យ ទេសចរណ៍ក្នុងស្រុក (Domestic Tourism) ទេសចរណ៍ជាតិ (National Tourism) ទេសចរណ៍អន្តរជាតិ (International Tourism) ទេសចរណ៍ផ្ទៃក្នុង (Internal Tourism) និងទេសចរណ៍សង្គម (Social Tourism) ដើម្បីយកមកបកស្រាយជានិយមន័យដូចខាងក្រោម៖

"ទេសចរណ៍ក្នុងស្រុក" (Domestic Tourism) សំដៅទៅលើសកម្មភាពទេសចរណ៍ ដែលភ្ជាប់ជាមួយការធ្វើដំណើរជាទេសចរ និងធ្វើសកម្មភាពទេសចរណ៍របស់ប្រជាពលរដ្ឋនៅលើទឹកដីនៃប្រទេសកំណើត (ប្រទេសដែលគេរស់នៅអចិន្ត្រៃយ៍)[7]។

"ទេសចរណ៍ក្នុងស្រុក" សម្គាល់លើដំណើរកម្សាន្តដែលត្រូវបានធ្វើឡើងដោយប្រជាជនក្នុងស្រុក ដើម្បីដើរកម្សាន្តក្នុងប្រទេសរបស់ពួកគេ[8]។

"ទេសចរណ៍ក្នុងស្រុក" ជារួមមានអត្ថន័យថា ជាសកម្មភាពធ្វើដំណើរទស្សនាលំហែរបស់ប្រជាជននៃជាតិសាសន៍មួយដែលធ្វើដំណើរ សម្រាក លំហែក្នុងទឹកដីកំណើតរបស់ពួកគេផ្ទាល់ដោយមិនបានឆ្លងកាត់ហួសព្រំដែនទៅកាន់ប្រទេសក្រៅ។

ចំពោះពាក្យ "ទេសចរណ៍ជាតិ" (National Tourism) វិញ ក៏មានអ្នកស្រាវជ្រាវផ្នែកទេសចរណ៍ និងប្រភពឯកសារជាច្រើនបានលើកមកពន្យល់ផងដែរ។

"ទេសចរណ៍ជាតិ" គឺជាចង្កោមការងារដែលបម្រើឲ្យទេសចរណ៍ក្នុងស្រុក និងទេសចរណ៍ក្រៅប្រទេស។ ដូច្នេះទេសចរណ៍ជាតិ ជាសកម្មភាពរបស់ជនជាតិនៃប្រទេសណាមួយដែលអាចធ្វើដំណើរទេសចរណ៍ក្នុងស្រុក ឬទេសចរណ៍ក្រៅប្រទេស[9]។

សង្ខេបមក "ទេសចរណ៍ជាតិ" សំដៅដល់សកម្មភាពដំណើរកម្សាន្តជាទេសចរណ៍របស់ប្រជាពលរដ្ឋនៃជាតិសាសន៍មួយនៅក្នុងទឹកដី និងតំបន់នានានៃប្រទេសនោះ ឬចេញទៅក្រៅប្រទេសក្នុងទម្រង់ជាទេសចរណ៍ជាតិរបស់ប្រទេសដើមកំណើត។

ចំណែក "ទេសចរណ៍អន្តរជាតិ" (International Tourism) ជាសកម្មភាពដែលចងភ្ជាប់ជាមួយការធ្វើដំណើរទេសចរណ៍ និងសកម្មភាពទេសចរណ៍របស់ប្រជាពលរដ្ឋពីប្រទេសមួយទៅ

[7] ហាុង វណ្ណៈ ជា ស៊ីថា និងសហការី ,សេចក្ដីផ្ដើមទេសចរណ៍ (ភ្នំពេញ៖ ០១ តុលា ២០១៤), ៨៧

[8] https://www.slideshare.net/GlyGly1/domestic-tourism-64202191 ចូលទស្សនាថ្ងៃទី២៥ មិថុនា ឆ្នាំ២០១៧

[9] ហាុង វណ្ណៈ ជា ស៊ីថា និងសហការី ,សេចក្ដីផ្ដើមទេសចរណ៍, (ភ្នំពេញ៖ ០១ តុលា ២០១៤), ៩១

កាន់ប្រទេសមួយទៀត។ តាមរយៈនៃការធ្វើដំណើរនេះ ទេសចរណ៍អន្តរជាតិដែលត្រូវបែងចែកជាពីរគឺ៖

ទេសចរណ៍បរទេស (Inbound Tourism ) សំដៅលើជនទាំងឡាយណាដែលធ្វើដំណើរចូលមកកាន់ប្រទេសណាមួយ ហើយស្នាក់នៅទីនោះលើសពីរយៈពេល២៤ម៉ោង តែតិចជាងមួយឆ្នាំ ក្នុងគោលបំណងផ្សេងៗដែលមិនពាក់ព័ន្ធនឹងការស្វែងរកការងារ[10]។

ទេសចរណ៍ក្រៅប្រទេស (Outbound Tourism) សំដៅទៅលើជនទាំងឡាយណាដែលធ្វើដំណើរ និងស្នាក់នៅកន្លែងក្រៅពីប្រទេសរបស់ពួកគេ និងនៅខាងក្រៅបរិយាកាសធម្មតារបស់ពួកគេសម្រាប់រយៈពេលមិនលើសពី ១២ខែសម្រាប់កម្សាន្ត និងគោលបំណងផ្សេងទៀតដែលមិនពាក់ព័ន្ធនឹងការស្វែងរកការងារ[11]។

ទាក់ទងនឹង "ទេសចរណ៍ផ្ទៃក្នុង" ( Internal Tourism ) ក៏មានការលើកបញ្ជាក់ពីការសិក្សាស្រាវជ្រាវឯកសារទេសចរណ៍ជាច្រើនទៀតដែរ។

"ទេសចរណ៍ផ្ទៃក្នុង" សំដៅលើទេសចរដែលធ្វើដំណើរកំសាន្តក្នុងស្រុក (Domestic Tourism) និងទេសចរដែលធ្វើដំណើរកម្សាន្តចូលមកក្នុងប្រទេសយើង ( Inbound Tourism )[12]។

"ទេសចរណ៍ផ្ទៃក្នុង" គឺជាសកម្មភាពធ្វើដំណើររបស់ប្រជាជនក្នុងប្រទេសមួយ រួមទាំងទេសចរបរទេសដែលធ្វើដំណើរក្នុងប្រទេសមួយនោះ[13]។

ជារួម "ទេសចរណ៍ផ្ទៃក្នុង" ជាដំណើរទេសចរណ៍របស់ជនបរទេស ឬម្ចាស់ស្រុកនៅតាមទីកន្លែងទាក់ទាញទេសចរណ៍ ឬតំបន់នានាក្នុងទឹកដីនៃប្រទេសរបស់ម្ចាស់ស្រុកនោះ។

រីឯពាក្យ "ទេសចរណ៍សង្គម" ( Social Tourism ) ក៏មានការឲ្យនិយមន័យជាច្រើនដោយឡែកពីគ្នាមួយចំនួនដែរ។

"ទេសចរណ៍សង្គម" ជាប្រភេទទេសចរណ៍ដែលបង្កើតឡើងដោយរាជរដ្ឋាភិបាលសម្រាប់ទ្រទ្រង់ដល់សិស្ស និសិត្ស យុវវ័យ អ្នកចូលនិវត្តន៍ ជនពិការ និងប្រជាពលរដ្ឋរបស់ខ្លួនបានចូលរួមធ្វើដំណើរទេសចរណ៍ និងបានធ្វើសកម្មភាពទេសចរណ៍ពិសេសក្នុងរដូវទេសចរណ៍តិច (Low Season)[14]។

---

[10] www.sesric.org/imgs/news/File/1050-presentations/sudan.pdf ចូលទស្សនាថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៧

[11] http://www.stat.fi/meta/kas/ulkommatkailu_en.html ចូលទស្សនាថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០១៧

[12] http://www.stat.fi/meta/kas/maansis_matk_en.html ចូលទស្សនាថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០១៧

[13] https://www.slideshare.net/sabinjoseph2/tourism-43551540 ចូលទស្សនាថ្ងៃទី ២១ ឧសភា ឆ្នាំ ២០១៧

[14] ហុង វណ្ណៈ ជា ស៊ីថា និងសហការី ,សេចក្តីផ្តើមទេសចរណ៍, (ភ្នំពេញ៖០១ តុលា ២០១៤), ៩៣

ម្យ៉ាងទៀត ទេសចរណ៍សង្គម សំដៅទៅលើសកម្មភាព កម្មវិធី ឬព្រឹត្តិការណ៍ដែលអាចឲ្យប្រជាជនទាំងអស់ជាពិសេសយុវជន ក្រុមគ្រួសារ អ្នកចូលនិវត្តន៍ បុគ្គលដែលមានប្រាក់ចំណូលតិចតួចនិងបុគ្គលដែលមានសមត្ថភាពរាងកាយមានកម្រិត បានចូលរួមដើម្បីភាពរីករាយនឹងវិស័យទេសចរណ៍ខណ:ពេលដែលបានចូលរួមក្នុងទំនាក់ទំនងរវាងភ្ញៀវនិងសហាគមន៍ម្ចាស់ផ្ទះ[15]។

## ១.៣ ការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព

មានទស្សន:ជាច្រើន ដែលទាក់ទងទៅនឹងការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តភាព។ ដោយទស្សន:ទាំងនោះគឺមានលក្ខណ:ខុសប្លែកពីគ្នា ប៉ុន្តែអត្ថន័យរបស់វាមានន័យដូចគ្នា ដែលសំដៅទៅលើការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តភាព។ មុននឹងបកស្រាយពីនិយមន័យនេះ យើងត្រូវដឹងពាក្យសំខាន់ៗជាមុនសិនដូចជាពាក្យ **"អភិវឌ្ឍន៍"** និងពាក្យ **"និរន្តភាព"** ជាមុនសិន។ ចំពោះការកំណត់និយមន័យ ដែលទាក់ទងនឹងពាក្យ **"ការអភិវឌ្ឍ"** ត្រូវបានគេឲ្យនិយមន័យជាច្រើនដូចខាងក្រោម៖

តាមសៀវភៅ "ការអភិវឌ្ឍ និងផែនការទេសចរណ៍" **ការអភិវឌ្ឍ** មានន័យថាជាការផ្លាស់ប្តូរកម្រិតជីវភាពរស់នៅរបស់ប្រជាជាតិឲ្យមានការរីកចម្រើន និងប្រសើរឡើង[16]។

វចនានុក្រមព្រះសង្ឃរាជ **ជួន ណាត** បានពន្យល់ថា "ចម្រើនក្រៃលែង លូតលាស់ចំរើន[17]។

តាមវចនានុក្រម Cambridge Dictionary របស់ប្រទេសអង់គ្លេសបានឲ្យនិយមន័យ **ការអភិវឌ្ឍ** ជាដំណើរការ ឬអ្វីមួយដែលមានការលូតលាស់ឬផ្លាស់ប្តូរ ហើយធ្វើឲ្យមានការរីកចម្រើនបន្ថែមទៀត[18]។ មួយវិញទៀត **ការអភិវឌ្ឍ** គឺជាការកែប្រែធនធានមនុស្ស សម្ភារ:មធ្យោបាយ និងបណ្តាធនធានធម្មជាតិ ឲ្យកាន់តែប្រសើរឡើងដែលសម្ភារ:នោះសំដៅដល់ផ្ទះ សាលារៀន ផ្លូវថ្នល់ មន្ទីរពេទ្យ និងអណ្តូងទឹកជាដើម[19]។

ចំណែកឯពាក្យ "និរន្តរភាព" មានន័យថាគង់វង្សយូរអង្វែងដែលបន្ត ឬបន្សល់ទុកពីមួយជំនាន់ទៅមួយជំនាន់ទៀត។

**និរន្តរភាព** មានអត្ថន័យថា ជាការធ្វើឲ្យមានផលប៉ះពាល់អវិជ្ជមានក្នុងកម្រិតទាបបំផុត ឬគ្មានភាពខូចខាតធ្ងន់ធ្ងរដល់បរិស្ថាន ដែលធានាបានសារ:ប្រយោជន៍យូរអង្វែង។

---

[15] http://www.shtourism.eu/social-tourism.html ចូលទស្សនាថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៧

[16] ហុង វណ្ណ: និងឈឹម ផាន់ណា, ការអភិវឌ្ឍ និងផែនការទេសចរណ៍,(ភ្នំពេញ៖ ឆ្នាំ២០១៦), ៩

[17] វចនានុក្រម សម្តេចសង្ឃរាជ ជួន ណាត), ឆ្នាំ២០០៩

[18] http://dictionary.cambridge.org/dictionary/english/development ចូលទស្សនាថ្ងៃទី២០ ឧសភា ២០១៧

[19] ហុង វណ្ណ: និងឈុន ពហុ, អេកូទេសចរណ៍, ឯកសាបង្រៀននៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ,(ភ្នំពេញ), ២០១៤, ៨០

ចំពោះអត្ថន័យនៃ ការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព ត្រូវបានលើកឡើងជាទស្សនៈផ្សេងៗដូចជា៖

តាមរយៈរបាយការណ៍គណៈកម្មការពិភពលោកស្តីពីបរិស្ថាន និងការអភិវឌ្ឍបានលើកឡើងថា **ការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព** គឺជាដំណើរការមួយដើម្បីបំពេញនូវសេចក្តីត្រូវការបច្ចុប្បន្ន ដោយមិនធ្វើឲ្យខូចប្រយោជន៍ដល់មនុស្សជំនាន់ក្រោយ សម្រាប់បំពេញតម្រូវការផ្ទាល់ខ្លួនរបស់ពួកគេនៅថ្ងៃអនាគត[20]។

ក្នុងសៀវភៅ ការអភិវឌ្ឍ និងផែនការទេសចរណ៍ បានកំណត់និយមន័យនៃ **ការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព** ដូចជា៖

ការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព គឺជាការបំពេញនូវតម្រូវការទេសចរ និងម្ចាស់ស្រុកក្នុងតំបន់នៅពេលបច្ចុប្បន្នដោយមានការការពារ និងការធ្វើឲ្យប្រសើរឡើងនូវកាលានុវត្តភាពសម្រាប់អនាគតកាល[21]។

ម្យ៉ាងវិញទៀត ការអភិវឌ្ឍប្រកបដោយនិរន្តរភាព គឺជាការបង្កើតឲ្យមានជីវិតកាន់តែប្រសើរចំពោះមនុស្សគ្រប់រូបតាមមធ្យោបាយផ្សេងៗ ដែលនឹងធ្វើឲ្យមាននិរន្តរភាពសម្រាប់អនាគតកាលក៏ដូចជានៅបច្ចុប្បន្នកាលផងដែរ។ ការអភិវឌ្ឍប្រកបដោយនិរន្តរភាពមានសសរស្តម្ភចំនួនបីរួមមាន៖

- និរន្តរភាពចំពោះសេដ្ឋកិច្ចដែលមានន័យថា ការធ្វើឲ្យមានភាពសម្បូររុងរឿងទៅតាមកម្រិតសង្គមខុសៗគ្នា និងអាចបញ្ជាក់បាននូវប្រសិទ្ធភាពនៃសកម្មភាពសេដ្ឋកិច្ចទាំងអស់។ សំខាន់ជាងនេះទៅទៀត និរន្តរភាពចំពោះសេដ្ឋកិច្ចអាចធ្វើឲ្យសហគ្រាសនានាទទួលបានជោគជ័យ និងមានលទ្ធភាពរក្សាបានស្ថេរភាពយូរអង្វែង
- និរន្តរភាពចំពោះសង្គមមានន័យថា ជាការគោរពសិទ្ធិមនុស្ស និងការធ្វើឲ្យមានកាលានុវត្តភាពស្មើៗគ្នាសម្រាប់មនុស្សទាំងអស់នៅក្នុងសង្គម។ និរន្តរភាពបែបនេះទាមទារឲ្យមានការចែកចាយនូវអត្ថប្រយោជន៍ស្មើៗគ្នា ដោយផ្តោតលើការកាត់បន្ថយភាពក្រីក្រ
- និរន្តរភាពចំពោះបរិស្ថានមានន័យថា ជាការអភិរក្ស និងគ្រប់គ្រងធនធាននានាដែលមានតម្លៃដល់ការគាំទ្រជីវិត។ ដើម្បីទទួលបាននិរន្តរភាពបរិស្ថាន វាជាការចាំបាច់ធ្វើសកម្មភាពដែលទាក់ទងដល់ការបំពុលខ្យល់ ដី និងទឹកឲ្យធ្លាក់ដល់កម្រិតអប្បបរមា និងមានការយកចិត្តទុកដាក់លើការអភិរក្សជីវសាស្ត្រចម្រុះ និងកេរតំណែលធម្មជាតិ[22]។

---

[20] ហុង វណ្ណៈ និងឈឹម ផាន់ណា "ការអភិវឌ្ឍ និងផែនការទេសចរណ៍", ភ្នំពេញ, ៨

[21] ហុង វណ្ណៈ និងឈឹម ផាន់ណា "ការអភិវឌ្ឍ និងផែនការទេសចរណ៍" , ភ្នំពេញ, ទំព័រ៨២

[22] Johannessburg, ***Tourism and Sustainability***, 2002, USA, P3

ដោយយោងតាម អង្គការទេសចរណ៍ពិភពលោក (UNWTO) បានកំណត់និយមន័យថា "ការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព" គឺជាការឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ទេសចរ និងម្ចាស់ស្រុកក្នុងតំបន់នាពេលបច្ចុប្បន្នដោយមានការការពារ និងបង្កើតជាឱកាសសម្រាប់ប្រើប្រាស់នាពេលអនាគត។ ដើម្បីធ្វើការគ្រប់គ្រងទៅលើសេចក្តីត្រូវការខាងផ្នែកសេដ្ឋកិច្ច សង្គម និងសោភ័ណភាព ដែលអាចជួយឲ្យមានភាពគង់វង្សនៃវប្បធម៌ ដំណើរនៃប្រព័ន្ធអេកូឡូស៊ី ជាពិសេសជីវសាស្ត្រចម្រុះ និងប្រព័ន្ធទ្រទ្រង់ជីវិតដ៏ទៃទៀត[23]។

សរុបជារួមមក ការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព សំដៅដល់កិច្ចការដែលធ្វើឲ្យរីកចម្រើននូវរាល់សេវាកម្មទេសចរណ៍ ហេដ្ឋារចនាសម្ព័ន្ធ និងធនធានទេសចរណ៍នានាក្នុងស្មារតីអភិរក្ស រៀបចំផែនការគ្រប់គ្រងលើការប្រើប្រាស់ឲ្យបានសមរម្យ ដើម្បីរក្សាបាននូវភាពទាក់ទាញយកសារៈប្រយោជន៍ពីធនធានដែលពាក់ព័ន្ធឲ្យបានយូរអង្វែង។

## ១.៤ ផលប៉ះពាល់អវិជ្ជមាននៃការអភិវឌ្ឍទេសចរណ៍

រាល់ការអភិវឌ្ឍទេសចរណ៍ទាំងអស់នៅលើពិភពលោក គឺដើម្បីទទួលបានផលប្រយោជន៍ខ្ពស់សម្រាប់ការអភិវឌ្ឍប្រទេស ជាពិសេសសង្គមទាំងមូល។ ផលប្រយោជន៍ដែលអ្នកអភិវឌ្ឍន៍ទេសចរណ៍ចង់បាន គឺធ្វើយ៉ាងណាឲ្យចំណេញដល់សេដ្ឋកិច្ច វប្បធម៌ សង្គម និងបរិស្ថានជាដើម។

ការអភិវឌ្ឍទេសចរណ៍ បាននាំមកនូវផលប្រយោជន៍ជាច្រើនដល់ប្រទេសជាតិទាំងមូល ប៉ុន្តែជាមួយគ្នានេះដែរ ទេសចរណ៍ក៏បាននាំមកនូវផលប៉ះពាល់អវិជ្ជមានជាច្រើនទៅលើសេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌ផងដែរ។

ក្នុងនោះផលប៉ះពាល់អវិជ្ជមានដែលមានមកលើការអភិវឌ្ឍទេសចរណ៍មានដូចជា៖[24]

**ផល់ប៉ះពាល់អវិជ្ជមានមកលើសេដ្ឋកិច្ច:** វិស័យទេសចរណ៍ក៏មានតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសជាតិនីមួយៗ។ ថ្វីត្បិតតែ វិស័យនេះបាននាំមកនូវអត្ថប្រយោជន៍សេដ្ឋកិច្ចយ៉ាងច្រើនក៏ដោយ ប៉ុន្តែវិស័យនេះក៏បាននាំមកនូវគុណវិបត្តិមួយចំនួនដល់សេដ្ឋកិច្ចផងដែរ ប្រសិនបើមិនមានការគ្រប់គ្រងច្បាស់លាស់នោះទេ។ ផល់ប៉ះពាល់អវិជ្ជមានទាំងអស់នោះបានធ្វើឲ្យមានការខាតបង់ប្រាក់ចំណេញសេដ្ឋកិច្ច ដោយសារការប្រើប្រាស់រាល់ទំនិញ បរិក្ខារ និងរបស់របរប្រើប្រាស់ក្នុងវិស័យនេះត្រូវបាននាំចូលពីបរទេស រួមទាំងការប្រើប្រាស់រូបិយប័ណ្ណបរទេសដោយគ្មានសណ្តាប់ធ្នាប់ដែលធ្វើឲ្យតម្លៃដី ទំនិញ និងសេវាកម្មមួយចំនួនដែលពាក់ព័ន្ធនឹង

[23] United National World Tourism Organization "Sustainable Tourism Development", ២០

[24] ហុង វណ្ណៈ និងឈឹម ផាន់ណា "ការអភិវឌ្ឍ និងផែនការទេសចរណ៍" , ភ្នំពេញ, ទំព័រ១៨

ទេសចរណ៍មានការកើនឡើង។ រីឯផលចំណេញសេដ្ឋកិច្ចពីការអភិវឌ្ឍទៀតសោត ពុំមានការបែងចែកគ្រប់ទិសទីដោយសារមានការអភិវឌ្ឍតំបន់តែ១ ឬ២ នៅក្នុងប្រទេស និងតំបន់ផ្សេងទៀតដោយមិនបានធ្វើការគិតគូរឲ្យបានច្បាស់លាស់។ ទន្ទឹមនឹងគ្នានេះដែរ ការអភិវឌ្ឍទេសចរណ៍មានឥទ្ធិពលចំពោះសេដ្ឋកិច្ចជាអវិជ្ជមាន ដោយសារតែការផ្តល់ឱកាសការងារ និងការលើកទឹកចិត្តច្រើនពេកដល់ជនបរទេសមកបម្រើការងារដោយមានទាំងជំនាញចាំបាច់ និងមិនចាំបាច់ចូលមកក្នុងតំបន់អភិវឌ្ឍន៍។

**ផល់ប៉ះពាល់អវិជ្ជមានមកលើបរិស្ថាន:** យើងបានដឹងហើយថា បរិស្ថានមានតួនាទីយ៉ាងសំខាន់នៅក្នុងវិស័យទេសចរណ៍ ដែលជាផ្នែកមួយសម្រាប់ទាក់ទាញទេសចរអោយមកកម្សាន្ត ហើយធានាបាននូវបទពិសោធន៍របស់ទេសចរទាំងបរិស្ថានធម្មជាតិដែលមានដូចជាដី ព្រៃភ្នំ ទន្លេ សមុទ្រ សត្វ និងបរិស្ថានកែច្នៃដូចជា ផ្លូវថ្នល់ អាគារ ដែលសុទ្ធសឹងជាមូលដ្ឋានគ្រឹះសម្រាប់ឧស្សាហកម្មទេសចរណ៍។ ប៉ុន្តែការអភិវឌ្ឍបានធ្វើឲ្យមានផល់ប៉ះពាល់អវិជ្ជមានជាច្រើន ដែលក្នុងនោះមានការកាប់បំផ្លាញព្រៃឈើ ការបាញ់សម្លាប់សត្វព្រៃ និងធនធានធម្មជាតិនានា។ មិនតែប៉ុណ្ណោះការបំពុលបរិយាកាស ការបំពុលទឹក ដូចជាការចោលសំរាម ការបង្ហូរកាកសំណល់របស់សណ្ឋាគារ ឬភោជនីយដ្ឋាន ភាពរញ៉េរញ៉ៃ ឬការរំខានដល់ការរស់នៅរបស់សត្វព្រៃ ការបង្កាត់ពូជ និងការចាប់ចំណីរបស់សត្វព្រៃ ធ្វើឲ្យបាត់បង់នូវសម្រស់ធម្មជាតិ ដែលមកពីការរៀបចំគ្រប់គ្រងមិនបានល្អត្រឹមត្រូវ។ ការរៀបចំប្រព័ន្ធផ្លូវសាធារណៈពុំបានល្អ ជាហេតុបណ្តាលឲ្យមានការកកស្ទះ ធ្វើឲ្យមានការសឹករិចរិលនៃធម្មជាតិ និងបាត់បង់ជម្រកសត្វព្រៃ ភាពខ្វះអនាម័យក្នុងការរស់នៅ និងការទទួលទានអាហាររបស់អ្នកស្រុក និងទេសចរ។

**ផលប៉ះពាល់វិជ្ជមានមកលើសង្គម:** ទេសចរណ៍អាចនាំមកនូវគុណសម្បត្តិជាច្រើនដល់សង្គម រឺសហគមន៍ដែលជាគោលដៅទេសចរណ៍។ យ៉ាងណាក៏ទេសចរណ៍អាចនាំមកនូវគុណវិបត្តិដល់សហគមន៍ជាច្រើនផងដែរ ប្រសិនបើសហគមន៍គិតតែខិតខំព្យាយាមអភិវឌ្ឍន៍វិស័យនេះខ្លាំងពេកពោល គឺជាការខិតខំព្យាយាមបំពេញតាមតម្រូវការរបស់ទេសចរឲ្យបាន 100% ដែលជាហេតុនាំអោយការកើតឡើងនូវឧក្រិដ្ឋកម្មផ្សេងៗដូចជា អំពើឆក់ប្លន់ លួច ការចាប់ជម្រិត ការឆបោក និងក្លែងបន្លំ។ ការបណ្តោយឲ្យមានការប្រើប្រាស់ និងការចរាចរណ៍ ថ្នាំញៀន ពេស្យាចារ ការជួញដូរផ្លូវភេទជាដើម។ ម្យ៉ាងវិញទៀត គឺជាការកើតមានជម្ងឺឆ្លងផ្សេងៗពិសេសជម្ងឺអេដស៍។

**ផលប៉ះពាល់អវិជ្ជមានមកលើវប្បធម៌:** ការអភិវឌ្ឍទេសចរណ៍ក៏បានផ្តល់ផលប្រយោជន៍ ជាច្រើនមកលើវប្បធម៌ដែរ ដោយបានធ្វើឲ្យទេសចរបានស្គាល់អំពីវប្បធម៌របស់ប្រទេសយើង។ ប៉ុន្តែ

យ៉ាងណាក៏ដោយ វាក៏មានផលប៉ះពាល់អវិជ្ជមានដែលកើតមានឡើងជាច្រើនដែរ ដោយសារតែនៅពេលដែលបរិមាណទេសចរមកទស្សនា មានចំនួនច្រើនលើសលប់នោះអាចធ្វើឲ្យប្រជាជនម្ចាស់ស្រុក សហគមន៍មានទង្វើ ឬអាកប្បកិរិយាមិនសមរម្យមកលើពួកគេ។ ហើយក៏អាចបណ្តាលឲ្យមានភាពសឹករិចរិលនូវរមណីយដ្ឋាន វប្បធម៌ ប្រវត្តិសាស្ត្រ និងវត្ថុបុរាណសំខាន់ៗនានាដែលកើតឡើងដោយមានអ្នកទស្សនាលើសកម្រិត និងការប៉ះពាល់ផ្សេងៗ។ ម្យ៉ាងវិញទៀត យុវវ័យងាយនឹងត្រាប់តាមនូវវប្បធម៌ ទំនៀមទម្លាប់ ប្រពៃណី អាកប្បកិរិយា និងលក្ខណៈផ្សេងៗទៀតនៃវប្បធម៌បរទេសដែលធ្វើឲ្យប្រាសចាកពីវប្បធម៌ជាតិរបស់ខ្លួន។ ការបោះបង់មុខរបររបស់ប្រជាជនពីការធ្វើស្រែចំការ តម្បាញ និងសិប្បកម្ម ហើយងាកមកធ្វើការបម្រើការងារក្នុងវិស័យទេសចរណ៍កាន់តែច្រើនទៅៗ ដោយសារតែការប្រែប្រួលសេដ្ឋកិច្ច និងប្រពៃណី។ ក្នុងនោះក៏បណ្តាលឲ្យមានការបំផ្លិចបំផ្លាញនូវវត្ថុបុរាណ និងសំណង់ដែលជាបេតិកភណ្ឌជាតិ ហើយបែរជាយកទីតាំងនោះសម្រាប់សាងសង់សំណង់ថ្មីៗ ដែលបម្រើឲ្យវិស័យទេសចរណ៍ ឬបម្រើក្នុងផ្នែកផ្សេងៗទៀត។

## ១.៥ បទពិសោធន៍បរទេសទាក់ទងនឹងការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព

ជាការពិតណាស់ក្នុងការអភិវឌ្ឍប្រទេសជាតិសព្វថ្ងៃ មានប្រទេសជាច្រើនបានយកវិស័យទេសចរណ៍ជាវិស័យដ៏សំខាន់មួយក្នុងការជំរុញសេដ្ឋកិច្ចឲ្យមានការរីកចម្រើន។ ហេតុនេះហើយទើបប្រទេសនីមួយៗបានខិតខំគិតគូក្នុងការបង្កើតជាយុទ្ធសាស្ត្រ ដើម្បីធ្វើការអភិវឌ្ឍរមណីយដ្ឋានរបស់ពួកគេឲ្យកាន់តែមានភាពទាក់ទាញ និងភាពល្អប្រសើរឡើងបន្ថែមទៀត។ ដើម្បីជាចំណេះដឹងបន្ថែមលើការសិក្សាស្រាវជ្រាវទៅលើប្រធានបទ "ការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព" ករណីសិក្សារមណីយដ្ឋានភ្នំកំពង់ត្រាច (ខេត្តកំពត) ក្នុងករណីសិក្សានេះ យើងខ្ញុំបានលើកយកនូវបទពិសោធន៍របស់ប្រទេសមួយចំនួន ដែលបានធ្វើការអភិវឌ្ឍលើរមណីយដ្ឋានរបស់ពួកគេដើម្បីធ្វើការពង្រឹងលើការរៀបចំផែនការអភិវឌ្ឍទេសចរណ៍ក្នុងរមណីយដ្ឋានមួយនេះ ឲ្យកាន់តែប្រសើរឡើង និងប្រកបដោយនិរន្តរភាព។

តាមការស្រាវជ្រាវលើ **ករណីសិក្សាប្រទេសឥណ្ឌា** តំបន់បេតិកភណ្ឌដ៏ល្បីល្បាញរបស់ប្រទេសឥណ្ឌាគឺរូបព្រះពុទ្ធដែលសាសនាចាអ៊ីន និងហិណ្ឌូធ្វើការគោរពក្នុងរូងភ្នំដោយកប់នៅក្រោមដីសម្រាប់ការថ្វាយបង្គំ និងការតាំងសមាធិ ហើយរូងភ្នំនេះជាប្រភេទរូងភ្នំមួយដែលយើងបានរកឃើញនៅតំបន់អាស៊ីអាគ្នេយ៍។ រូងភ្នំទាំងបីដែលល្បីល្បាញ និងជាបេតិកភណ្ឌពិភពលោករបស់ប្រទេសឥណ្ឌាគឺរូងភ្នំ Ajanta Ellora និង Elephanta មានការតុបតែង ឆ្លាក់ជារូបក្បាច់គុនហើយផ្ទាំងគំនូរផ្សេងៗទៀតក៏បានបង្ហាញពីទិដ្ឋភាពនៃសាសនា និងលោកិយដែលបានបង្កើត

ឡើងអស់ជាច្រើនសតវត្សដោយសិល្បករ និងអ្នកគោរពបូជានៅទីនោះ។ ផ្នែកខាងក្នុងនៃរូងភ្នំក៏មានបញ្ហាបន្តិចបន្តួចទៅលើសំណើម និងការខូចខាតទ្រង់ទ្រាយលើផ្ទៃជញ្ជាំងដោយសារតែមានអ្នកទស្សនាច្រើន ភាពសឹករិចរិលនៃស្រទាប់ថ្នាំលាប ការជ្រាបទឹកដោយសារការលូតលាស់នៃបន្លែ និងការឆ្លងរាលដាលនៃសត្វល្អិត និងសត្វប្រចៀវជាច្រើន។ តំបន់នៅជុំវិញនោះ មានបញ្ហាជាច្រើនដូចជាមិនសូវមានកន្លែងទស្សនាច្រើន ការទន្ទ្រានដោយការអភិវឌ្ឍពាណិជ្ជកម្ម ការគ្រប់គ្រងកាកសំណល់ ហើយភាពមិនត្រឹមត្រូវនៃការអនុវត្តផែនការនៃការគ្រប់គ្រងក៏មានការគំរាមកំហែងនៅក្នុងរូងភ្នំផងដែរ។ កាលពីដើមឆ្នាំ ១៩៩០ ASI ភាពជាដៃគូជាមួយសាជីវកម្មនៃការអភិវឌ្ឍទេសចរណ៍ Maharashtra និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) បានបង្កើតគំនិតផ្តួចផ្តើមមួយ ដើម្បីដោះស្រាយបញ្ហាទូទៅដែលមានការគំរាមកំហែងនៅតំបន់រូងភ្នំក្នុងប្រទេសឥណ្ឌា។ គំនិតផ្តួចផ្តើមនោះត្រូវបានស្វែងរក ដើម្បីកែលម្អនូវហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍រួមជាមួយនឹងសក្តានុពលនៃការអភិវឌ្ឍសេដ្ឋកិច្ច សម្រាប់តំបន់ធំៗតាមរយៈកិច្ចសហការ និងប្រាក់កម្ចីហិរញ្ញវត្ថុពីរដ្ឋាភិបាលជប៉ុនទៅកាន់ការអភិវឌ្ឍសាជីវកម្មក្នុងស្រុក។ ក្នុងតំបន់ជុំវិញរូងភ្នំមានការកែលម្អរួមទាំងរបង ផ្លូវដើរចូល និងប្រព័ន្ធឆ្លងកាត់ត្រូវបានប្រើសម្រាប់ទេសចរដើរលេងជុំវិញតំបន់។ នៅតំបន់នោះព័ទ្ធជុំវិញដោយព្រៃឈើ ទឹកស្អុយ និងប្រព័ន្ធបង្ហូរទឹកត្រូវបានគេធ្វើឲ្យប្រសើរឡើងជាងមុន។ ដើម្បីការពារនូវបរិស្ថានក្នុងរូងភ្នំ គេបានធ្វើការកំណត់នូវចំនួនទេសចរដែលអាចចូលទៅទស្សនារូងភ្នំក្នុងពេលតែមួយ។ ក្នុងឆ្នាំ ២០១៣ មជ្ឈមណ្ឌលសម្រាប់អ្នកទស្សនាត្រូវបានសម្ពោធដាក់ឲ្យប្រើក្នុងតំបន់ជាមួយនឹងសេវាកម្ម រួមជាមួយការបកប្រែ ការបន្ថែមនូវខ្នាតគំរូជាច្រើននូវផ្ទៃខាងក្នុងនៃរូងភ្នំដែលល្បីជាងគេ ដូច្នេះអ្នកទស្សនាអាចមើលឃើញនូវភាពអស្ចារ្យនៃភាពដើមរបស់រូងភ្នំនៅខាងក្រៅបាន[25]។

**ករណីសិក្សារបស់ប្រទេសហ្វីលីពីន** រូងភ្នំ Tabon គឺជាតំបន់ដ៏បុរាណវិទ្យាមួយនៅក្នុងខេត្ត Palawan។ រូងភ្នំនោះមានទីតាំងនៅចំណុច Lipuun និង Quezon ធ្វើដំណើរតាមទូកអស់រយៈពេល ២០-៣០នាទីពីកំពង់ផែនៃក្រុង Quezon។ សារៈសំខាន់នៃរូងភ្នំ Tabon នេះបានជំរុញឲ្យរដ្ឋាភិបាលហ្វីលីពីនបង្កើតនូវវិធានការផ្សេងគ្នា ដើម្បីអភិរក្សតំបន់នេះសម្រាប់កូនចៅជំនាន់ក្រោយ និងអភិវឌ្ឍន៍តំបន់នេះក្នុងគោលបំណងបង្កើតជាតំបន់ទេសចរណ៍។ ក្នុងឆ្នាំ ១៩៨៧ ផ្នែកនាយកដ្ឋាន

[25] John H. Stubbs, Robert G. Thomson, Architectural Conservation in Asia: National Experiences and Practice (India៖ India, ២០១៦), ៣៦៦, https://books.google.com/books?isbn=1317406192 (ចូលទស្សនាថ្ងៃទី១០ ឧសភា ២០១៧)

ទេសចរណ៍បានតែងតាំងក្រុមហ៊ុនទីប្រឹក្សាឯកជនមួយ ដើម្បីអភិវឌ្ឍន៍នូវផែនការដ៏លម្អិតនៃការអភិវឌ្ឍទេសចរណ៍-រូងភ្នំ Tabon។ គោលបំណងចម្បងនៃផែនការដ៏លម្អិតសម្រាប់អភិវឌ្ឍន៍ទេសចរណ៍-រូងភ្នំ Tabon គឺដើម្បីផ្តល់នូវក្របខ័ណ្ឌការងារសម្រាប់ការអភិវឌ្ឍបេតិកភណ្ឌវប្បធម៌ និងធម្មជាតិនៃតំបន់រូងភ្នំ Tabon ឲ្យក្លាយទៅជាគោលដៅទេសចរណ៍មួយដ៏សំខាន់ក្នុងប្រទេសហ្វីលីពីន។ ផែនការដ៏លម្អិតសម្រាប់ការអភិវឌ្ឍទេសចរណ៍-រូងភ្នំ Tabon បានកំណត់នូវបញ្ហាមួយចំនួនដូចជាភាពខ្សោយនៃយុទ្ធសាស្ត្រទីផ្សារ កង្វះខាតសម្ភារៈសម្រាប់ទេសចរ ដូចជាសណ្ឋាគារ ហោដ្ឋារចនាសម្ព័ន្ធ ឧបករណ៍ប្រើប្រាស់ និងមធ្យោបាយធ្វើដំណើរដើម្បីទៅដល់ចំណុច Lipuun។ បន្ទាប់ពីការដាក់ស្នើនូវផែនការអភិវឌ្ឍន៍ផ្សេងៗជាច្រើនសម្រាប់រូងភ្នំ Tabon នោះ ការកែលម្អមួយចំនួនត្រូវបានអនុវត្តនៅក្នុងការវិនិយោគ ដោយរដ្ឋាភិបាលជាតិនៃប្រទេសហ្វីលីពីនអស់ចំនួន ៨០,៥ លានប៉េសូ។ ការធ្វើអន្តរាគមន៍រួមមានការសាងសង់នូវផ្លូវថ្មើរជើងចូលទៅរូងភ្នំមានភាពល្អប្រសើរ និងមានការដាក់នូវផ្លាកសញ្ញានៅតាមមាត់រូងភ្នំ ព្រមទាំងតភ្ជាប់នូវការសាងសង់ផ្លូវទៅកន្លែងកម្សាន្តពិចនិច[26]។

ចំណែកឯ **ករណីសិក្សាខាងប្រទេសម៉ាឡេស៊ី** វិញបានបង្ហាញថារូងភ្នំនោះគឺជាកន្លែងទី សក្ការៈបូជាមួយដ៏មានប្រជាប្រិយបំផុតដែលមានឈ្មោះថា រូងភ្នំ Batu។ រូងភ្នំ Batu នេះត្រូវបានគេហៅថាជារូងភ្នំទី១០ ឬជាភ្នំរបស់ព្រះអម្ចាស់ Muruga ដែលមានទីកន្លែងសក្ការៈបូជាដ៏សំខាន់ចំនួន ៦ ក្នុងប្រទេសឥណ្ឌា និងចំនួន៤ ផ្សេងទៀតនៅក្នុងប្រទេសម៉ាឡេស៊ី ហើយកន្លែងសក្ការៈបូជាចំនួន៣ ទៀតនោះគឺប្រាសាទ Kallumalai ក្នុងខេត្ត Ipoh ប្រាសាទ Tanneermalai ក្នុងខេត្ត Penang និងប្រាសាទ Sannasimalai ក្នុងខេត្ត Malacca។ រូងភ្នំ Batu ដែលមានភាពងងឹតនេះគឺជាភាពទាក់ទាញមួយនៃកន្លែងសក្ការៈបូជាដែលសាសនាហិណ្ឌូធ្វើការគោរពក្នុងទីក្រុងគូឡាឡាំពួ ដែលបានផ្តល់ និងបង្កើតនូវឱកាសសម្រាប់ការស្រាវជ្រាវ ការអប់រំ និងជាកន្លែងកម្សាន្តផងដែរ។ វាបានផ្តល់នូវការកម្សាន្តឡើងភ្នំ និងស្រាវជ្រាវក្នុងរូងភ្នំដែលបានរៀបចំដោយគណៈកម្មាការសង្គមធម្មជាតិម៉ាឡេស៊ី។ រូងភ្នំ Batu ក៏ជាចំណុចកណ្តាលនៃការកម្សាន្តឡើងភ្នំដែលស្ថិតក្នុងការអភិវឌ្ឍក្នុងប្រទេសម៉ាឡេស៊ីកាលពី១០ ឆ្នាំមុន។ ការឡើងលើរូងភ្នំ Batu គឺមានផ្លូវដល់ទៅ១៦០ ហើយផ្លូវទាំងនោះត្រូវបានវាយប៉ាយនៅជុំវិញរូងនោះ ដែលកើតឡើងនូវថ្មកំបោរដុះឡើងដល់កម្ពស់ ១៥០ម។ ផ្លូវឡើងទៅរូងភ្នំ គឺមានភាពងាយស្រួលចូលទៅដល់ ដោយសារតែថ្មក្រហែងក្រហូងភាគច្រើននៅ

[26] Peter Gould, K. Anne Pyburn ,Collision or Collaboration: Archaeology Encounters Economic Development (Philippines៖ Philippines, ២០១៦), ៩៣ ៩៤ ,https://books.google.com/books?isbn=3319445154 (ចូលទស្សនាថ្ងៃទី ១៣ ឧសភា ឆ្នាំ២០១៧)

លើដីរាបទៅហើយ។ ផ្លូវឡើងទៅលើភ្នំចាប់ផ្តើមពីទិសឦសាន ដោយជណ្តើរដើរ និងច្រកចូលប្រាសាទបែរមុខទៅខាងត្បូង។ ប៉ុន្មានទសវត្សក្រោយនេះ តំបន់ដែលនៅជុំវិញរូងភ្នំបានធ្វើការផ្លាស់ប្តូរពីលំនៅដ្ឋានជាភូមិតូចមួយទៅជាសួនឧស្សាហកម្ម និងមានលំនៅដ្ឋានថ្មីជាច្រើន។ នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១១ ក្នុងអំឡុងពេលពិធីបុណ្យ Thaipusam រូងភ្នំនោះត្រូវបានប្រកាសថានឹងមានការសាងសង់រថយន្តខ្សែកាបសម្រាប់ពិធីបុណ្យប្រចាំឆ្នាំ ដែលមានតម្លៃប្រហែល ១០ លានរីងហ្គីត[27]។

[27] https://en.wikipedia.org/wiki/Batu_Caves ចូលទស្សនាថ្ងៃទី១៧ កក្កដា ឆ្នាំ២០១៧

# ជំពូកទី២

# ស្ថានភាពទូទៅនៃ

# ទេសចរណ៍ខេត្តកំពត

# ជំពូកទី ២
# ស្ថានភាពទូទៅនៃទេសចរណ៍ខេត្តកំពត

## ២.១ ស្ថានភាពទូទៅនៃខេត្តកំពត

### ២.១.១ ទីតាំងភូមិសាស្ត្រ

កំពតគឺជាខេត្តមួយក្នុងចំណោមខេត្ត-ក្រុងទាំង២៤ នៃព្រះរាជាណាចក្រកម្ពុជាដែលស្ថិតនៅតំបន់ឆ្នេរ ត្រូវបានរាជរដ្ឋាភិបាលកំពុងខិតខំប្រឹងប្រែងយ៉ាងសកម្មក្នុងការស្តារ កសាងហេដ្ឋារចនាសម្ព័ន្ធតំបន់ឆ្នេរ និងជំរុញកិច្ចសហប្រតិបត្តិច្រករបៀងសេដ្ឋកិច្ចខាងត្បូងឈៀងខាងលិច។ ការស្តារកសាងផ្លូវជាតិសំខាន់ៗមានដូចជា ផ្លូវជាតិលេខ៣១ (ផ្លូវបែកគូសមកកំពង់ត្រាច) លេខ ៣៣ (ពីកំពង់ត្រាចមកទីរួមខេត្តកំពត) កំណាត់ផ្លូវជាតិលេខ៣ (កំពត-វាលរេញ) ដងផ្លូវជាតិលេខ ៣ (ពីចោមចៅមកទីរួមខេត្តកាត់តាមស្រុកឈូក) ផ្លូវជាតិលេខ៤៨ (ពីទីរួមខេត្តកោះកុង មកភ្ជាប់ផ្លូវជាតិលេខ៤) ។ ខេត្តកំពតមានចំងាយ ១៤៨ គ.ម ពីរាជធានីភ្នំពេញប៉ែកនិរតី មានស្រុកចំនួន ៧ និងក្រុង១ ឃុំចំនួន៨៧ សង្កាត់៥ ភូមិ៤៧៧ មាន ផ្ទៃដី ៤.៨៧៣គ.ម² និងមានប្រជាជនចំនួន ៥៨៥.៨៥០នាក់ ដង់ស៊ីតេប្រជាជនមាន ១២០នាក់/គ.ម² (ស្ថិតិជំរឿនឆ្នាំ២០០៨)។ ដោយឡែកទីក្រុងកំពតមានប្រជាជនចំនួន ៣៦៣៦៧នាក់។ ក្រៅពីជនជាតិខ្មែរមានជនជាតិផ្សេងទៀតដូចជា ខ្មែរឥស្លាម ចិន វៀតណាម ប្រជាជនទាំងនោះប្រកបមុខរបរធ្វើស្រែចំការ នេសាទ សមុទ្រ ជាងសំណង់ ធ្វើជំនួញក្នុងស្រុក និងមួយចំនួនតូចនាំទំនិញចេញ-ចូលក្រៅប្រទេសទៀតផង[28]។

ខេត្តកំពតសំបូរធនធានធម្មជាតិដ៏មានតំម្លៃសម្រាប់បម្រើឲ្យវិស័យកសិកម្ម ឧស្សាហកម្ម និងទេសចរណ៍។ ក្រៅពីស្រូវនៅមានធនធានសំខាន់ៗដូចជា ស៊ីម៉ង់ត៍ ថ្មកំបោរ ជីហ្វូស្វាត អំបិល ផលសមុទ្រ អនុផលព្រៃឈើ ផ្លែឈើ រមណីយដ្ឋានទេសចរណ៍។ល។

### ២.១.២ វិស័យនានាក្នុងខេត្តកំពត

**វិស័យកសិកម្ម** គឺជាមុខព្រួញមួយយ៉ាងសំខាន់បំផុត សម្រាប់ជំរុញកំណើនសេដ្ឋកិច្ចជាតិ ហើយក៏ជាមូលដ្ឋានមួយសម្រាប់ជួយវិស័យផ្សេងៗទៀត ដើម្បីឲ្យមានការរីកចម្រើនដូចជា វិស័យឧស្សាហកម្ម សេវាកម្ម។ល។ ផ្តើមចេញពីនេះ មន្ទីរកសិកម្មក៏បានរួមចំណែកក្នុងការអភិវឌ្ឍវិស័យកសិកម្មក្នុងតំបន់សម្រាប់លើកស្ទួយជីវភាពគ្រួសារក្រីក្រនៅតាមជនបទ និងធានាឲ្យបាននូវសន្តិសុខ ស្បៀង និងអាហារូបត្ថម្ភ។

[28] http://kampot.cambodia.gov.kh ចូលទស្សនាថ្ងៃទី១៣ ឧសភា ឆ្នាំ២០១៧

**វិស័យទេសចរណ៍** បានធ្វើការអភិវឌ្ឍវិស័យទេសចរណ៍សម្រាប់ការប្រកួតប្រជែងលើទីផ្សារជាតិ និងអន្តរជាតិ លើកស្ទួយកម្រិតជីវភាពប្រជាពលរដ្ឋចូលរួមកាត់បន្ថយភាពក្រីក្រ ថែមទាំងធ្វើការអភិវឌ្ឍវិស័យទេសចរណ៍លើគ្រប់ផ្នែក ដើម្បីឲ្យមានប្រាក់ចំណូល និងបង្កើនឱកាសការងារជូនប្រជាពលរដ្ឋក្នុងខេត្ត។ ដោយការអភិវឌ្ឍមួយប្រកបដោយចិរភាពបរិស្ថាន និងផ្តល់ផលប្រយោជន៍ជូនប្រជាពលរដ្ឋទូទៅក្នុងខេត្ត ហើយប្រកាន់ខ្ជាប់នូវគោលការណ៍ សីលធម៌ វិជ្ជាជីវៈ ច្បាប់បរិស្ថានកម្រិតខ្ពស់។

**វិស័យអប់រំ** ប្រជាពលរដ្ឋក្នុងខេត្តកំពត បានទទួលនូវសេវាកម្មផ្នែកអប់រំប្រកបដោយគុណភាព គុណធម៌ និងជំនាញ ដើម្បីដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍន៍វិស័យអប់រំយុវជន និងកីឡាគឺត្រូវមានតម្រូវការសេដ្ឋកិច្ច សង្គម វប្បធម៌ក៏ដូចជាការរីកចម្រើនក្នុងប្រទេសកម្ពុជាផងដែរ[29]។

## ២.២ ស្ថានភាពទេសចរណ៍ខេត្តកំពត

នៅចំកណ្តាលរវាងខេត្តកោះកុង ខេត្តកែប និងខេត្តព្រះសីហនុជាមួយនឹងភាគខាងត្បូងឈាងខាងកើតនៃប្រទេសផងនោះ ខេត្តកំពតជាខេត្តដែលសម្បូរទៅដោយធនធានធម្មជាតិប្រវត្តិសាស្ត្រមានដូចជាភ្នំ រមណីយដ្ឋានបែបធម្មជាតិជាមួយនឹងទេសភាពស្រស់បំព្រងដែលជាចំណាប់អារម្មណ៍របស់ទេសចរ លើសពីនេះទៀតក៏មាននូវផលិតផលទេសចរណ៍សម្រាប់បំពេញតម្រូវការដល់ទេសចររួមមានហេដ្ឋារចនាសម្ព័ន្ធ សុវត្ថិភាព បរិស្ថាន និងសំណាក់ប្រជាពលរដ្ឋម្ចាស់ស្រុកជាដើម ហើយវាក៏ជាកន្លែងពេញនិយមសម្រាប់ទេសចរជាតិ និងអន្តរជាតិមកលេងកម្សាន្តផងដែរ។

### ២.២.១ សក្តានុពលទេសចរណ៍ខេត្តកំពត

### ក. រមណីយដ្ឋានទេសចរណ៍ចម្បង

ខេត្តកំពត ជាខេត្តដែលសម្បូរទៅដោយសក្តានុពល សម្រាប់ទាក់ទាញទេសចរឲ្យមកទស្សនាកាន់តែច្រើន។ ក្នុងខេត្តនេះមានរមណីយដ្ឋានជាច្រើនដូចជា៖

**ឋានសួគ៌បូកគោ** នៅលើភ្នំបូកគោ គឺប្រមូលផ្តុំទៅដោយសំណង់អគារជាច្រើនដូចជា ព្រះវិហារ សណ្ឋាគារ និងកាស៊ីណូ វត្តអារាម ទឹកជ្រោះ ដំណាក់ស្តេច រូបសំណាក់លោកយាយម៉ៅ លំនៅដ្ឋានរបស់ស្តេចកាលពីសម័យអាណានិគមបារាំង។ រមណីយដ្ឋាននេះត្រូវបានគេបោះបង់ចោលអស់រយៈពេលយូរណាស់មកហើយ គេក៏បានធ្វើការអភិវឌ្ឍសារជាថ្មីនូវហេដ្ឋារចនាសម្ព័ន្ធដ៏ទំនើប ដើម្បីធ្វើឲ្យទីកន្លែងនោះមានភាពងាយស្រួលក្នុងការធ្វើដំណើរ។ នៅទីតាំងរូបសំណាក

[29] http://kampot.cambodia.gov.kh/linedepartment/ ចូលទស្សនាថ្ងៃទី៣ កក្កដា ឆ្នាំ២០១៧

លោកយាយមៅ ភ្ញៀវអាចមើលឃើញទិដ្ឋភាពដ៏ស្រស់ស្អាតនៃផ្ទៃសមុទ្រពណ៌ខៀវ ព្រំដែនសមុទ្រ ច្រាំងសមុទ្រ និងទិដ្ឋភាពធំទូលាយនៃខេត្តកំពត។ ប្រសិនបើអ្នកឆ្លងកាត់ទីនោះនៅពេលល្ងាច អ្នកអាចរង់ចាំបន្តិចដើម្បីទស្សនាទិដ្ឋភាពដ៏អស្ចារ្យនៃព្រះអាទិត្យលិចចូលទៅក្នុងសមុទ្រ[30]។

**រមណីយដ្ឋានទឹកឈូ** មានទីតាំងស្ថិតនៅភូមិស្នំប្រាំពីរ ឃុំម៉ាក់ប្រាង្គ ស្រុកទឹកឈូ ខេត្តកំពត មានចម្ងាយ ៨គ.មពីប៉ែកខាងជើងទីក្រុងកំពត។ ទឹកឈូ គឺជាជ្រោះមួយដែលកើតឡើងពីការប្រសព្វគ្នាតាមបណ្តាជ្រោះជាច្រើននៃភ្នំទាំងឡាយរបស់ប្រជុំភ្នំដំរី ហើយភាពប្រសព្វគ្នានេះបានបញ្ចប់នៅតំបន់ទឹកឈូ រួចហូរតភ្ជាប់ជាមួយព្រែកកំពង់បាយ (ព្រែកកំពត) ចុះទៅសមុទ្រ។ ភាពក្រវិចក្រវៀននៃជ្រោះទឹកឈូតាមជម្រាលនៃបណ្តាភ្នំទាំងឡាយ ពោរពេញដោយធម្មជាតិល្អត្រកាលលាយឡំគ្នានោះ បានបង្កើតជាសោភ័ណភាពឆើតឆាយអស្ចារ្យចេញពីធម្មជាតិគ្មានកែច្នៃ។ ទឹកជ្រោះនេះបានពុះជ្រែកជ្រលងភ្នំបង្កើត បានជាខ្សែទឹកហូរលាន់លឺរំពងកាត់ព្រៃព្រឹក្សាខ្ញបប្រាំងវស្សាមិនដាច់រយៈ។ នៅតាមដងជ្រោះ និងក្នុងជ្រោះ តាំងពីចំណុចប្រសព្វដើមរហូតដល់ចំណុចព្រំប្រទល់ទឹកប្រៃ និងទឹកសាបពោរពេញដោយរុក្ខជាតិតូច ធំដុះប្រជ្រៀតគ្នាអមតាមមាត់ជ្រោះចោលម្លប់មួយផ្នែកគ្របដណ្តប់ជ្រោះដែលមានទឹកហូរថ្លាឈ្វេងឆ្លុះដល់បាតដី ព្រមទាំងហូរកាត់ផ្ទាំងសិលាតូច ធំដុះរកេតរកូតពេញផ្ទៃជ្រោះ ជាហេតុធ្វើឲ្យទឹកជ្រោះមានភាពត្រជាក់អលង្ក័យ[31]។

**ភ្នំឈ្លោក** ប្រាសាទភ្នំឈ្លោកមានទីតាំងស្ថិតនៅភូមិបុស្សត្របែក ឃុំត្រពាំងព្រីង ស្រុកទឹកឈូ ខេត្តកំពត និងមានចម្ងាយ ៨គ.មពីប៉ែកឦសានទីក្រុងកំពត។ ដើម្បីទៅដល់ភ្នំឈ្លោក គេអាចធ្វើដំណើរចូលតាមក្លោងទ្វារវត្តប្រឡាយខាងត្បូងផ្លូវចូលទៅរោងចក្រស៊ីម៉ង់ត៍ និងចូលតាមខ្លោងទ្វារមន្ទីរស្រុកទឹកឈូ ដោយធ្វើដំណើរឆ្លងកាត់ភ្នំក្បាលរមាសក៏បាន។ ប្រាសាទភ្នំឈ្លោក គឺជារមណីយដ្ឋានវប្បធម៌មួយដែលមានលក្ខណៈ ជាទីកន្លែងសម្រាប់ប្រជាជនខ្មែរធ្វើការគោរពអបិយជំនឿបែបព្រហ្មសាសនា ដើម្បីសុំសេចក្តីសុខ សេចក្តីចម្រើនទៅតាមជំនឿរបស់ពួកគេរៀងៗខ្លួន។ ភ្នំឈ្លោកជាភ្នំថ្មដែលពុំសូវមានរុក្ខជាតិធំៗទេ គឺច្រើនតែកូនឈើតូចៗដុះតាមក្រហែបថ្ម ដែលព័ទ្ធទៅដោយលតាវល្លិរយោងរយាងស៊ុបទ្រុបលើថ្មផង។ នៅលើកំពូលភ្នំនេះពុំសូវមានខ្នងរាបទេ ដូច្នេះការធ្វើដំណើរលើខ្នងភ្នំមានការលំបាក ម្យ៉ាងទៀតការឡើង និងចុះទៅមើលប្រាសាទក្នុងល្អាងពីមុនជួនកាលលំបាកតែបច្ចុប្បន្ន ព្រះសង្ឃ ប្រជាជន និងរដ្ឋអំណាចមូលដ្ឋានបានកសាងកាំ

[30] https://en.wikipedia.org/wiki/Bokor_Hill_Station ចូលទស្សនាថ្ងៃទី១៣ ឧសភា ឆ្នាំ២០១៧

[31] មន្ទីរទេសចរណ៍ខេត្តកំពត, *ប្រវត្តិសង្ខេបខេត្តកំពត* (កំពត៖ មន្ទីរទេសចរណ៍ខេត្តកំពត, ២០១៧), ១៦

ដំណើរដោយរៀបជាថ្មី បានបង្កលក្ខណៈងាយស្រួលមួយកម្រិតដល់ទេសចរដែលទៅកម្សាន្តនៅទីនោះ[32]។

**រមណីយដ្ឋានព្រែកអំពិល** មានទីតាំងស្ថិតនៅភូមិព្រែកអំពិល ឃុំកោះតូច ស្រុកទឹកឈូមានចម្ងាយ ១៨គ.មពីក្រុងកំពត ដោយធ្វើដំណើរតាមផ្លូវជាតិលេខ ៣ ឆ្ពោះទៅទិសខាងលិច។ ព្រែកអំពិល ជារមណីយដ្ឋានធម្មជាតិមួយ ដែលមានសម្រស់ស្រស់ត្រកាលគួរឲ្យចង់ទស្សនា និងកម្សាន្តព្រោះទីនោះជាតំបន់ជាប់ឆ្នេរសមុទ្រ ដែលមានបណ្តោយពីកើតទៅលិចប្រមាណជា ២០០០ ម៉ែត្រចាប់ពីព្រែកតាទែនរហូតដល់ព្រែកស្វាវ។ ដើមកាប៉ាងដុះជាជួរចោលម្លប់ត្រជាក់ត្រឈឹងត្រឈៃលាយឡំនឹងខ្យល់ជំនោររំភើយបក់មកពីសមុទ្រ បានបង្កើតឲ្យមានអាកាសធាតុត្រជាក់ ហើយជានិច្ចសម្រាប់ទេសចរដែលចង់សម្រាកកម្សាន្ត។ បច្ចុប្បន្នទោះបីរមណីយដ្ឋានព្រែកអំពិលពុំទាន់បានស្តារ និងអភិវឌ្ឍន៍បានល្អនូវបណ្តាហេដ្ឋារចនាសម្ព័ន្ធនានាយ៉ាងណាក៏ដោយនៅតែមានគ្រួសារ មិត្តភក្តិ ទេសចរជាច្រើនធ្វើដំណើរទៅកម្សាន្តនៅទីនោះជាហូរហែរ[33]។

**ព្រែកត្នោត** មានទីតាំងស្ថិតនៅក្នុងខេត្តកំពតមានចម្ងាយ ៣០គ.មពីក្រុងកំពត ធ្វើដំណើរតាមផ្លូវជាតិលេខ ៣ឬចម្ងាយ ៩០គ.មពីក្រុងព្រះសីហនុតាមផ្លូវជាតិលេខ ៤។ សហគមន៍អេកូទេសចរណ៍ព្រែកត្នោតបានបង្កើតឡើងក្នុងឆ្នាំ ២០០៧ ក្រោមការគាំទ្រពីអង្គការក្រៅរដ្ឋាភិបាលដែលគេហៅថា "ការជួយសង្គ្រោះជីវិតសត្វព្រៃក្នុងប្រទេសកម្ពុជា"។ ព្រែកត្នោតបានផ្តល់នូវទេសភាពដ៏ស្រស់ស្អាតសម្រាប់អ្នកទស្សនាជាច្រើន។ ទេសចរអាចដើរតាមក្តារក្រាលនៃព្រៃកោងកាងទៅដល់ទឹកធ្លាក់មួយកន្លែង ឬតាមមគ្គុទេសក៍ដែលនាំផ្លូវដើម្បីធ្វើការសិក្សាពីបរិស្ថាន ពិធីបុណ្យប្រពៃណី និងការចម្អិនម្ហូបអាហារដោយប្រជាជនក្នុងស្រុក។ ជារឿយៗ អំពិលអំពែកតែងតែលេចឡើងនៅពេលរាត្រី ដែលធ្វើឲ្យបរិយាកាសកាន់តែពិសេសថែមទៀត[34]។

**រមណីយដ្ឋានណាតាយ៉ា** មានរយៈចម្ងាយ ១៦គ.មពីទីរួមខេត្តកំពត និងមានទីតាំងនៅវាលទំនាបនៃជើងភ្នំបូកគោ។ រមណីយដ្ឋាននេះបានផ្តល់នូវសេវាកម្មដែលមានតែមួយគត់ ដើម្បីបំពេញសេចក្តីត្រូវការ និងចំណង់ចំណូលចិត្តរបស់អ្នកធ្វើដំណើរ ហើយក៏ជាកន្លែងដែលមានទេសភាពស្រស់ស្អាតសម្រាប់កាជួបជុំគ្រួសារ ការថតរូបអាពាហ៍ពិពាហ៍ក៏ដូចជាការជួបជុំមិត្តរួមក្រុម និងការធ្វើសាលសន្និសិទផងដែរ។ សម្រាប់ទេសចរដែលចង់ដើរលេង រមណីយដ្ឋាននេះក៏អាចរៀបចំ

[32] មន្ទីរទេសចរណ៍ខេត្តកំពត, *ប្រវត្តិសង្ខេបខេត្តកំពត* (កំពត៖ មន្ទីរទេសចរណ៍ខេត្តកំពត, ២០១៧), ១៧

[33] មន្ទីរទេសចរណ៍ខេត្តកំពត, *ប្រវត្តិសង្ខេបខេត្តកំពត* (កំពត៖ មន្ទីរទេសចរណ៍ខេត្តកំពត, ២០១៧), ១៥

[34] http://www.tourismcambodia.com/activities/community-based-tourism-cbt/prek-thnout-community-based-ecotourism-site.htm ចូលទស្សនាថ្ងៃទី១៤ ឧសភា ឆ្នាំ២០១៧

ដំណើរកម្សាន្តទៅលេងទឹកឈូ ភ្នំបូកគោ និងតំបន់ទាក់ទាញបែបប្រវត្តិសាស្ត្រដែលនៅក្បែរនេះ។ លក្ខណៈពិសេសដ៏ចម្បងនៃរមណីយដ្ឋាននេះ គឺជាទីតាំងដែលល្អឥតខ្ចោះរួមមានឆ្នេរខ្សាច់ សួនច្បារ ដើមកោងកាងអមជាមួយនឹងស្ពានឈើមានផ្លូវដើរនៅលើសមុទ្រ[35]។

## ខ. រមណីយដ្ឋានទេសចរណ៍បន្ទាប់បន្សំ

យើងសង្កេតឃើញថា ក្រៅពីតំបន់រមណីយដ្ឋានក្នុងខេត្តកំពតដែលទាក់ទាញបានភ្ញៀវច្រើនដូចជារមណីយដ្ឋានទឹកឈូ រមណីយដ្ឋានភ្នំបូកគោ ក៏នៅមានកន្លែងកម្សាន្តបន្ទាប់បន្សំខ្លះទៀតដែលទេសចរមិនសូវបានដឹងដូចជា៖

**រមណីយដ្ឋានប្រាសាទភ្នំខ្យង** មានទីតាំងស្ថិតនៅក្នុងឃុំកន្ដោរខាងជើង ស្រុកកំពង់ត្រាច ខេត្តកំពតមានចម្ងាយ ៤៣គ.មពីក្រុងកំពត។ ប្រាសាទនេះត្រូវបានសាងសង់ឡើងនៅក្នុងរូងភ្នំដែលមានកម្ពស់ប្រមាណ ៤០ម ។ ប្រាសាទនេះជាបូជនីយដ្ឋានទេសចរណ៍មួយដ៏មានមហិទ្ធិឬទ្ធិកេរ្តិ៍ឈ្មោះល្បីល្បាញយ៉ាងសំខាន់ក្នុងអតីតកាល នាសម័យខ្មែរយើងកាន់ព្រហ្មញ្ញសាសនា។ ក្នុងប្រាសាទនេះ មានលិង្គថ្មធម្មជាតិមួយដុះចេញពីបាតភ្នំចំកណ្តាល។ ការបូជាភ្នំបានកើតឡើងមុនសម័យប្រវត្តិសាស្ត្រមកម្ល៉េះ ហើយប្រាសាទនេះមានប្រាង្គតែមួយគត់ត្រូវបានសាងសង់លើរានមួយផ្តិបជាប់នឹងជញ្ជាំងភ្នំដោយមានពីរផ្នែក។ ផ្នែកខាងលើមានដំបូលមួយដោយមានជម្រាល ៤ មានកំពូលជំទើតយ៉ាងអស្ចារ្យគួរឲ្យចង់គយគន់[36]។

**កសិដ្ឋានចំការម្រេច** ម្រេចគឺជាដំណាំមួយប្រភេទដែលខេត្តកំពតធ្លាប់មានឈ្មោះល្បីល្បាញតាំងពីដើមរៀងមក ហើយទីតាំងដាំម្រេចស្ថិតនៅក្នុងស្រុកកំពង់ត្រាច មានចម្ងាយ ៣៦គ.ម ខាងកើតក្រុងកំពត។ តាមការអះអាងពីក្រុមអ្នកស្រាវជ្រាវបានបង្ហាញថា ការទទួលទានដំណេកក្នុងចំការម្រេចបានផ្តល់ផលប្រយោជន៍ដល់អ្នកជម្ងឺ ពិសេសជម្ងឺបេះដូង[37]។

**វត្តភ្នំស** ជាទីអារាមមួយកសាងឡើងក្នុងរជ្ជកាលព្រះបាទមុនីវង្សដែលមានចំណាស់ប្រហែល ១០០ឆ្នាំ។ ក្នុងទីអារាមមានសំណង់ជាច្រើនដូចជាព្រះវិហារ កុដិ សាលាធម្មទាន និងរូបសំណាកព្រះគោព្រះកែវ ដែលកសាងឡើងសម្រាប់រំលឹកពីប្រវត្តិសាវតាខ្មែរពីអតីតកាល ហើយនៅក្បែរព្រះគោព្រះកែវមានប្រាសាទមួយទៀតឈ្មោះថាប្រាសាទត្រៃល័ក្ខ ដែលធ្វើជារូបសំពៅប្រកប

[35] http://www.natayaresort.com/resort-overview ចូលទស្សនាថ្ងៃទី១៨ ឧសភា ឆ្នាំ២០១៧

[36] ក្រសួងទេសចរណ៍កម្ពុជា, *ទស្សនាខេត្តទាំង ៤នៃដែនសមុទ្រ* (កំពត៖ ២០១៦), ៣៥

[37] ក្រសួងទេសចរណ៍កម្ពុជា, *ទស្សនាខេត្តទាំង ៤នៃដែនសមុទ្រ* (កំពត៖ ២០១៦), ៣៤

ទៅដោយក្បូរក្បាច់រចនាព្រមទាំងមានរូបព្រះពុទ្ធបដិមាករ រូបសំណាកតាឥសី និងព្រះនាងគង់ស៊ីអ៊ឹម[38]។

### ២.២.២ ទីផ្សារទេសចរណ៍ និងមូលដ្ឋានស្នាក់នៅទេសចរណ៍

យើងបានដឹងហើយថា ខេត្តកំពតជាខេត្តមួយដែលស្ថិតនៅក្នុងសក្តានុពលទេសចរណ៍នៃតំបន់ឆ្នេរ ហើយខេត្តកំពតក៏បានបង្ហាញនូវសក្តានុពលដ៏អស្ចារ្យដែលទទួលបានការវិនិយោគរាប់ពាន់លានដុល្លារពីបណ្តាក្រុមហ៊ុនជាតិ និងអន្តរជាតិ។ លោកចាន់ ចេស្តា អភិបាលរងខេត្តកំពតបាននិយាយថាគាត់បានបង្កើតគម្រោងការវិនិយោគដ៏ធំមួយ ដែលកំពុងស្ថិតក្នុងដំណាក់កាលសិក្សារង់ចាំការអនុម័តពីក្រុមប្រឹក្សាការអភិវឌ្ឍប្រទេសកម្ពុជា។ គាត់បានបន្ត គម្រោងនោះគឺមានទីតាំងស្ថិតនៅក្នុងស្រុកទឹកឈូតាមបណ្តោយសមុទ្រពីខេត្តកំពតទៅខេត្តកែប ដែលមានចម្ងាយ ១០ គ.មពីក្រុងកំពត។ គំនិតនៃការអភិវឌ្ឍនេះ គឺមិនមែនចាក់ដីបន្ថែមទៅក្នុងសមុទ្រទេ ប៉ុន្តែត្រូវបានបូមខ្សាច់ចេញពីសមុទ្រ ដើម្បីបង្កើតជាកោះសិប្បនិម្មិតមួយ។ ប្រសិនបើគម្រោងនោះធ្វើទៅតាមផែនការដែលបានរៀបចំ វានឹងទាក់ទាញទេសចរកាន់តែច្រើនទៅកម្សាន្តនៅខេត្តកំពត ហើយគាត់កំពុងអំពាវនាវដល់ក្រុមហ៊ុនឯកជនទាំងអស់ឲ្យធ្វើការវិនិយោគលើសណ្ឋាគារ និងផ្ទះសំណាក់ក្នុងខេត្តកំពត។ អាជ្ញាធរខេត្តសហការជាមួយក្រសួងទេសចរណ៍ ក៏មានផែនការក្នុងការអភិវឌ្ឍនៅលើផ្ទៃដី ២០០ហិកតា ដើម្បីសាងសង់តំបន់ទេសចរណ៍ថ្មីមានឈ្មោះថា កំពតថ្មី។ គម្រោងនេះបានឆ្លងកាត់ដោយគណៈកម្មាការឆ្នេរសមុទ្រ ក៏ដូចជាកំពុងធ្វើការសិក្សាទៅលើគម្រោងនេះផងដែរ ថាតើវានឹងមានភាពល្អប្រសើរប៉ុណ្ណា[39]។

នេះជាមធ្យោបាយដែលមិនគួរឲ្យជឿមួយ ដើម្បីទទួលបានការយល់ដឹងពីរបៀបដែលប្រជាពលរដ្ឋកម្ពុជារស់នៅតាមតំបន់ជនបទ។ ជាការពិតណាស់ នៅតាមជីវិតរស់នៅតាមជនបទក្នុងប្រទេសកម្ពុជាមានភាពលំបាក ដូច្នេះកុំរំពឹងថានឹងមានសណ្ឋាគារទំនើបនៅទីនោះ ប៉ុន្តែនេះជាភាពទាក់ទាញនៃបទពិសោធន៍ ក៏ដូចជាសង្កេតមើលនូវជីវភាពរស់នៅប្រចាំថ្ងៃក្នុងភូមិ។ ផ្ទះស្នាក់ទាំងអស់មានប្រព័ន្ធអគ្គិសនី ប៉ុន្តែមិនមានប្រព័ន្ធ Wifi ទេដោយអាចប្រើប្រព័ន្ធអ៊ីនធឺណេតតាមរយៈទូរស័ព្ទចល័ត។

**ភូមិព្រៃ:** មានផ្ទះស្នាក់ចំនួន២ បែបទំនើបមានកន្លែងគេងធំទូលាយ និងមានពូកចំនួន ៥ បំពាក់ដោយប្រព័ន្ធអគ្គិសនី។

---

[38] ក្រសួងទេសចរណ៍កម្ពុជា, *ទស្សនាខេត្តទាំង ៩នៃដែនសមុទ្រ* (កំពត៖ ២០១៦), ៣០

[39] https://www.realestate.com.kh/news/kampot/ ចូលទស្សនាថ្ងៃទី២០ កក្កដា ឆ្នាំ២០១៧

**ភូមិកោះចំការ** មានផ្ទះស្នាក់ចំនួន៣ បែបទំនើប និងមានផាសុកភាពដែលបំពាក់ដោយប្រព័ន្ធអគ្គិសនីមានគ្រែ២។

**ភូមិកោះត្នោត** មានផ្ទះស្នាក់ចំនួន៣ ដែលជាផ្ទះសម្រាប់អ្នកធ្វើដំណើរផ្សងព្រេងបំពាក់ដោយប្រព័ន្ធអគ្គិសនីមានគ្រែ១[40]។

## ២.៣ ស្ថានភាពនៃរមណីយដ្ឋានភ្នំកំពង់ត្រាច

### ២.៣.១ ស្ថានភាពទូទៅ និងប្រវត្តិ

រមណីយដ្ឋានភ្នំកំពង់ត្រាច ជាប្រភេទរមណីយដ្ឋានបែបធម្មជាតិ វប្បធម៌ ប្រវត្តិសាស្ត្រ និងជាកន្លែងទីសក្ការៈមួយរបស់ប្រជាជនខ្មែរ ចិន និងវៀតណាម ដែលមានទីតាំងស្ថិតនៅក្នុងភូមិដំណាក់កន្ទួត ឃុំដំណាក់កន្ទួតខាងត្បូង ស្រុកកំពង់ត្រាច ខេត្តកំពត មានចម្ងាយប្រហែល ១៣៤ គីឡូម៉ែតពីរាជធានីភ្នំពេញដោយធ្វើដំណើរតាមផ្លូវជាតិលេខ ៣ និង៣១ ប្រើរយៈពេលអស់ប្រមាណជា ៤ម៉ោង ហើយប្រសិនបើធ្វើដំណើរពីទីរួមខេត្តកំពតមកកាន់រមណីយដ្ឋានភ្នំកំពង់ត្រាចវិញនោះ មានចម្ងាយ ៣៨គ.មធ្វើដំណើរអស់រយៈពេល ១ម៉ោង។ ម្យ៉ាងវិញទៀត ភ្នំកំពង់ត្រាចមានលក្ខណៈជាភ្នំថ្មសុទ្ធសាធ និងមានដើមឈើតូចៗដុះអែបតាមកន្លៀតថ្ម ព្រមទាំងរុក្ខជាតិវល្លិ៍ដុះរយោងរយាងគ្របដណ្តប់លើថ្មទៀតផង។ ភ្នំនេះពុំសូវមានជើងជម្រាលដូចភ្នំដទៃទេ គឺមានស្ថានភាពត្រង់ឡើងលើប្រៀបដូចជាជញ្ជាំងផ្ទះ និងមានថ្មដុះ រឆេញរឆុញស្រួចៗ ដែលជាហេតុធ្វើឲ្យមានការលំបាកយ៉ាងខ្លាំងក្នុងការធ្វើដំណើរឡើងទៅលើកំពូលភ្នំព្រោះថានៅលើភ្នំនេះ ពុំសូវមានដីរាបទេ[41]។

រមណីយដ្ឋានភ្នំកំពង់ត្រាច ជាសម្បត្តិធម្មជាតិមួយដ៏វិសេសវិសាលដែលមានលក្ខណៈបែបធម្មជាតិ វប្បធម៌ និងប្រវត្តិសាស្ត្រ។ បើតាមការសន្និដ្ឋានរបស់អ្នកប្រវត្តិវិទ្យាបានឲ្យដឹងថា ដើមឡើយភ្នំនេះគឺជាកោះតូចមួយដែលព័ទ្ធទៅដោយទឹកសមុទ្រហើយដោយសារតែរលកសមុទ្រ បានបក់បោកខ្លាំងជារៀងរាល់ថ្ងៃទើបធ្វើឲ្យកោះនោះសឹករិចរិល ដោយសារកម្លាំងទឹកបុកក៏បណ្តាលឲ្យកើតមានជារូង និងល្អាងតូចធំជាច្រើនកើតឡើងដោយសារសំណឹកទឹកហូរច្រោះ ដែលនៅទិសខាងកើតមានល្អាងមួយត្រូវបានគេហៅថាល្អាងព្រះច័ន្ទ ដោយមានអ្នកនេសាទមួយក្រុមជាជនជាតិឥស្លាមបានធ្វើការស្នាក់អាស្រ័យនៅលើភ្នំ ក៏បានកសាងវិហារឥស្លាមនៅលើកំពូលភ្នំ។ ចាប់ពីពេលនោះមក ប្រជាជនដែលរស់នៅក្នុងស្រុកកំពង់ត្រាចបានគោរពព្រហ្មញ្ញសាសនានៅក្នុងវិហារ

40 http://mekongcrane.com/accommodation/ ចូលទស្សនាថ្ងៃទី១៥ កក្កដា ឆ្នាំ២០១៧

41 មន្ទីរទេសចរណ៍ខេត្តកំពត, *ប្រវត្តិ និងលក្ខណៈភូមិសាស្ត្ររមណីយដ្ឋានទេសចរណ៍ភ្នំកំពង់ត្រាច* (កំពត៖ មន្ទីរទេសចរណ៍ខេត្តកំពត, ២០១៧), ១

ឥស្លាម ដោយមានជំនឿលើការបួងសួងបន់ស្រន់នៅតាមល្អាងនីមួយៗ។ ដោយពិនិត្យមើលឃើញថា ស្ថានភាពនៅទីនោះមានការលំបាកដល់ប្រជាជនដែលរស់នៅជិតៗនោះ គួបផ្សំជាមួយនឹងទំនៀមទម្លាប់របស់ប្រជាជនខ្មែរតែងតែមានជំនឿលើបារមីផ្សេងៗនៅតាមព្រៃភ្នំ គេក៏បានសាងសង់ទីវត្តអារាមមួយសម្រាប់ធ្វើជាកន្លែងប្រារព្ធពិធីគោរពបូជាដល់វត្ថុសក្តិសិទ្ធិនៅទីនោះ។ ក្រោយពីបានឃើញប្រជាជនខ្មែរសាងសង់ទីវត្តអារាមរួច បន្ទាប់មកប្រជាជនចិន វៀតណាម គេក៏បានសាងសង់វត្តសម្រាប់សាសនារបស់ពួកគេមួយផងដែរ។ ជាតំណរក្រោយៗមកទៀត ដោយមានការនិយាយប្រាប់តៗគ្នាពីទិដ្ឋភាពដ៏អស្ចារ្យនៃរូងភ្នំកំពង់ត្រាច បានធ្វើឲ្យពុទ្ធបរិស័ទជិតឆ្ងាយមានការចាប់អារម្មណ៍ និងមកធ្វើបុណ្យទាន បន់ស្រន់ បួងសួងសុំសេចក្តីសុខទៅតាមជំនឿរបស់ខ្លួនជាបន្តបន្ទាប់រហូតមក។

ដោយផ្អែកលើបរិមាណភ្ញៀវទេសចរមានការកើនឡើងជាលំដាប់ ទើបព្រះរាជបុត្រាមួយអង្គព្រះនាម ព្រះបាទនរោត្តម ផិត សារិ បានផ្តួចផ្តើមរៀបចំប្រែក្លាយភ្នំកំពង់ត្រាចឲ្យទៅជារមណីយដ្ឋានទេសចរណ៍ចាប់ពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ១៩៥៩មកម៉្លេះ។ ទន្ទឹមនឹងនេះដែរនាទសវត្សទី៦០ វិស័យទេសចរណ៍នៅកម្ពុជាបានចាប់ផ្តើម ហើយទេសចរអន្តរជាតិចាប់ផ្តើមធ្វើដំណើរមកកម្សាន្តជាបណ្តើរៗ។ ដោយភាពល្បីល្បាញខាងសម្រស់ធម្មជាតិ និងភាពអស្ចារ្យនៃល្អាងភ្នំបានធ្វើឲ្យផលិតករនៃភាពយន្តធំៗមួយចំនួននៅកម្ពុជា បានជ្រើសរើសទីតាំងសំខាន់ៗមួយចំនួននៃភ្នំកំពង់ត្រាចមានជាអាទិ៍ វាលស្រែ១០០ បណ្តាគុហារសំខាន់ៗធ្វើជាកន្លែងថតភាពយន្ត ជាក់ស្តែងក្នុងឆ្នាំ ១៩៦៤ លោក លី ប៊ុនយីម ចាងហ្វាងផលិតកម្មផ្ទះពេជ្រភាពយន្តបានមកថតរឿង ពុទ្ធសែន នាងកង្រី ផ្កាវាំទឹកវាំ និងរឿងសព្វសិទ្ធ ដែលជារឿងមានភាពល្បីល្បាញ និងទទួលបានចំណាត់ថ្នាក់ខ្ពស់ក្នុងការប្រឡងប្រណាំងជាមួយភាពយន្តបរទេសទៀតផង។

ចាប់តាំងពីឆ្នាំ ១៩៧០ នៅពេលដែលប្រទេសកម្ពុជាធ្លាក់ចូលក្នុងភ្លើងសង្គ្រាមបានធ្វើឲ្យគ្រប់សកម្មភាពដូចជាទេសចរណ៍ជាដើមត្រូវបានផ្អាកទាំងស្រុង។ ទ្រង់ទ្រាយខ្លះនៃភ្នំ និងវត្តអារាមទាំងប្រជាជនខ្មែរ ចិន និងវៀតណាមត្រូវបានខូចខាត។ ក្រោយពីឆ្នាំ ១៩៧៩ រហូតដល់បច្ចុប្បន្ន រមណីយដ្ឋាននេះត្រូវបានរៀបចំកែលម្អ និងថែរក្សាទុកជាកន្លែងកម្សាន្តរបស់ទេសចរជាតិ អន្តរជាតិ និងកន្លែងសម្រាប់ពុទ្ធបរិស័ទធ្វើការគោរពបូជាទៅតាមទំនៀមទម្លាប់របស់ពួកគេតរៀងទៅ។ ក្នុងឆ្នាំ ២០០៥ រមណីយដ្ឋានភ្នំកំពង់ត្រាចជាកន្លែងវាយថ្មអនាធិបតេយ្យ ដែលប្រជាជនយកទៅលក់ ដើម្បីរកប្រាក់ចំណូលសម្រាប់ផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ លុះដល់ឆ្នាំ២០១២ ក៏មានការបង្កើតគណ:កម្មាករព្រៃឈើ ដើម្បីបញ្ឈប់ការវាយថ្ម ហើយពន្យល់ណែនាំឲ្យប្រជាជនក្នុងតំបន់នោះ

ប្រកបរបររកស៊ីតាមលទ្ធភាពដែលខ្លួនអាចធ្វើបាន ដើម្បីជាតម្រូវការសម្រាប់ទេសចរដែលចូលទៅទស្សនាក្នុងរមណីយដ្ឋានភ្នំកំពង់ត្រាច[42]។

ភ្នំកំពង់ត្រាច គឺជាភ្នំមួយដែលមានល្អាង ឬគុហារជាច្រើនដែលបង្កប់ទៅដោយអាថ៌កំបាំង និងជាទីកន្លែងសក្ការៈគោរពបូជា បន់ស្រន់ ទៅតាមជំនឿបែបសាសនារបស់ប្រជាជន ដែលជាសាសនិកទូទៅ (លោកព្រឹទ្ធាចារ្យ អ៊ុក សុខ អាយុ ៧៥ឆ្នាំ និងលោកព្រឹទ្ធាចារ្យ នាក់ ង៉ែត អាយុ ៧៧ឆ្នាំ ជាប្រជាជនរស់នៅក្នុងភូមិកំពង់ត្រាចទី១ ឃុំដំណាក់កន្ទួតខាងត្បូង) បានមានប្រសាសន៍ថា ភ្នំកំពង់ត្រាចមានល្អាងតូចធំជាច្រើន ហើយសុទ្ធតែមានប្រវត្តិរឿងរ៉ាវខុសៗគ្នា តែពេលនេះយើងសូមលើកយកឈ្មោះល្អាងសំខាន់ៗមួយចំនួនយកមកធ្វើការបរិយាយមានដូចខាងក្រោម៖

**ល្អាងលោកតាធុដុង្គ** ស្ថិតនៅចុងខាងត្បូងភ្នំកំពង់ត្រាចក្បែរផ្លូវចូលវត្តគិរីសិលា។ កាលពីសម័យសង្គមរាស្ត្រនិយម មានលោកតាជាព្រះសង្ឃពីរអង្គនិមន្តមកពីទីឆ្ងាយចូលមកសមាធិនៅក្នុងល្អាងនេះអស់រយៈកាលជាច្រើនឆ្នាំ។ លុះដល់ឆ្នាំ ១៩៧០ ប្រទេសយើងមានសង្គ្រាម ភ្នំកំពង់ត្រាចបានក្លាយជាទីតាំងសមរភូមិប្រយុទ្ធរវាងកងទ័ពយៀកកុង និងទ័ពអាមេរិកកាំងធ្វើឲ្យទីកន្លែងនេះរងនូវការបាញ់ផ្លោង និងទម្លាក់គ្រាប់បែកយ៉ាងខ្លាំងធ្វើឲ្យព្រះអង្គមិនអាចទ្រាំទ្រតទៅទៀតបានក៏និមន្តភៀសខ្លួនចាញបាត់តាំងពីពេលនោះរហូតទៅ ទើបល្អាងនោះមានឈ្មោះថា ល្អាងធុដុង្គរហូតមកដល់សព្វថ្ងៃនេះ[43]។

**ល្អាងលោកតាសធំ** ស្ថិតនៅក្នុងបរិវេណវត្តគិរីសិលាប៉ែកខាងកើតឡើងតាមជណ្ដើរទៅលើកម្ពស់ ១៥ម៉ែត្រ។ នៅក្នុងល្អាងនេះមានទីអសនៈស័ក្តសិទ្ធិ និងតឹងរឹងត្រឹមត្រូវបំផុត ហើយអសនៈនោះមានរូបបដិមាព្រះពុទ្ធតូចៗជាច្រើនអង្គ អ្នកដែលបានបែរបន់សុំលាភសក្ការៈបានសម្រេចដូចប្រាថ្នា ហើយយកមកថ្វាយទុកជាទីគោរពបូជាគ្រប់ៗគ្នា។

**ល្អាងព្រះចូលនិព្វាន** ស្ថិតនៅក្នុងបរិវេណដ៏ធំទូលាយមួយនៅប៉ែកខាងកើត។ ទីបរិវេណដ៏ធំទូលាយនេះមានឈ្មោះថា ល្អាងក្រពះនាគ នៅក្នុងល្អាងព្រះចូលនិព្វានមានរូបសំណាក់ព្រះពុទ្ធចូលនិព្វានប្រវែង ៥ម៉ែត្រ ព្រះកេស្សផ្តេកទៅទិសខាងលិច។ ព្រះបដិមានេះបានកសាងឡើងក្នុងឆ្នាំ ១៩៥៩ ដោយព្រះអង្គ នរោត្តម សិរិ ទុកជាទីគោរពបូជាដល់ប្រជាពលរដ្ឋគ្រប់ៗគ្នា។

---

[42] មន្ទីរទេសចរណ៍ខេត្តកំពត, *ប្រវត្តិ និងលក្ខណៈភូមិសាស្ត្ររមណីយដ្ឋានទេសចរណ៍ភ្នំកំពង់ត្រាច* (កំពត៖ មន្ទីរទេសចរណ៍ខេត្តកំពត, ២០១៧), ១

[43] មន្ទីរទេសចរណ៍ខេត្តកំពត, *ប្រវត្តិ និងលក្ខណៈភូមិសាស្ត្ររមណីយដ្ឋានទេសចរណ៍ភ្នំកំពង់ត្រាច* (កំពត៖ មន្ទីរទេសចរណ៍ខេត្តកំពត, ២០១៧), ២

**ល្អាងក្រពះនាគ** ជាឈ្មោះតាមព្រហ្មញ្ញសាសនៅគ្រប់ទិសទាំងអស់នៃល្អាងក្រពះនាគមានល្អាងជាច្រើន។ នៅតាមផ្លូវចូលទៅក្នុងល្អាងនេះ យើងត្រូវឆ្លងកាត់តាមក្លោងទ្វារដែលមានក្បូរក្បាច់រចនាដ៏ស្អាត និងមានព្រំរូបនាគនៅខាងលើដំបូល ព្រមទាំងមានក្រាលការ៉ូពណ៌ក្រហមនៅខាងក្រោម។ ការ៉ូពណ៌ក្រហមនេះហើយ ជានិមិត្តរូបនៃអណ្តាតនាគ (តាមការដឹងពីម្ចាស់កសាង)។

**ល្អាងកុមារពេជ្រ កុមារទេព** ស្ថិតនៅប៉ែតខាងត្បូងនៃល្អាងក្រពះនាគឡើងតាមជណ្តើរកម្ពស់ ៥ម៉ែត្រ នៅក្នុងល្អាងនេះមានទីអសនៈបារមីកុមារពេជ្រ កុមារទេពជាកន្លែងគោរពបូជាតាមព្រហ្មញ្ញសាសនាតាំងពីយូរលង់ណាស់មកហើយ។ (ក្នុងឧបសម្ព័ន្ធទី២ រូបទី១១)

**ល្អាងបិតាព្រហ្ម** ស្ថិតនៅប៉ែកនិរតីនៃល្អាងក្រពះនាគ។ បិតាព្រហ្មមានឈ្មោះព្រះព្រហ្ម ជាអ្នកគ្រប់គ្រងផែនដី និងមនុស្សលោកយើងមុនគេ ទើបមកដល់សព្វថ្ងៃនេះយើងទៅគោរពតាមព្រហ្មសាសនានេះឯង។

**ល្អាងឥសីអគ្គីនេត្រ** ស្ថិតនៅប៉ែកខាងលិចនៃល្អាងក្រពះនាគ។ កាលពីមុនមានរូបសំណាក់លោកតាឥសីអគ្គីនេត្រនៅកន្លែងនេះ តែដោយសាររូបនេះបានបាក់បែកបាត់បង់ក្នុងសម័យសង្គ្រាមអស់ទៅ ទើបមានសប្បុរសដែលមានជំនឿលើបារមីតាលោកតាឥសី បានមកសាងរូបសំណាក់លោកតាឡើងវិញនៅក្នុងបរិវេណនេះទុកជាកន្លែងគោរពបូជាគ្រប់គ្នា[44]។

**ល្អាងម្រេញគង្វាល** ល្អាងនេះស្ថិតនៅប៉ែកពាយ័ព្យនៃល្អាងក្រពះនាគ នៅក្នុងល្អាងមានរូបសំណាក់ម្រេញគង្វាល ២រូប ស្រី ១ ប្រុស ១ ព្រមទាំងមានរូបព្រះពុទ្ធគង់លើផ្ទេននាគទៀតផង។ នៅខាងកើតចំពីមុខព្រះពុទ្ធរូបនេះ មានអណ្តូងទឹកមន្តមួយដែលមានទឹកមិនដែលរីងនៅគ្រប់រដូវទឹកនេះភ្ញៀវតែងតែយកទុកពិសារ និងលុបមុខសុំសេចក្តីសុខទៅតាមជំនឿគ្រប់ៗគ្នា។

**ល្អាងស្គរហនុមាន** ស្ថិតនៅប៉ែកឦសាននៃល្អាងក្រពះនាគ។ ទីតាំងនេះជាទីសក្ការៈគោរពបូជាដល់បារមីហនុមាន មានថ្មដុះសំយ៉ាកចុះក្រោមធ្វើឲ្យយើងវាយឮស្គរទៀតផង ថ្មនេះមានឈ្មោះថាស្គរហនុមានដល់សព្វថ្ងៃ ហើយទីកន្លែងនេះកំពុងមានការចាប់អារម្មណ៍ពីទេសចរយ៉ាងខ្លាំង។

**ល្អាងដំរីសពេជ្រ** ល្អាងនេះស្ថិតនៅខាងលិចស្គរហនុមាន។ នៅទីនោះមានថ្មដុះជារូបដំរីពណ៌សធំមួយ មានពន្លឺផ្លេកដូចពេជ្រ រូបដំរីសនេះជានិមិត្តរូបក្នុងបារមីស្តេចទេវតា។ ទីកន្លែងនេះជាកន្លែងដែលភ្ញៀវបានគោរពបូជា សុំសេចក្តីសុខ និងលាភសក្ការៈគ្រប់គ្នា។

---

[44] មន្ទីរទេសចរណ៍ខេត្តកំពត, *ប្រវត្តិ និងលក្ខណៈភូមិសាស្ត្ររមណីយដ្ឋានទេសចរណ៍ភ្នំកំពង់ត្រាច* (កំពត៖ មន្ទីរទេសចរណ៍ខេត្តកំពត, ២០១៧), ៣

**ល្អាងព្រះអាទិត្យ** ល្អាងនេះស្ថិតនៅចុងភ្នំខាងជើងចម្ងាយពីវត្តគិរីសិលា ១០០០ម៉ែត្រ ល្អាងនេះត្រូវឡើងដលើកម្ពស់ ៤០ម៉ែត្រទើបដល់ល្អាងព្រះអាទិត្យជាឈ្មោះរាជបុត្ររបស់ព្រះឥន្ទ្រីសុរិយា ជាស្ដេចគ្រប់គ្រងចក្រវាឡយើងនេះ។ នៅខាងក្រោមល្អាងព្រះអាទិត្យមានល្អាងទឹកមួយឈ្មោះថា ស្រះព្រះអាទិត្យ។ នៅរដូវវស្សា ស្រះនេះមានទឹកច្រើនថ្លាត្រជាក់ស្អាតល្អណាស់ ដែលធ្វើឲ្យភ្ញៀវចូលចិត្តចុះងូតកម្សាន្តលេងយ៉ាងសប្បាយរីករាយ ហើយសព្វថ្ងៃនេះកំពុងមានភ្ញៀវជាច្រើនទៅទស្សនាជាហូរហែរមិនដាច់ឡើយ។

**ល្អាងព្រះច័ន្ទ** ល្អាងនេះស្ថិតនៅខាងល្អាងស្រះស្រង់ព្រះអាទិត្យទៅលើកម្ពស់ ៣០ម៉ែត្រ។ ល្អាងព្រះច័ន្ទនេះជាទីកន្លែងព្រះវិហារជនជាតិចាមតាំងពីទីនេះនៅជាទឹកសមុទ្រម្ល៉េះ។ ការគោរពរាប់ពាន់ឆ្នាំមុន ចំពោះបារមីព្រះច័ន្ទរបស់ជនជាតិចាមនេះហើយ ទើបធ្វើឲ្យមានការគោរពបូជាមកដល់សព្វថ្ងៃ។ ទីនេះកំពុងមានភ្ញៀវចូលមកទស្សនា និងគោរពបូជាជារៀងរាល់ថ្ងៃ។

**ល្អាងស្រែមួយរយ** ស្ថិតនៅប៉ែកខាងកើតនៃភ្នំឡើងទៅលើកម្ពស់ ៣០ម៉ែត្រ។ ដោយសារមានទឹកហូរធ្លាក់ចុះមកលើផ្ទាំងថ្មរាប់រយឆ្នាំ ធ្វើឲ្យមានថ្មដុះបង្កើតបានជារូបរាងស្រែតូចៗនៅពាសពេញលើផ្ទាំងថ្មគួរឲ្យចាប់អារម្មណ៍។ ប៉ុន្តែដោយសារសង្គ្រាម និងនៅសម័យ ប៉ុល ពត ទីនេះត្រូវជីកកាយយកដីធ្វើឲ្យផ្ទាំងថ្មស្រែមួយរយនេះ ត្រូវបានបាក់បែករលំរលើងខូចខាតអស់ស្ទើរទាំងស្រុង ប៉ុន្តែបច្ចុប្បន្នក៏នៅមានភ្ញៀវចូលទស្សនាជាហូរហែរដែរ[45]។

**ល្អាងញាត់នាគ** ល្អាងនេះស្ថិតនៅប៉ែកខាងកើតភ្នំ។ កាលពីបុរាណ ល្អាងនេះជាកន្លែងដែលអ្នកស្រុកបានយកកូនទៅបួសនៅក្នុងល្អាងនេះមុននឹងដង្ហែរចូលទៅកាន់វត្ត ដើម្បីគ្រងស្បង់ជីវរជាសង្ឃពេញលេញ។ ល្អាងនេះមានឈ្មោះថា វិហារញាត់នាគ មកដល់សព្វថ្ងៃ។

**ល្អាងលោកតាលោកយាយត្រៃភព** ល្អាងនេះស្ថិតនៅខាងជើងល្អាងស្គរហនុមាន។ នៅក្នុងល្អានេះមានផ្សិតថ្មមួយដុះឡើង ជានិមិត្តរូបភពផែនដីដែលដុះក្នុងសមុទ្រមុនគេ ហើយជាទីចាប់អារម្មណ៍របស់ទេសចរខ្លាំងណាស់[46]។

### ២.៣.២ សក្តានុពលភ្នំកំពង់ត្រាច

រមណីយដ្ឋានភ្នំកំពង់ត្រាច មានសក្ដានុពលជាច្រើនដើម្បីទាក់ទាញទេសចរឲ្យមកទស្សនា និងកម្សាន្ត។ ភ្ញៀវដែលទៅកម្សាន្តនៅភ្នំកំពង់ត្រាចមានទាំងទេសចរជាតិ និងអន្តរជាតិ ប៉ុន្តែបើ

---

[45] មន្ទីរទេសចរណ៍ខេត្តកំពត, *ប្រវត្តិ និងលក្ខណៈភូមិសាស្ត្ររមណីយដ្ឋានទេសចរណ៍ភ្នំកំពង់ត្រាច* (កំពតៈ មន្ទីរទេសចរណ៍ខេត្តកំពត, ២០១៧), ៤

[46] មន្ទីរទេសចរណ៍ខេត្តកំពត, *ប្រវត្តិ និងលក្ខណៈភូមិសាស្ត្ររមណីយដ្ឋានទេសចរណ៍ភ្នំកំពង់ត្រាច* (កំពតៈ មន្ទីរទេសចរណ៍ខេត្តកំពត, ២០១៧), ៥

តាមការសង្កេតឃើញភាគច្រើនជាទេសចរជាតិ ដែលពួកគាត់ទៅទីនោះដើម្បីទស្សនារូងភ្នំ ថតរូបផ្តិតយកទិដ្ឋភាពស្រស់ស្អាត ខ្លះទៀតទៅដើម្បីបន់ស្រន់ និងសែនព្រេនទៅតាមអបិយជំនឿ។ ចំណែកឯទេសចរអន្តរជាតិវិញ គឺពួកគាត់ធ្វើដំណើរទៅកាន់ភ្នំកំពង់ត្រាចដើម្បីទស្សនាកម្សាន្តរូងភ្នំដូចគ្នាប៉ុន្តែអ្វីដែលពិសេសនោះ គឺពួកគេចង់ដឹងពីប្រវត្តិដើមទងនៃការកកើតរូងភ្នំដ៏ស្រស់ស្អាតមួយនេះថែមទៀត។

បើគេធ្វើដំណើរតាមផ្លូវរថភ្លើង គេអាចមើលឃើញទិដ្ឋភាពរួមរបស់រមណីយដ្ឋាននេះយ៉ាងច្បាស់ ព្រោះវាមានទីតាំងជាប់នឹងផ្លូវរថភ្លើងតែម្តង។ (ក្នុងឧបសម្ព័ន្ធទី២ រូបទី៩) ពេលចូលទៅក្នុងរមណីយដ្ឋាននោះមានវត្តមួយដែលគេសាងសង់សម្រាប់ប្រជាជនខ្មែរមានឈ្មោះថា **គិរីសិលា** ក៏ដូចជាកសាងជណ្តើរសម្រាប់ឡើងទៅគុហារតូចៗ ដើម្បីរៀបចំកន្លែងសំណាក់ធម៌របស់តាៗយាយជី ឬកន្លែងសម្រាប់គោរពបូជាវត្ថុសក្តិសិទ្ធិផ្សេងៗនៅខាងជើងវត្តនោះ[47]។ បន្ទាប់ពីការដើរកម្សាន្តផុតល្អាងមាត់នាគមក យើងបានឃើញនូវទីធ្លាតូចមួយ ដែលព័ទ្ធជុំវិញដោយជញ្ជាំងថ្មធម្មជាតិពណ៌បៃតង។ យើងក៏បានឃើញមានដី ៧ពណ៌ផ្សេងៗគ្នាដែលគេហៅថា **វាលដី៧ពណ៌** ព្រមទាំងគុហារតូច មធ្យមចំនួន៤-៥ ហើយគេបានកសាងរូបព្រះពុទ្ធចូលបរិនិព្វានមួយអង្គយ៉ាងធំដែលជាកន្លែងសម្រាប់ភ្ញៀវចូលកម្សាន្ត និងគោរពបូជាសុំសេចក្តីសុខនៃបារមីទាំងឡាយ។ ការដើរកម្សាន្តនៅទីធ្លាតូចនេះ យើងក៏បានឃើញនូវផ្លូវតូចចង្អៀតជាច្រើនដែលជាច្រកចូលទៅល្អាងដទៃទៀត។ ជាក់ស្តែង ក្មេងៗដែលនៅតំបន់នោះបានស្គាល់គ្រប់ច្រកល្អាងទាំងអស់ទៅហើយ ធ្វើឲ្យពួកគេអាចនាំទៅច្រកល្អាងផ្សេងទៀតដែលយើងមិនបានឃើញ។ ទឹកដែលស្រក់ពីលើភ្នំចូលមកក្នុងអាងតូច គឺមាននៅតាមល្អាងនីមួយៗ ក៏ដូចជាផ្ទាំងថ្មផងដែរ។ តាមវាលនោះគេអាចធ្វើដំណើរចូលរូងមួយទៀតឆ្ពោះទៅកាន់គុហារវាលស្រែ ១០០។ នៅតាមផ្លូវទល់មុខភូមិដំណាក់កន្ទួតនោះគេបានឃើញបឹងដ៏ស្រស់បំព្រងមួយនៅចន្លោះភ្នំពីរ ហើយផ្ទៃមុខនៃបឹងនោះមានភាពរលោងដូចស្ងួត្រដែលឆ្លុះបញ្ចាំងពីភាពស្រស់ត្រកាល។ បណ្តាទិដ្ឋភាពនៃរូងភ្នំកំពង់ត្រាច ជាអច្ឆរិយវត្ថុមួយដ៏អស្ចារ្យ ដែលធម្មជាតិបានផ្តល់ឲ្យមនុស្សជាតិសម្រាប់ទស្សនាកម្សាន្ត[48]។

### ២.៣.៣ បញ្ហាប្រឈម

បើយើងសង្កេតមើលសក្តានុពលនៅរមណីយដ្ឋានភ្នំកំពង់ត្រាច គឺនៅមានបញ្ហាប្រឈមដែលធ្វើឲ្យមានការរាំងស្ទះក្នុងការអភិវឌ្ឍ។ ថ្វីត្បិតតែពោរពេញដោយសក្តានុពលទេសចរណ៍រួម

[47] មន្ទីរទេសចរណ៍ខេត្តកំពត, *ប្រវត្តិ និងលក្ខណៈភូមិសាស្ត្ររមណីយដ្ឋានទេសចរណ៍ភ្នំកំពង់ត្រាច* (កំពតៈ មន្ទីរទេសចរណ៍ខេត្តកំពត, ២០១៧), ១៣

[48] http://www.terrafirmatourist.com/caves-of-kampong-trach-kampot-caves/ ចូលទស្សនាថ្ងៃទី១៥ កក្កដា ឆ្នាំ២០១៧

ជាមួយនឹងការដាក់ចេញនូវផែនការយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍវិស័យទេសចរណ៍ មន្ទីរទេសចរណ៍ និងក្រសួងទេសចរណ៍ក៏ដោយបញ្ហាប្រឈមនានានៅតែកើតមាននាពេលសព្វថ្ងៃនេះ។ ដោយមើលឃើញបញ្ហាទាំងអស់នោះភាគច្រើនទាក់ទងទៅនឹងហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈ ប្រព័ន្ធទូរគមនាគមន៍ ការបំពុលបរិស្ថាន ការយល់ដឹងរបស់មនុស្ស ការចូលរួមពីអ្នកពាក់ព័ន្ធនៅមានកម្រិត និងកង្វះការផ្គត់ផ្គង់ម្ហូបអាហារ និងភេសជ្ជៈ។

**បញ្ហាហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈ** ក្នុងការធ្វើដំណើរពីរាជធានីភ្នំពេញ ទៅរមណីយដ្ឋានភ្នំកំពង់ត្រាចតាមបណ្តោយផ្លូវជាតិលេខ៣ និង៣១ ផ្លូវមានលក្ខណៈល្អប្រសើរច្រើនដែលងាយស្រួលក្នុងការធ្វើដំណើរ ប៉ុន្តែផ្លូវចូលទៅកាន់រមណីយដ្ឋានភ្នំកំពង់ត្រាចដែលមានប្រវែងប្រមាណ ២គីឡូម៉ែត្រ និងផ្លូវព័ទ្ធជុំវិញ ៤គីឡូម៉ែត្រទៀតជាផ្លូវដីក្រហម ថ្មគ្រោះ រលាក់និងខ្លះទៀតមានភាពខូចខាត ពេលមានភ្លៀងធ្លាក់ម្តងៗធ្វើឲ្យមានការពិបាកក្នុងការធ្វើដំណើរ។ មួយវិញទៀតស្លាកសញ្ញាដែលសម្គាល់ពីរមណីយដ្ឋានភ្នំកំពង់ត្រាចមិនមានគ្រប់គ្រាន់ទេ ប្រសិនបើទេសចរធ្វើដំណើរពីភ្នំពេញគឺមិនអាចងាយមើលឃើញនោះទេ ព្រោះស្លាកសញ្ញាដាក់នៅគៀនផ្លូវច្រកចូល។ ទាក់ទងនឹងចំណតរថយន្ត ទេសចរធ្វើការចតរថយន្តក្នុងបរិវេណវត្ត ព្រោះថាមិនមានកន្លែងធំទូលាយសម្រាប់ចំណតរថយន្តច្បាស់លាស់ត្រឹមត្រូវទេ ថែមទាំងគ្មានអ្នករៀបចំឲ្យមានរបៀបរៀបរយនៅកន្លែងចំណតនោះទៀតផង។ យោងតាមការសម្ភាសផ្ទាល់ពីប្រធានសហគមន៍ទេសចរណ៍បានឲ្យដឹងថាប្រព័ន្ធទូរគមនាគមន៍ ប្រព័ន្ធអគ្គិសនីមានតម្លៃថ្លៃដែលជាហេតុមិនអាចផ្គត់ផ្គង់សេវាកម្មគ្រប់គ្រាន់ដល់ទេសចរ និងប្រជាពលរដ្ឋក្នុងតំបន់ ហើយប្រព័ន្ធទឹកស្អាតមានការខ្វះខាតច្រើន ដោយប្រជាជននៅទីនោះដងទឹកពីស្រះយកទៅប្រើសម្រាប់ជីវភាពប្រចាំថ្ងៃ។ នេះជាបញ្ហាប្រឈមមួយសម្រាប់ប្រជាជននៅក្នុងតំបន់នោះដែលមានកង្វះទឹកស្អាត។ តាមរយៈការសម្ភាសផ្ទាល់ពីលោកពូម្នាក់បានឲ្យដឹងថា នៅខាងឆ្វេងដៃនៃច្រកចូលរមណីយដ្ឋានមានប្រព័ន្ធទឹកស្អាតសម្រាប់ឲ្យប្រជាពលរដ្ឋប្រើប្រាស់ដោយធ្វើការបូម ឬរែក ប៉ុន្តែពុំមានការផ្គត់ផ្គង់គ្រប់គ្រាន់ដល់ប្រជាពលរដ្ឋប្រចាំថ្ងៃនោះទេ។ ដូច្នេះហើយ ទើបធ្វើឲ្យប្រជាពលរដ្ឋប្រើប្រាស់ទឹកនោះដើម្បីធ្វើម្ហូបអាហារ ដែលធ្វើឲ្យមានផលប៉ះពាល់ដល់សុខភាពទេសចរ និងអាជីវករផងដែរ។ វាក៏ជាបញ្ហាប្រឈមដែលគួរតែមានការពិចារណាទៅលើការផ្គត់ផ្គង់ទឹកស្អាតសម្រាប់ប្រជាពលរដ្ឋក្នុងតំបន់។

**បញ្ហាបរិស្ថាន** រាល់ការអភិវឌ្ឍតែងតែគិតពីបញ្ហាដែលទាក់ទងនឹងបរិស្ថាន ដែលបរិស្ថានជាកត្តាមួយដ៏សំខាន់ក្នុងវិស័យទេសចរណ៍។ តាមការមើលឃើញជាក់ស្តែង បរិស្ថាននៅទីនោះពុំសូវមានសោភ័ណភាពស្រស់ស្អាតនៅឡើយទេទាំងកន្លែងអង្គុយលេង បន្ទប់ទឹក និងការរៀបចំទីតាំង

លក់ជាដើម។ ដោយមើលឃើញទីធ្លានៅមុខច្រកចូលល្អាង ក៏ដូចជាក្នុងល្អាងសម្បូរទៅដោយសំរាម និងកាកសំណល់ផ្សេងៗ ព្រមទាំងល្បាប់ភក់ដែលមិនមានការយកចិត្តទុកដាក់រៀបចំក្នុងការសម្អាតត្រឹមត្រូវឡើយ ម៉្យាងវិញទៀតមុខច្រកចូលល្អាងពោរពេញដោយស្លឹកឈើជ្រុះ តូបអង្គុយលេងមិនបានរៀបចំល្អ ហើយកន្លែងខ្លះមានកាកសំណល់ និងមានធុំក្លិនទៀតផង ទីតាំងលក់រៀបចំមិនទាន់មានលក្ខណៈស្តង់ដានៅឡើយទេ។ ប្រព័ន្ធលូជាបញ្ហាប្រឈមសំខាន់ដែលរាំងស្ទះក្នុងការអភិវឌ្ឍ និងអាចធ្វើឲ្យបរិស្ថានមិនមានភាពស្រស់បំព្រង មានក្លិនមិនល្អបណ្តាលឲ្យប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋ និងទេសចរផងដែរ។ ដូច្នេះបញ្ហាបរិស្ថាននេះហើយជាបញ្ហាប្រឈម ដែលទាក់ទងទៅនឹងការអភិវឌ្ឍរមណីយដ្ឋាន។

**កង្វះការផ្គត់ផ្គង់ម្ហូបអាហារ និងភេសជ្ជៈ** ការផ្គត់ផ្គង់ម្ហូបអាហារនៅទីនោះមិនទាន់មាន លក្ខណៈគ្រប់គ្រាន់ទេ។ ទេសចរមួយចំនួនបានប្រាប់ថាការបម្រើអាហារ និងភេសជ្ជៈនៅមិនទាន់មានលក្ខណៈគ្រប់គ្រាន់នៅឡើយទេ ដោយសារការផ្គត់ផ្គង់នោះមានកម្រិតទាប ដែលមិនអាចបំពេញសេចក្តីត្រូវការបានគ្រប់គ្រាន់។ នៅពេលការផ្គត់ផ្គង់មិនគ្រប់គ្រាន់ធ្វើឲ្យទេសចរមិនចង់មកកម្សាន្តព្រមទាំងបាត់បង់ប្រាក់ចំណូលប្រជាជនក្នុងស្រុកផងដែរ។

**ការយល់ដឹងរបស់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ** ស្របពេលដែលវិស័យទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជាកំពុងរីកចម្រើនយ៉ាងឆាប់រហ័ស តម្រូវការកំលាំងពលកម្មក៏កើនឡើងខ្លាំងដែរ ជាពិសេសផ្នែកជំនាញវិជ្ជាជីវៈដែលនៅមានកង្វះខាតច្រើនទាំងបរិមាណ និងគុណភាព។ កម្រិតជំនាញប្រកបដោយគុណភាព គឺជាកត្តាគន្លឹះក្នុងការពង្រឹងគុណភាពសេវាកម្មទេសចរណ៍ និងបង្កើនការប្រកួតប្រជែងតាមរយៈការបំពេញសេចក្តីត្រូវការរបស់ទេសចរជាតិ និងអន្តរជាតិ។ ដូច្នេះហើយ ការយល់ដឹងរបស់ប្រជាពលរដ្ឋជាបញ្ហាប្រឈមយ៉ាងខ្លាំងនៅពេលបណ្តុះបណ្តាលផ្នែកទេសចរណ៍ ជាពិសេសវគ្គខ្លីៗដែលទាក់ទងនឹងសេវាកម្មផ្សេងៗ ឬសេវាកម្មមគ្គុទេសក៏នៅមានលក្ខណៈខ្សោយ ដែលមិនអាចបំពេញតម្រូវការសម្រាប់ទេសចរបានឡើយ។ នៅពេលខ្វះធនធានមនុស្សនឹងមានបញ្ហាកើតឡើងជាច្រើនដែលប្រឈមនឹងការទាក់ទងគ្នា ភាពខ្វះខាតចំណេះដឹងដែលបញ្ហាទាំងនេះហើយធ្វើឲ្យការអភិវឌ្ឍទេសចរណ៍មិនសូវមានភាពរីកចម្រើន និងធ្វើឲ្យរាំងស្ទះដល់ប្រាក់ចំណូលជាតិព្រមទាំងប្រជាពលរដ្ឋផងដែរ។ ដូច្នេះតាមការសាកសួរអាជីវករដែលនៅទីនោះផ្ទាល់ពួកគាត់បាននិយាយថា គាត់មិនបានសិក្សារៀនសូត្រឲ្យបានត្រឹមត្រូវតាមក្បួនខ្នាតនោះទេ ក៏ពុំមានមគ្គុទេសក៏ត្រឹមត្រូវដែរគឺមានតែក្មេងៗនៅតំបន់នោះចេះតៗគ្នារហូតមក។ មួយវិញទៀតការអភិវឌ្ឍទេសចរណ៍ប្រព្រឹត្តទៅបានល្អ និងធានាមាននិរន្តរភាពអាស្រ័យដោយមានការ

ចូលរួមពីផ្នែកពាក់ព័ន្ធនានាជាច្រើន។ ការចូលរួមជាកត្តាមួយសំខាន់បំផុត ដើម្បីធ្វើឲ្យការអភិវឌ្ឍទទួលបាននិរន្តរភាពស្ថិតស្ថេរគង់វង្ស និងមានតម្លៃទៅថ្ងៃអនាគត។ ចំពោះអ្នកចូលរួមធ្វើឲ្យមាននិរន្តរភាពនេះមានការចូលរួមផ្ទាល់ ឬប្រយោលពីបណ្តាសមាសធាតុពាក់ព័ន្ធជាច្រើន ដែលការចូលរួមទាំងនោះមាននាទី និងរបៀបនៃការអនុវត្តផ្សេងៗគ្នាផងដែរ។

យោងទៅតាមការសាកសួររបស់អាជីវករជាច្រើនបានឲ្យដឹងថា រមណីយដ្ឋានភ្នំកំពង់ត្រាចនេះជាសហគមន៍តូចមួយ ប៉ុន្តែមិនមានអ្នកគ្រប់គ្រងច្បាស់លាស់នៅឡើយទេ ហើយគាត់ក៏មានប្រសាសន៍ថាពុំសូវមានអ្នកចូលរួមអភិវឌ្ឍន៍គាំទ្រឡើយ ដោយសារតែខ្វាចខ្វចខាតលក្ខណៈទ្រង់ទ្រាយដើមរបស់រមណីយដ្ឋាន។ សបញ្ជាក់ឲ្យឃើញថា មិនសូវជាមានការចូលរួមពីអ្នកពាក់ព័ន្ធផ្សេងៗនៅឡើយទេ ដូច្នេះធ្វើឲ្យតំបន់រមណីយដ្ឋាននៅទីនោះមិនសូវមានការអភិវឌ្ឍ ហើយចំនួនទេសចរក៏បានធ្លាក់ចុះដោយសារតែបញ្ហាប្រឈមទាក់ទងនឹងអ្នកពាក់ព័ន្ធនេះឯង។

តាមរយៈការជួបសម្ភាសផ្ទាល់ជាមួយនឹងលោកប្រធានសហគមន៍ទេសចរណ៍ ស្រុកកំពង់ត្រាច គាត់មានប្រសាសន៍ថាបញ្ហាប្រឈមដែលមានការរាំងស្ទះដល់ការអភិវឌ្ឍរមណីយដ្ឋានភ្នំកំពង់ត្រាចនេះ គឺដោយសារតែពីមុនប្រជាពលរដ្ឋនៅទីនោះបានវាយថ្មយ៉ាងអនាធិបតេយ្យ ដើម្បីប្រកបរបររកស៊ីចិញ្ចឹមជីវិត ដែលជាហេតុធ្វើឲ្យបាត់បង់នូវសោភ័ណភាពនៃភ្នំ។ គាត់បានបន្តទៀតថា មិនទាន់មានការគ្រប់គ្រងបរិស្ថាន និងកន្លែងចតឡាននៅឡើយទេ នៅពេលមានពិធីបុណ្យធំៗដូចជាបុណ្យមាឃបូជា ពិសាខបូជាជាដើមនៅក្នុងរមណីយដ្ឋានភ្នំកំពង់ត្រាចមានការបោះចោលសំរាមពាសវាលពាសកាលគ្មានសណ្តាប់ធ្នាប់ ហើយពុំមានទីធ្លាគ្រប់គ្រាន់សម្រាប់ចំណតឡានទេដែលធ្វើឲ្យមានការពិបាកដល់ការអភិវឌ្ឍតំបន់នោះ។ នៅរមណីយដ្ឋានភ្នំកំពង់ត្រាច ពុំទាន់មានសេវាស្នាក់នៅទេដូចនេះទើបធ្វើឲ្យទេសចរមកកម្សាន្តតំបន់នោះក្នុងរយៈពេលខ្លី។

# ជំពូកទី៣

# ទស្សនទានក្នុង

# ការអភិវឌ្ឍរមណីយដ្ឋាន

# ភ្នំកំពង់ត្រាច

# ជំពូកទី៣

# ទស្សនទានក្នុងការអភិវឌ្ឍរមណីយដ្ឋានភ្នំកំពង់ត្រាច

ជាទូទៅការអភិវឌ្ឍរមណីយដ្ឋានភ្នំកំពង់ត្រាច ពិតជាមានសារៈសំខាន់ណាស់ដែលមិនអាចខ្វះបានក្នុងការជំរុញឲ្យសេដ្ឋកិច្ចមានការកើនឡើងជាលំដាប់។ តាមរយៈការបកស្រាយខាងលើយើងសង្កេតឃើញថា រមណីយដ្ឋានភ្នំកំពង់ត្រាចកំពុងជួបប្រទះនូវបញ្ហាប្រឈមនានាជាច្រើននាពេលបច្ចុប្បន្ននេះ ទោះបីជាប្រជាពលរដ្ឋនៅទីនោះទទួលបានផលប្រយោជន៍ពីទេសចរក៏ដោយក៏នៅតែជួបបញ្ហាប្រឈមជាច្រើនដែលមិនអាចរំលងបាន។ បញ្ហាប្រឈមទាំងនោះមានដូចជាការខ្វះខាតនូវហេដ្ឋារចនាសម្ព័ន និងសេវាសាធារណៈ ប្រព័ន្ធអគ្គីសនី ប្រព័ន្ធទឹកស្អាត អនាម័យបរិស្ថាន កង្វះការច្នៃប្រឌិតក្នុងការរៀបចំឲ្យមានភាពទាក់ទាញ ការផ្គត់ផ្គង់ម្ហូបអាហារ កង្វះខាតក្នុងការផ្សព្វផ្សាយ និងការលើកទឹកចិត្តឲ្យមានការចូលរួមពីអ្នកពាក់ព័ន្ធនានា។ បញ្ហាទាំងអស់នេះហើយដែលកំពុងបង្ហាញឲ្យមានការយកចិត្តទុកដាក់ក្នុងការរៀបចំគ្រប់គ្រង និងស្តារឡើងវិញពីសំណាក់អាជ្ញាធរដែនដី ប្រជាពលរដ្ឋ ទេសចរ និងស្ថាប័នដែលជាប់ពាក់ព័ន្ធឲ្យបានជិតដល់តាម រយៈការផ្តល់ជាគំនិតក្នុងការរួមចំណែកក្នុងចំណុចដែលមានដូចខាងក្រោម៖

## ៣.១ ការកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈ

តាមរយៈការសម្ភាស និងការចុះអង្កេតបានបង្ហាញឲ្យឃើញថា បញ្ហាប្រឈមជាចម្បងដែលមានការខ្វះខាតក្នុងរមណីយដ្ឋាននេះមានដូចជា ផ្លូវចូលទៅកាន់រមណីយដ្ឋាន ផ្លូវជុំវិញភ្នំ ស្លាកសញ្ញាសម្រាប់បង្ហាញពីទិសក្នុងការធ្វើចរាចរណ៍ និងការរៀបចំកន្លែងចំណតរថយន្ត។ ម្យ៉ាងវិញទៀត នៅតំបន់រមណីយដ្ឋានភ្នំកំពង់ត្រាច ពុំឃើញមានសេវាស្នាក់នៅសម្រាប់ទេសចរដែលមានបំណងចង់ស្នាក់នៅនោះទេ។ ក្នុងនោះប្រទេសជាច្រើននៅលើពិភពលោក គេយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើបញ្ហាទាំងអស់នេះ ដោយសារហេដ្ឋារចនាសម្ព័ន្ធជាផ្នែកមួយដ៏សំខាន់ក្នុងការទាក់ទាញទេសចរឲ្យមកទស្សនាតំបន់នោះ នៅពេលដែលមានផ្លូវស្អាតល្អ វាមានភាពងាយស្រួលក្នុងការធ្វើដំណើរសម្រាប់ទេសចរដែលចង់មកទស្សនាកម្សាន្ត។ ដូច្នេះហើយ យើងគួរធ្វើការរៀបចំផែនការក្នុងការអភិវឌ្ឍទៅលើផ្នែកទាំងអស់នេះដូចខាងក្រោម៖

**ផ្លូវ** ចូលទៅកាន់រមណីយដ្ឋានដែលមានប្រវែងប្រមាណជា ២គីឡូម៉ែត គួរតែធ្វើការរៀបចំឲ្យបានស្អាតដោយមានការចាក់គ្រួសក្រហមឈូសឆាយឲ្យបានស្អាតល្អ និងពង្រីកឲ្យបានកាន់តែធំ ដើម្បីផ្តល់ភាពងាយស្រួលក្នុងការធ្វើដំណើរចូលទៅកាន់រមណីយដ្ឋាន និងការធ្វើចរាចរណ៍សម្រាប់ឡានទេសចរណ៍ធំៗ។ ចំណែកផ្លូវជុំវិញភ្នំវិញ គួរតែមានការរៀបចំឲ្យដូចទៅនឹងផ្លូវចូល

ទៅកាន់រមណីយដ្ឋាន ប៉ុន្តែគួរតែកាប់ឆ្ការព្រៃដែលនៅខាងក្រោយភ្នំជាមុនសិន។ ជាពិសេសផ្លូវចូលទៅក្នុងរូងភ្នំគួរតែធ្វើការចាក់ជាស៊ីម៉ង់ ឬក្រាលជាឥដ្ឋការ៉ូឲ្យបានរាបស្មើល្អតាំងពីផ្លូវចូលរូងរហូតដល់ផ្លូវចេញពីភ្នំ និងកន្លែងដែលមានទីចោទ ឬឡើងខ្ពស់គួរតែរៀបចំឲ្យមានជាជណ្ដើរសម្រាប់ឡើងចុះ ដើម្បីងាយស្រួលក្នុងការដើរទស្សនារបស់ទេសចរ។ (ក្នុងឧបសម្ព័ន្ធទី២ រូបទី២)

**ផ្លាកសញ្ញា** គួរដាក់នូវផ្លាកសញ្ញាផ្សេងៗដូចជា ផ្លាកសញ្ញាបត់ស្ដាំ បត់ឆ្វេង ផ្លាកសញ្ញាបញ្ជាក់ពីទីតាំងនានាទាំងនៅក្នុង និងជុំវិញរមណីយដ្ឋាន ដើម្បីទប់ស្កាត់ក្នុងការកកស្ទះពេលដែលទេសចរមានចំនួនច្រើន មានភាពងាយស្រួលសម្រាប់រថយន្តក្នុងការធ្វើចរាចរណ៍ និងផ្លាកសញ្ញាសំរាប់ទេសចរឲ្យមានការប្រុងប្រយ័ត្ននៅក្នុងរូងភ្នំផងដែរ។ (ក្នុងឧបសម្ព័ន្ធទី២ រូបទី១ និងទី៣)

**ចំណតរថយន្ត** គួររៀបចំឲ្យបានត្រឹមត្រូវដើម្បីឲ្យមានភាពងាយស្រួលក្នុងការចូលចត និងយករថយន្តចេញពីកន្លែងចតនោះ ដោយរៀបចំចំណតនៅខាងក្រៅបរិវេណវត្ត ដើម្បីកុំឲ្យចង្អៀត និងពិបាកក្នុងការចេញចូល ប៉ុន្តែកុំឲ្យឆ្ងាយពីរបងវត្តពេក។

ចំពោះសេវាសាធារណៈក៏មានបញ្ហាប្រឈមជាចម្បងដែលកើតមានដែរ ដូចជាការខ្វះខាតប្រព័ន្ធទូរគមនាគមន៍ ប្រព័ន្ធទឹកស្អាត និងប្រព័ន្ធអគ្គីសនី ដែលបម្រើដល់វិស័យទេសចរណ៍ជាចាំបាច់។ កាលណាដែលតំបន់រមណីយដ្ឋានមានការខ្វះខាតលើបញ្ហាទាំងអស់នេះ ក៏បណ្ដាលឲ្យមានផលវិបាកជាច្រើនផងដែរក្នុងការទាក់ទាញទេសចរឲ្យមកទស្សនាកម្សាន្ត និងរឹតតែពិបាកក្នុងការអភិវឌ្ឍថែមទៀតផង។

**ប្រព័ន្ធអគ្គីសនី** ទោះបីជានៅទីនោះមានប្រព័ន្ធអគ្គីសនី ប៉ុន្តែនៅតែមានការខ្វះខាតនៅឡើយ ពីព្រោះនៅកន្លែងខ្លះនៅមិនទាន់មានដាក់អំពូលភ្លើងបំភ្លឺនៅឡើយ ហើយផ្ទះប្រជាពលរដ្ឋខ្លះក៏មិនទាន់មានការភ្ជាប់ប្រព័ន្ធអគ្គីសនីដែរ។ ម្យ៉ាងវិញទៀត នៅក្នុងរូងភ្នំពុំមានភ្លើងបំភ្លឺគ្រប់គ្រាន់ទេ ដែលជាការពិបាកក្នុងការទស្សនា និងធ្វើឲ្យទេសចរមានអារម្មណ៍ភ័យខ្លាច ហើយមិនសូវហ៊ានចូលនៅពេលងងឹត។ តាមការសម្ភាសជាមួយប្រជាជនអំពីប្រព័ន្ធអគ្គិសនី បានឲ្យដឹងដូចខាងក្រោម៖

ក្រាហ្វិកទី១. ការយល់ឃើញរបស់ប្រជាជនអំពីប្រព័ន្ធអគ្គិសនី




យោងតាមក្រាហ្វិកខាងលើបានបង្ហាញពីការឆ្លើយរបស់ប្រជាជនថា មានប្រព័ន្ធអគ្គិសនីគ្រប់គ្រាន់ចំនួន ៤គំរូតាង ត្រូវនឹង២០% និងមិនគ្រប់គ្រាន់ចំនួន ១៦គំរូតាង ត្រូវនឹង៨០%។ តាមការសម្ភាសនេះបានឲ្យដឹងថាមានប្រព័ន្ធអគ្គីសនី ប៉ុន្តែវាមានតម្លៃថ្លៃបន្តិចយ៉ាងណាក៏នៅតែមានការខ្វះខាតនៅឡើយ ហើយចំពោះការផ្គត់ផ្គង់ក្នុងរមណីយដ្ឋានមានកង្វះខាតទៅលើការចំណាយក្នុងការប្រើប្រាស់ដែលជាហេតុនាំឲ្យមានការខ្វះខាតក្នុងការរៀបចំបំពាក់នូវប្រព័ន្ធភ្លើងក្នុងរូងភ្នំ និងជុំវិញតំបន់នេះ។ ហេតុនេះហើយ សូមឲ្យផ្នែកពាក់ព័ន្ធទាំងអស់គួរគិតគួរលើបញ្ហានេះ ដូចជារៀបចំ កំណត់តម្លៃឲ្យបានសមរម្យដាក់ឧបករណ៍ភ្លើងបំភ្លឺឲ្យបានគ្រប់ទីកន្លែង មិនថាតាមផ្លូវចូលផ្លូវព័ទ្ធជុំវិញភ្នំក្នុងបរិវេណតំបន់រមណីដ្ឋាននេះទេ ជាពិសេសក្នុងរូងភ្នំតែម្តង ព្រោះថាកាលណាខ្វះខាតផ្នែកណាមួយនាំឲ្យការអភិវឌ្ឍមានការរាំងស្ទះ ហើយទេសចរនឹងមិនមានការសម្រាកកម្សាន្តទេ បើសិនមានការខ្វះខាតផ្នែកផ្សេងៗដូចជាផ្នែកប្រព័ន្ធអគ្គីសនីជាដើម។ ម្យ៉ាងទៀត គួរតែស្វែងរកដៃគូរសហការណ៍ស្ថាប័នឯកជន ឬអង្គការក្រៅរដ្ឋាភិបាលក្នុងការផ្តល់ជាជំនួយឧបត្ថម្ភជាថវិកាដើម្បីចំណាយលើការប្រើប្រាស់ក្នុងរមណីយដ្ឋាននេះ។

**ប្រព័ន្ធទូរគមនាគមន៍** ចំពោះការទំនាក់ទំនងវិញក៏សង្កេតឃើញមានការពិបាកដែរដោយសារតែពេលចូលដល់ក្នុងតំបន់នោះមិនសូវមានសេវាទូរស័ព្ទឡើយ។ ហេតុដូច្នេះហើយ គ្រប់បុគ្គលិកដែលបម្រើការក្នុងរមណីយដ្ឋាននេះ គួរតែមានឧបករណ៍ទំនាក់ទនងផ្ទាល់ដូចជា អាយកូមជាដើម ដើម្បីងាយស្រួលផ្តល់ពត៌មានទៅគ្នាទៅវិញទៅមកពេលធ្វើការ និងសម្រាប់អ្នកដែលនាំភ្ញៀវចូលទស្សនាបានរាយការណ៍រាល់ពត៌មានផ្សេងៗ និងពេលមានបញ្ហាដែលកើតមានឡើងជាយថាហេតុ។

**ប្រព័ន្ធទឹកស្អាត** ជាមួយគ្នានេះដែរប្រព័ន្ធទឹកស្អាត ក៏ដើរតួរនាទីយ៉ាងសំខាន់សម្រាប់បម្រើឲ្យវិស័យទេសចរណ៍ និងសម្រួលដល់ការរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់រមណីយដ្ឋាននេះដែរ។ ខាងក្រោមនេះ ជាពត៌មានដែលទាក់ទងនឹងការផ្គត់ផ្គង់ប្រព័ន្ធទឹកស្អាតនៅក្នុងរមណីយដ្ឋានភ្នំកំពង់ត្រាច។

ក្រាហ្វិកទី២. ការយល់ឃើញពីប្រព័ន្ធទឹកស្អាតរបស់ប្រជាជន




យោងតាមក្រាហ្វិកខាងលើបានឲ្យដឹងថា ការផ្គត់ផ្គង់ប្រព័ន្ធទឹកស្អាតមិនទាន់មានលក្ខណៈគ្រប់គ្រាន់ទេ តាមការឆ្លើយរបស់ប្រជាជនដែលមានគ្រប់គ្រាន់ចំនួន ៣គំរូតាង ត្រូវនឹង១៤% និងមិនគ្រប់គ្រាន់មានចំនួន ១៧គំរូតាង ត្រូវនឹង៨៦%។ ដោយតាមរយៈការសម្ភាស និងចុះសង្កេតដោយផ្ទាល់បានឲ្យដឹងថាប្រព័ន្ធទឹកស្អាតក្នុងតំបន់នោះមានហើយ ក៏ប៉ុន្តែមិនបានចែកចាយគ្រប់គ្រាន់ និងតាមសេចក្តីត្រូវការរបស់ប្រជាជនប្រើប្រាស់ជាប្រចាំថ្ងៃទេ។ ដោយសារតែបរិមាណទឹកនៃផ្ទះផ្គត់ផ្គង់ទឹកស្អាតនោះធ្វើការចែកចាយ គឺនៅមានកំណត់នៅឡើយ ហើយចំពោះតម្លៃក៏មានតម្លៃថ្លៃដែរ។ ដូច្នេះហើយ សូមស្ថាប័នដែលពាក់ព័ន្ធនានាគួរគប្បីរៀបចំនូវប្រព័ន្ធទឹកស្អាតឲ្យបានចូលដល់គ្រប់ផ្ទះប្រជាពលរដ្ឋក្នុងតំបន់នោះទាំងអស់ ហើយកំណត់តម្លៃឲ្យបានក្នុងកម្រិតទាបមួយដែលអាចឲ្យប្រជាជននៅទីនោះ មានលទ្ធភាពប្រើប្រាស់បានព្រមទាំងធ្វើការបង្កើននូវការផលិតទាំងគុណភាព និងបរិមាណ ដើម្បីលើកកម្ពស់សុខភាព និងការប្រើប្រាស់របស់ ប្រជាពលរដ្ឋក្នុងតំបន់ និងទេសចរដែលមកទស្សនា។ (ក្នុងឧបសម្ព័ន្ធទី២ រូបទី៨)

## ៣.២ ការបង្កើនគុណភាពអាហារ និងភេសជ្ជៈ (គុណភាព អនាម័យ បដិសណ្ឋារកិច្ច)

តាមការសង្កេតមើលការផ្គត់ផ្គង់ម្ហូបអាហារ និងភេសជ្ជៈរបស់អាជីវករចំពោះទេសចរ គឺនៅមានភាពខ្វះខាតច្រើនទាំងគុណភាព និងអនាម័យ។ តាមរយៈការធ្វើបទសម្ភាសន៍ជាមួយទេសចរ និងប្រជាពលរដ្ឋបានឆ្លុះបញ្ចាំងឲ្យឃើញពីភាពខ្វះខាតនូវគុណភាពនៃការចម្អិនអាហារ និងការកែលម្អសោភ័ណភាពអាហារជាដើម។ ជាមួយគ្នានេះដែរ ការផ្តល់បដិសណ្ឋារកិច្ចជូនទេសចរក៏មានការខ្វះខាតច្រើនដែរពីសំណាក់អាជីវករក្នុងតំបន់រមណីយដ្ឋាននោះ។

### ៣.២.១ ការរៀបចំតូបអង្គុយ និងតូបលក់ដូរ

ជាមួយគ្នានេះដែរតូបអង្គុយ និងតូបលក់ដូរក៏ជារឿងមួយគួរឲ្យយកចិត្តទុកដាក់ក្នុងការរៀបចំផងដែរ ព្រោះថានៅពេលដែលទេសចរមកទស្សនាកម្សាន្តតំបន់រមណីយដ្ឋាននីមួយៗតែងតែចង់បានកន្លែងអង្គុយសម្រាក និងទទួលទានអាហារជុំគ្នាបន្ទាប់ពីនឿយហត់ក្នុងការទស្សនា។ កាលពីដើមឆ្នាំ ២០១៧ គេសង្កេតឃើញមានប្រជាពលរដ្ឋប្រមាណជាបួន-ប្រាំគ្រួសារបានបង្កើតជាអាជីវកម្មផ្ទាល់ខ្លួនជាតូបអង្គុយញ៉ាំអាហារនៅតាមផ្ទះរបស់គាត់ផ្ទាល់។ (ក្នុងឧបសម្ព័ន្ធទី២ រូបទី៧) ចំពោះការបង្កើតអាជីវកម្មនេះផងដែរ ខាងស្ថាប័នពាក់ព័ន្ធគួរតែមានការចុះមកណែនាំ និងត្រួតពិនិត្យផងដែរលើការសាងសង់កញ្ចុះទាំងអស់ដូចជាៈ

**ដំបូល** នៅតាមតូបអង្គុយលេងនីមួយៗត្រូវមានការប្រក់ដំបូលស័ង្កសីឲ្យបានជិត និងស្អាតដើម្បីជៀសវាងនៅពេលមានភ្លៀង និងជួយណែនាំដល់អាជីវករឲ្យមានការពិនិត្យមើល និងជួសជុលក៏ដូចជាកំណត់រយៈពេលនៃការផ្លាស់ប្តូរថ្មី ដើម្បីធ្វើឲ្យទេសចរមានផាសុកភាពនៅពេលទទួលទានអាហារ។

**សសរតូបអង្គុយ** តាមការសង្កេតឃើញនៅតាមតូបនីមួយៗមានគ្រែ និងបង់អង្គុយលេង ចំណែកឯសសរវិញគួរតែជ្រើសរើសយកឈើណាដែលមានសភាពរឹងមាំ ដើម្បីជៀសវាងការបាក់ធ្លាក់ស្របពេលដែលទេសចរកំពុងអង្គុយលេងធ្វើឲ្យគ្រោះថ្នាក់ដល់ទេសចរ។ ដូច្នេះ សូមអាជីវករនៅក្នុងរមណីយដ្ឋានទាំងអស់គួរគិតគូរឡើងវិញ ដើម្បីឲ្យទេសចរមានទំនុកចិត្តក្នុងការអង្គុយលេងនៅតាមតូបនីមួយៗ។

### ៣.២.២ អាជីវករ

ចំណេះដឹង និងជំនាញក្នុងការបង្កើនគុណភាពម្ហូបអាហារត្រូវមានការបណ្តុះបណ្តាលផ្នែកម្ហូបអាហារទៅកាន់អាជីវករក្នុងតំបន់ ឲ្យពួកគាត់មានជំនាញច្បាស់លាស់ក្នុងការចម្អិនម្ហូបអាហារ

និងរៀបចំម្ហូបអាហារឲ្យមានភាពទាក់ទាញដល់ទេសចរ។ ខាងក្រោមនេះជាពត៌មាន ដែលទាក់ទង នឹងការចម្អិនអាហាររបស់ប្រជាជន៖

ក្រាហ្វិកទី៣. ប្រជាជនចេះរបៀបចម្អិនអាហារតាមរយ:




យោងតាមការសម្ភាសបានឲ្យដឹងថាអាជីវករនៅរមណីយដ្ឋាននេះ ភាគច្រើនពួកគាត់ចេះរបៀបចម្អិនអាហារតាមគ្រួសារមានចំនួន ១៧គំរូតាង ត្រូវនឹង៨៨% និងតាមការបណ្តុះបណ្តាលមានចំនួន ៣គំរូតាង ត្រូវនឹង១២% ដែលនេះជាមូលហេតុនាំឲ្យគុណភាពអាហារនៅមានកម្រិត ហើយពួកគាត់ពុំទាន់មានគំនិតក្នុងការកែច្នៃអាហារឲ្យកាន់តែល្អប្រសើរនៅឡើយទេ។ ហេតុដូច្នេះហើយខាងអាជ្ញាធរដែនដី និងមន្ទីរទេសចរណ៍គួរតែស្វែងរកផ្នែកឯកជន ជាពិសេសអ្នកជំនាញមកពីសាលាបណ្តុះបណ្តាលខាងម្ហូបអាហារ ភោជនីយដ្ឋាន និងសណ្ឋាគារ ចូលរួមជួយណែនាំបង្ហាត់បង្រៀនពីការចម្អិនម្ហូបអាហារឲ្យបានត្រឹមត្រូវតាមស្តង់ដា និងបច្ចេកទេសប្រកបដោយគុណ (បរិមាណ និងតម្លៃ) ការរៀបចំអាហារព្រមទាំងសោភ័ណភាពនៃការទុកដាក់ចាប់អាហារឲ្យបានស្អាត។ មន្ទីរទេសចរណ៍ខេត្ត និងមន្ទីរបរិស្ថានចាំបាច់ត្រូវចុះទៅពន្យល់ពួកគាត់អំពីការកាត់បន្ថយ ឬបញ្ឈប់ការប្រើប្រាស់ថង់ប្លាស្ទិចសម្រាប់វេចខ្ចប់ផងដែរ។

ម្យ៉ាងវិញទៀត តាមការចុះអង្កេតដោយផ្ទាល់ និងតាមការសម្ភាសជាមួយទេសចរក៏បានបង្ហាញនូវភាពខ្វះខាតក្នុងការផ្គត់ផ្គង់អាហារសម្រាប់ទេសចរក្នុងរមណីយដ្ឋានផងដែរ។

ក្រាហ្វិកទី៤. ការយល់ឃើញរបស់ទេសចរចំពោះការផ្គត់ផ្គង់អាហារក្នុងរមណីយដ្ឋាន




តាមរយៈក្រាហ្វិកខាងលើបានបង្ហាញនូវចម្លើយរបស់ទេសចរក្នុងការសម្ភាសថា ការផ្គត់ផ្គង់អាហារដែលមានលក្ខណៈគ្រប់គ្រាន់មានចំនួន ៦គំរូតាង ត្រូវនឹង១២% សមរម្យមានចំនួន ៩គំរូតាង ត្រូវនឹង១៨% និងមិនមានគ្រប់គ្រាន់មានចំនួន ៣៥គំរូតាង ត្រូវនឹង៧០%។ តាមរយៈពត៌មានខាងលើបានសបញ្ជាក់ឲ្យឃើញថា អាជីវករក្នុងតំបន់រមណីយដ្ឋានភ្នំកំពង់ត្រាចមិនទាន់មានលទ្ធភាពគ្រប់គ្រាន់ក្នុងការផ្គត់ផ្គង់អាហារចំពោះទេសចរនៅឡើយទេ ដោយសារតែចំនួនមុខម្ហូបមានតិច និងបរិមាណក្នុងការលក់នៅមានកម្រិត។ ដូច្នេះហើយគួរតែមានការរៀបចំបង្កើនមុខម្ហូបឲ្យបានច្រើនជាងមុន ក៏ដូចជាបង្កើតនូវមុខម្ហូបប្រចាំតំបន់រមណីយដ្ឋាននេះផ្ទាល់ ដើម្បីជាភាពទាក់ទាញមួយ និងបំពេញទៅតាមសេចក្ដីត្រូវការរបស់ទេសចរ។

ក្រាហ្វិកទី៥. ការយល់ឃើញរបស់ទេសចរអំពីការបម្រើសេវាកម្ម



តាមក្រាហ្វិកខាងលើកក៏បានបង្ហាញនូវចំនួនទេសចរភាគច្រើនយល់ឃើញថា ការបម្រើសេវាកម្មមិនទាន់មានលក្ខណៈគ្រប់គ្រាន់នោះមានចំនួនដល់ទៅ ៤០គំរូតាង ត្រូវនឹង៨០% និងមានគ្រប់គ្រាន់ចំនួន ១០ គំរូតាង ត្រូវនឹង២០%។ បងប្រុសដែលទៅកម្សាន្តនៅទីនោះបានប្រាប់ឲ្យដឹងថា អាជីវករមិនសូវមានភាពរាក់ទាក់ទេ ហើយការបម្រើអាហារ និងការស្នើសុំអ្វីមួយមានភាពយឺតយ៉ាវ។ ដូច្នេះហើយសូមស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរគួរតែរៀបចំវគ្គបណ្តុះបណ្តាលខ្លីៗ ស្តីពីការបម្រើសេវាកម្មម្ហូបអាហារដល់អាជីវករ ដើម្បីឲ្យពួកគាត់បានយល់ដឹង និងមានជំនាញក្នុងការប្រកបរបរក្នុងវិស័យទេសចរណ៍នេះ។

មួយវិញទៀត ប្រជាពលរដ្ឋ និងអាជីវករដែលលក់ម្ហូបអាហារនៅក្នុងតំបន់បានសំណូមពរឲ្យមន្ទីរ ឬស្ថាប័នជាប់ពាក់ព័ន្ធជួយកែសម្រួលនូវសេវាម្ហូបអាហារ ឲ្យមានការបណ្តុះបណ្តាលផ្នែកចម្អិនអាហារ ព្រោះពួកគាត់ចេះតែវិធីចម្អិនអាហារតាមគ្រួសារតៗគ្នា ដូច្នេះហើយទើបធ្វើឲ្យអាហារគ្មានស្តង់ដា និងគ្មានគុណភាពដើម្បីទាក់ទាញទេសចរឲ្យមកកម្សាន្ត ក៏ដូចជារីករាយជាមួយនឹងអាហារប្រចាំតំបន់ផងដែរ។

### ៣.២.៣ ប្រភពគ្រឿងផ្សំ

ក្នុងសាច់ បន្លែ ផ្លែឈើដែលមានគុណភាពសម្រាប់សុខភាពជារឿងចម្បងផងដែរ ដែលយើងត្រូវដឹងឲ្យច្បាស់ពីប្រភពនាំចូលជៀសវាងមានផលប៉ះពាល់ដល់ទេសចរ។ ប្រសិនបើទិញតាមចំការដែលប្រជាជនកសិករដាំដោយផ្ទាល់នោះកាន់តែល្អ ជៀសវាងទៅទិញនៅតាមផ្សារអាចជា បន្លែ ត្រី សាច់ដែលនាំចូលពីប្រទេសជិតខាងមានជាតិគីមី ធ្វើឲ្យប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋបូករួមទាំងទេសចរផងដែរ។ ខាងក្រោមនេះ ជាពត៌មានដែលយើងធ្វើការសម្ភាសជាមួយអាជីវករទាក់ទងនឹងប្រភពគ្រឿងផ្សំ (ប៊ីចេង អំបិល សាច់ត្រី បន្លែ ម្សៅស៊ុប...) ដែលយកមកប្រើប្រាស់ក្នុងការចម្អិនម្ហូបអាហារ។

ក្រាហ្វិកទី៦. ប្រភពគ្រឿងផ្សំដែលអាជីវករយកទៅចម្អិនអាហារ




យោងតាមក្រាហ្វិកខាងលើបានឲ្យដឹងថា គ្រឿងផ្សំដែលអាជីវករយកមកប្រើប្រាស់ភាគច្រើនបានទិញពីផ្សារមានចំនួន ៣៥គំរូតាង ត្រូវនឹង៧០% ផលិតដោយខ្លួនឯងមានចំនួន ៩គំរូតាង ត្រូវនឹង១៨% និងផលិតក្នុងភូមិមានចំនួន ៦គំរូតាង ត្រូវនឹង១២%។ នេះបានបញ្ជាក់ថា ប្រភពបន្លែ ត្រីសាច់សម្រាប់ផ្គត់ផ្គង់អាហារនៅទីនោះមិនទាន់មានលក្ខណៈល្អនៅឡើយទេ ដោយសារតែខាងអាជីវករភាគច្រើនបានទិញពីផ្សារដែលនៅជិតរមណីយដ្ឋាននោះ។ ដូច្នេះផ្នែកពាក់ព័ន្ធទាំងអស់ គួរធ្វើការលើកទឹកចិត្តដល់ប្រជាពលរដ្ឋក្នុងតំបន់ឲ្យដាំដំណាំ បន្លែ ផ្លែឈើនៅក្នុងភូមិជាជាងទិញមកពីផ្សារ ព្រោះថាបើមានបន្លែ ផ្លែឈើដែលដាំដោយខ្លួនឯងគ្មានជាតិគីមីដែលមិនធ្វើឲ្យប៉ះពាល់ដល់សុខភាព និងផ្តល់ជាប្រាក់កម្រៃដល់ពួកគាត់ផងដែរ។ ចំណែកការដាំដំណាំ ចិញ្ចឹមសត្វក៏ជាផ្នែកមួយដែលអាចទាក់ទាញទេសចរបាន ព្រោះការធ្វើដំណើរកម្សាន្តមិនមែនគ្រាន់តែទស្សនានូវល្អាងភ្នំ និងសក្តានុពលផ្សេងៗនោះទេ ផ្នែកដំណាំកសិកម្ម ក៏ជាផ្នែកមួយដ៏សំខាន់នៅក្នុងវិស័យទេសចរណ៍ផងដែរ។ មួយវិញទៀត ប្រជាពលរដ្ឋក្នុងតំបន់ត្រូវចាំបាច់បង្កើនការផលិតនិង ផ្គត់ផ្គង់ភេសជ្ជៈប្រចាំតំបន់ឲ្យបានច្រើនរួមមានទឹកអំពៅ ទឹកដូង ទឹកត្នោតផ្អែម និងទឹកត្នោតជូរជាដើម។

ចំណែកឯគ្រឿងទេសវិញ ប្រជាពលរដ្ឋក៏ដូចជាអាជីវករបានប្រាប់ថាគ្រឿងផ្សំដែលយកមកធ្វើម្ហូបអាហារមួយផ្នែកធំត្រូវបាននាំចូលពីផ្សារ និងតំបន់ខាងក្រៅ (ប៊ីចេង អំបិល ម្សៅស៊ុប និងគ្រឿងទេសផ្សេងៗជាដើម) ក្នុងនោះដែរ សូមស្ថាប័នពាក់ព័ន្ធនានាគួរតែមានការត្រួតពិនិត្យរាល់ទំនិញនាំចូលទាំងអស់នេះឲ្យបានច្បាស់លាស់មុននឹងឲ្យនាំចូលមកលក់ក្នុងទីផ្សារ និងទប់ស្កាត់រាល់ទំនិញខូចគុណភាព ដែលបណ្តាលឲ្យមានផលប៉ះពាល់ដល់សុខភាពរបស់ប្រជាពលរដ្ឋ។

### ៣.២.៤ ឧបករណ៍ក្នុងការចម្អិនអាហារ

ក្នុងការរៀបចំធ្វើម្ហូបអាហារឲ្យកាន់តែមានរសជាតិឆ្ងាញ់ និងមានភាពឆាប់រហ័ស ក្នុងនោះដែរក៏ទាមទារឲ្យមាននូវឧបករណ៍សម្រាប់ចម្អិនទំនើបៗ ដែលផ្តល់ផាពងាយស្រួលប៉ុន្តែវាមានតម្លៃថ្លៃខ្លាំង។ តាមរយៈការសម្ភាសជាមួយបងស្រីម្នាក់ដែលជាអ្នកធ្វើម្ហូបបានប្រាប់ថា ឧបករណ៍ដែលគាត់យកមកប្រើប្រាស់ក្នុងការចម្អិនអាហាររាល់ថ្ងៃមានចង្រ្កានដីឥដ្ឋ ខ្ទះ វែក កាំបិតតូចធំ ឆ្នាំង និងរបស់របរផ្សេងៗទៀត។ ទាក់ទងនឹងការប្រើប្រាស់ចង្រ្កានដីឥដ្ឋនេះគាត់បានបន្ថែមថា ត្រូវចំណាយពេលយូរបន្តិច ព្រោះថាមុនធ្វើម្ហូប គាត់ត្រូវចំណាយពេលបង្កាត់ភ្លើងទើបអាចរៀបចំចម្អិនអាហារបាន។ ហេតុនេះហើយ គួរណែនាំឲ្យពួកគាត់ប្រើប្រាស់ជាចង្រ្កានហ្គាសធុនតូច ឬធំទៅតាមសមត្ថភាពរបស់ពួកគាត់ និងបង្ហាញពីរបៀបថែរក្សាប្រើប្រាស់ ដើម្បីជៀសវាងការកើតមានឧបទ្ទវហេតុផ្សេងៗដែលកើតមានឡើង។ លើសពីនេះទៀត គួរធ្វើការដុះលាងសម្អាតឲ្យបានស្អាត និងមានការរៀបចំទុកដាក់នូវឧបករណ៍ទាំងនោះឲ្យមានអនាម័យ និងសណ្តាប់ធ្នាប់។

### ៣.៣ បង្កើនការគ្រប់គ្រងផ្នែកបរិស្ថាននិងអនាម័យ

តាមការលើកឡើងខាងលើ និងការចុះអង្កេតដោយផ្ទាល់បានបង្ហាញថា ការគ្រប់គ្រងអនាម័យ និងបរិស្ថានពិតជាមានសារៈសំខាន់ដែលពុំអាចខ្វះបានពិតមែន ដោយសារតែការខ្វះខាតនូវការសម្អាត និងការយកចិត្តទុកដាក់ពីសំណាក់អ្នកពាក់ព័ន្ធនានាទើបធ្វើឲ្យតំបន់ជុំវិញភ្នំ ក្នុងរូងភ្នំក្រោមដើមឈើ ក្រោយតូបលក់មានកាកសំណល់ផ្សេងៗ ចំណែកឯនៅបរិវេណជុំវិញភ្នំកំពង់ត្រាចមានការខ្វះខាតនូវធុងសំរាមព្រមទាំងបង្គន់អនាម័យផងដែរ។ ចំពោះការចូលរួមថែរក្សាបរិស្ថាន និងអនាម័យគឺជាកត្តាចាំ បាច់មួយដែលបង្ហាញពីគុណភាព និងផាសុកភាពនៃជីវិតរស់នៅរបស់ប្រជាជននៅក្នុងតំបន់។

ក្រាហ្វិកទី៧. ការយល់ឃើញរបស់ទេសចរពីការទុកដាក់កាកសំណល់



ទន្ទឹមនឹងនេះដែរ យោងតាមការសម្ភាសជាមួយទេសចរបានបង្ហាញថា ទេសចរបានវាយតម្លៃ ទៅលើការទុកដាក់កាកសំណល់ និងសំរាមផ្សេងៗថា មិនបានរៀបចំទុកដាក់ឲ្យបានល្អមានចំនួន ៣២ គំរូតាង ត្រូវនឹង៦៥% មធ្យមមានចំនួន ១០គំរូតាង ត្រូវនឹង២០% និងល្អមានចំនួន ៨គំរូតាង ត្រូវនឹង១៥% ដូចដែលបានសង្កេតឃើញផ្ទាល់នៅរមណីយដ្ឋានតែម្តង។

ការរក្សាទុកកាកសំណល់ដែលក្នុងនោះមានកាកសំណល់រឹង និងរាវដែលពុំសូវមានការយកចិត្តទុកដាក់ក្នុងការរៀបចំវេចខ្ចប់យកទៅចោលឲ្យបានត្រឹមត្រូវនោះទេ ហើយតាមការសង្កេតឃើញបានឲ្យដឹងថា ធុងសំរាមក៏មិនមានគ្រប់គ្រាន់ដែរដែលជាហេតុបណ្តាលឲ្យទីនោះមានសោភ័ណភាពមិនល្អ។ ហេតុដូចនេះហើយសូមឲ្យស្ថាប័នពាក់ព័ន្ធនានា និងប្រជាពលរដ្ឋទាំងអស់គួររួមគ្នាបោសសម្អាតបរិស្ថានជុំវិញ និងក្នុងរូងភ្នំឲ្យបានស្អាត និងជួយឧបត្ថម្ភជាធុងសំរាមឲ្យបានគ្រប់គ្រាន់ ដើម្បីឲ្យមានភាពស្រស់បំព្រងក្នុងការរស់នៅ ហើយក៏ទទួលបានផលចំណេញពីវិស័យទេសចរណ៍ផងដែរ។ ម៉្យាងវិញទៀត មន្ទីរបរិស្ថាន មន្ទីរទេសចរណ៍ខេត្ត រួមទាំងអាជ្ញាធរដែនដី ត្រូវសហការគ្នាក្នុងការរៀបចំកែលម្អ និងរៀបចំបន្ថែមទៀតដូចជាការរៀបចំឲ្យមានអ្នកបោសសម្អាតសំរាម ឬកាកសំណល់ផ្សេងៗ ដែលមានក្នុងបរិវេណភ្នំកំពង់ត្រាចទាំងមូល និងនៅតាមផ្លូវដែលទេសចរបានបោះចោលឲ្យបានជាប្រចាំដើម្បីធានាឲ្យបាននូវសោភ័ណភាពស្រស់ស្អាត។ ជាមួយគ្នានេះដែរ ប្រជាជនក្នុងតំបន់គួរតែជីកជារណ្តៅដីដាក់ជាលូធំៗដើម្បីដាក់សំរាម ឬដុតចោល។ ទន្ទឹមនឹងនេះ គ្រប់មន្ទីរស្ថាប័នដែលពាក់ព័ន្ធគួររៀបចំប្រព័ន្ធបង្ហូរកាកសំណល់ផ្សេងៗឲ្យបានត្រឹមត្រូវ និងមានសណ្តាប់ធ្នាប់ដោយធ្វើការកែច្នៃដើម្បីគុណប្រយោជន៍ និងជៀសវាងការសាយភាយនូវក្លិនស្អុយដល់ប្រជាជន និងទេសចរដែលអាចបណ្តាលឲ្យប៉ះពាល់ដល់សុខភាពថែមទៀតផង។ ចំណែកឯបង្គន់អនាម័យវិញ ទេសចរក៏បានបង្ហាញនូវការយល់ឃើញដូចខាងក្រោម៖

ក្រាហ្វិកទី៨. ការយល់ឃើញរបស់ទេសចរអំពីបង្គន់អនាម័យ



យោងតាមក្រាហ្វិកខាងលើបានឲ្យដឹងពីការយល់ឃើញរបស់ទេសចរតាមការសម្ភាស គឺភាគច្រើនបានឆ្លើយថាមិនមានបង្គន់អនាម័យគ្រប់គ្រាន់ទេមានចំនួន ៤៧គំរូតាង ត្រូវនឹង៩៥% និងមានគ្រប់គ្រាន់មានចំនួនតែ ៣គំរូតាងប៉ុណ្ណោះដែលត្រូវនឹង៥%។ តាមការសង្កេតដោយផ្ទាល់ឃើញថាសព្វថ្ងៃនេះ ក្នុងរមណីយដ្ឋានភ្នំកំពង់ត្រាចមានបង្គន់អនាម័យតែ ២ បន្ទប់ប៉ុណ្ណោះ ហើយមានទីតាំងនៅក្បែរសាលាឆាន់ និងច្រកចូលរូងភ្នំទៀតផង ដែលពុំសូវមានអនាម័យ ក្លិនមិនល្អ និងការប្រើប្រាស់មិនគ្រប់គ្រាន់ទេ ដោយសារព្រះសង្ឃ លោកតា លោកយាយ ប្រជាពលរដ្ឋ ដែលលក់ដូរក្នុងរមណីយដ្ឋានប្រើប្រាស់រួមគ្នា ជាពិសេសទេសចរក៏ប្រើបង្គន់នោះដែរ។ ដូចនេះយើងគួរតែធ្វើការសាងសង់បង្គន់ឲ្យបានគ្រប់គ្រាន់ ដូចជាក្នុងបរិវេណរមណីយដ្ឋាន និងខាងក្រោយភ្នំ ហើយមានចម្ងាយសមល្មមពីរមណីយដ្ឋាន មិនតែប៉ុណ្ណោះគួរតែមានការសម្អាតឲ្យបានស្អាតជាប្រចាំផងដែរ។ ចំពោះអ្នកដែលបន្ទោរបង់ផ្ដេសផ្ដាសគួរតែមានការដាកពិន័យ ហើយបង្កើតជាស្លាកអប់រំដាក់នៅតាមដើមឈើ ឬកន្លែងដែលងាយមើលឃើញពីបញ្ហាពាក់ព័ន្ធនានាអំពីបរិស្ថាន។

ការចូលរួមសម្អាតបរិស្ថានក៏ជាវិធានការដ៏ល្អមួយសម្រាប់អាជ្ញាធរភូមិ ឃុំ សាលាខេត្ត មន្ទីរបរិស្ថាន មន្ទីរសុខាភិបាលខេត្ត ត្រូវតែធ្វើការគិតគូរឡើងវិញទៅលើការផ្សព្វផ្សាយ អប់រំប្រជាពលរដ្ឋក្នុងការចូលរួមយកចិត្តទុកដាក់ថែរក្សាបរិស្ថាន និងកាកសំណល់ផ្សេងៗឲ្យបានត្រឹមត្រូវក្នុងនោះដែរ ធុងសំរាមក៏ត្រូវបានធ្វើការបែងចែកទៅតាមប្រភេទកាកសំណល់ និងត្រូវដាក់ធុងសំរាមនៅតាមទីសាធារណៈ និងគ្រប់ទីកន្លែងជុំវិញភ្នំឲ្យបានគ្រប់គ្រាន់។

យោងតាមការសម្ភាសអាជ្ញាធរដែលពាក់ព័ន្ធនឹងប្រជាពលរដ្ឋទាំងអស់ គួរតែរួមគ្នាបោសសម្អាតបរិស្ថានជុំវិញ និងក្នុងរូងភ្នំកំពង់ត្រាចឲ្យបានស្អាត ដើម្បីឲ្យមានភាពស្រស់បំព្រងក្នុងការរស់នៅ ហើយក៏ទទួលបានផលចំណេញពីវិស័យទេសចរណ៍ដែរ។ ម៉្យាងវិញទៀត មន្ទីរបរិស្ថាន មន្ទីរទេសចរណ៍ខេត្តរួមទាំងអាជ្ញាធរដែនដីត្រូវសហការគ្នាក្នុងការរៀបចំកែលម្អ និងរៀបចំបន្ថែមទៀតដូចជា ការរៀបចំឲ្យមានអ្នកបោសសម្អាតសំរាម ឬកាកសំណល់ផ្សេងៗដែលមានក្នុងបរិវេណភ្នំកំពង់ត្រាចទាំងមូល និងនៅតាមផ្លូវដែលទេសចរបានបោះចោលឲ្យបានជាប្រចាំ ដើម្បីធានាឲ្យបាននូវសោភ័ណភាពស្រស់ស្អាត។ ទន្ទឹមនឹងនេះដែរ គ្រប់មន្ទីរស្ថាប័នដែលពាក់ព័ន្ធគួររៀបចំប្រព័ន្ធបង្ហូរកាកសំណល់ផ្សេងៗឲ្យបានត្រឹមត្រូវ និងមានសណ្ដាប់ធ្នាប់ដោយធ្វើការកែច្នៃដើម្បីគុណប្រយោជន៍។

## ៣.៤ ពត្រឹមផ្នែកសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់

យើងបានដឹងរួចមកហើយថាសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ជាផ្នែកមួយដ៏សំខាន់នៅតាមតំបន់ទេសចរណ៍ កាលណាមានសន្តិសុខ និងសណ្តាប់ធ្នាប់ល្អនោះនឹងធ្វើឲ្យទេសចរចង់ទៅកម្សាន្តនៅរមណីយដ្ឋាននោះ ប៉ុន្តែបើទេសចរឮថារមណីយដ្ឋាននោះមានបញ្ហាសន្តិសុខ និងសណ្តាប់ ធ្នាប់ធ្វើឲ្យអារម្មណ៍នៃការចង់ទៅកម្សាន្តរបស់ទេសចរ បានបាត់បង់បន្តិចម្តងៗអាចនឹងលែងមានអ្នក ចង់ទៅកម្សាន្តនៅតំបន់នោះ។ ចំណែករមណីយដ្ឋានភ្នំកំពង់ត្រាចមិនទាន់មានការរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់បានល្អនៅឡើយទេ។ ខាងក្រោមនេះ ជាពត៌មានដែលបង្ហាញពិការយល់ឃើញរបស់ទេសចរចំពោះបញ្ហាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ក្នុងរមណីយដ្ឋានភ្នំកំពង់ត្រាច។

ក្រាហ្វិកទី៩. ការយល់ឃើញរបស់ទេសចរលើសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់




យោងតាមក្រាហ្វិកខាងលើបានបង្ហាញថា មានទេសចរភាគច្រើនដែលគាត់យល់ឃើញថាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ក្នុងរមណីយដ្ឋាននេះគួរតែពង្រឹងបន្ថែមដែលមានចំនួនដល់ទៅ ៣១គំរូតាង ត្រូវនឹង៦២%។ ហេតុដូច្នេះហើយ យើងគួរតែមានការរៀបចំលើបញ្ហានេះឲ្យបានល្អ ដើម្បីសុវត្ថិភាពទេសចរ អាជីវករដែលលក់ដូរ ក៏ដូចជានៅតាមកន្លែងផ្សេងៗក្នុងរមណីយដ្ឋាននេះ។ យើងត្រូវគិតគូរទៅលើកម្លាំងសន្តិសុខ ឬអ្នកយាមឲ្យបានគ្រប់គ្រាន់ដោយរៀបចំធ្វើយ៉ាងណាឲ្យពួកគាត់មើលការខុសត្រូវទាំងក្នុង និងជុំវិញភ្នំឲ្យបានជាប្រចាំ រួមទាំងទទួលខុសត្រូវក្នុងការថែរក្សារថយន្តរបស់ទេសចរ។ ម្យ៉ាងទៀត គួរបង្កើតឲ្យមានកន្លែងផ្តល់ពត៌មានដល់ទេសចរនៅខាងមុខរូងភ្នំ ដើម្បីឲ្យពួកគាត់មានការប្រុងប្រយ័ត្ននៅពេលចូលទស្សនាក្នុងរូងភ្នំ។ ចំណែកឯតូបលក់ដូរដែលស្ថិតនៅក្នុងបរិវេណវត្ត ត្រូវធ្វើការស្នើសុំអាជីវករឲ្យមកធ្វើការសង់តូបលក់ដូរនៅខាង

ក្រៅវិញ ដើម្បីរក្សាបាននូវសណ្តាប់ធ្នាប់ និងសោភ័ណភាពល្អប្រសើរ។ ក្នុងនោះសុវត្ថិភាពចំណីអាហារក៏ជាបញ្ហាប្រឈមមួយដែរ ដោយយើងគួររៀបចំត្រួតពិនិត្យ និងលើកកម្ពស់ទៅលើគុណភាពស្តង់ដាអនាម័យ និងចំណីអាហារក៏ដូចជាការលក់នៅក្នុងរមណីយដ្ឋាន ដើម្បីផ្តល់ជាទំនុកចិត្តដល់ទេសចរពេលមកកម្សាន្តនៅភ្នំកំពង់ត្រាច។

**នៅក្នុងល្អាង និងជុំវិញភ្នំ** សង្កេតឃើញថាមានសភាពស្ងាត់មិនមានអ្នកយាមល្បាតទេ ដូច្នេះ សូមផ្នែកពាក់ព័ន្ធទាំងអស់គួរគិតគូរ និងត្រូវពង្រឹងសន្តិសុខឲ្យបានល្អ ហើយរៀបចំឲ្យមានអ្នកយាម ល្បាតឲ្យបានគ្រប់គ្រាន់នៅជុំវិញភ្នំ ជាពិសេសក្នុងរូងភ្នំត្រូវតែមានអ្នកយាមល្បាតគ្រប់ពេលដែលមាន ទេសចរចូលទស្សនា ហើយគួរដើរត្រួតពិនិត្យជាប្រចាំជៀសវាងមានជនខិលខូចលាក់ខ្លួនក្នុងរូងភ្នំចង់ មានបំណងមិនល្អមកលើទេសចរ។

### ៣.៥ ការលើកទឹកចិត្តផ្នែកឯកជន និងអង្គការក្រៅរដ្ឋាភិបាល

ក្នុងការអភិវឌ្ឍតំបន់រមណីយដ្ឋានទេចរណ៍ គួរតែមានការលើកទឹកចិត្តដល់ផ្នែកឯកជន ឬអង្គការណាមួយឲ្យចូលរួមក្នុងការរៀបចំអភិវឌ្ឍន៍ដើម្បីឲ្យមានភាពល្អប្រសើរ និងរីកចំរើនកាន់តែខ្លាំងឡើងៗ។ ខាងក្រោមនេះជាពត៌មានដែលបានបង្ហាញថា តើមានផ្នែកឯកជន ឬអង្គការក្រៅរដ្ឋាភិបាលណាចូលរួមក្នុងការអភិវឌ្ឍរមណីយដ្ឋានភ្នំកំពង់ត្រាចឬទេ?

ក្រាហ្វិកទី១០. ផ្នែកឯកជន និងអង្គការក្រៅរដ្ឋាភិបាលដែលអភិវឌ្ឍន៍ភ្នំកំពង់ត្រាច




តាមរយៈការសម្ភាសជាមួយអាជ្ញាធរក្នុងតំបន់ និងប្រធានផែនការអភិវឌ្ឍទេសចរណ៍វប្បធម៌នៃខេត្តកំពតបានប្រាប់ឲ្យដឹងថា ក៏ធ្លាប់មានផ្នែកឯកជនដែលគេចង់មកអភិវឌ្ឍន៍ក្នុងតំបន់រមណីយដ្ឋាននេះដែរ ប៉ុន្តែក្នុងការចូលរួមអភិវឌ្ឍន៍នេះផងដែរ ត្រូវមានការកែច្នៃមួយចំនួនទើប

ក្រសួងទេសចរណ៍ និងប្រធានសហគមន៍ទេសចរណ៍ក្នុងតំបន់នោះមានការបដិសេធដោយមិនចង់ឲ្យមានការកែច្នៃអ្វីទេ ព្រោះចង់រក្សានូវភាពដើម និងសម្បត្តិធម្មជាតិដែលមានក្នុងរមណីយដ្ឋាននេះឲ្យនៅដដែល។ ទោះជាយ៉ាងណាក៏ផ្នែកឯកជន និងអង្គការក្រៅរដ្ឋាភិបាលគួរតែជួយគិតគូទៅលើបញ្ហាដូចជា៖

**ប្រព័ន្ធអគ្គីសនី** គួរតែមានការឧបត្ថម្ភ ឬការចំណាយទៅលើសេវានៃការប្រើប្រាស់អគ្គិសនីនៅក្នុងតំបន់រមណីយដ្ឋានផង ព្រោះថាគណកម្មការវត្តពុំមានលទ្ធភាពក្នុងការរ៉ាប់រងទៅលើការចំណាយទាំងស្រុងទេ ទើបជាហេតុបណ្តាលឲ្យមានការខ្វះខាតក្នុងការបំពាក់ភ្លើងបំភ្លឺនៅក្នុងរមណីយដ្ឋាននេះ។

**ឡានដឹកសំរាម** ជាធម្មតាសំរាម និងកាកសំណល់ផ្សេងៗគឺខាងអាជីវករបានប្រើរទេះ ដើម្បីដឹកសំរាមយកទៅដុតចោល ជួនកាលក៏អាចទុករយៈពេលយូររហូតដល់មានក្លិនមិនល្អ។ ដូច្នេះប្រសិនបើស្ថាប័ននានាមិនមានលទ្ធភាពក្នុងការរៀបចំឡានដឹកសំរាម គួរតែប្រគល់ឲ្យផ្នែកឯកជនឬអង្គការណាមួយឲ្យរៀបចំដើម្បីឲ្យមានភាពងាយស្រួលដល់ប្រជាពលរដ្ឋ និងអាជីវករ ជាពិសេសដើម្បីទាក់ទាញទេសចរដែលចូលមកទស្សនាកម្សាន្តបានឃើញថា រមណីយដ្ឋាននេះមានការរៀបចំបានស្អាតល្អ មានឡានដឹកសំរាមត្រឹមត្រូវធ្វើឲ្យបរិស្ថានជុំវិញនោះមានអនាម័យល្អ មិនមានការគរទុកសំរាមនៅតាមកន្លែងលក់ដូរ។

**បង្គន់អនាម័យ** តាមការចុះអង្កេតនៅរមណីយដ្ឋានមានការខ្វះខាតបង្គន់អនាម័យជាក់ស្តែងមានបង្គន់អនាម័យមិនមានគ្រប់គ្រាន់ទេ។ ដូច្នេះវាអាចមានការលំបាកនៅពេលដែលភ្ញៀវជាច្រើនត្រូវការប្រើប្រាស់បង្គន់អនាម័យ។ ប្រសិនបើរដ្ឋមិនអាចជួយបានត្រូវទាក់ទងទៅផ្នែកឯកជនណាមួយ ឬសប្បុរសជននានាដែលគាត់មានសមត្ថភាពធ្វើការវិនិយោគ ឬឧបត្ថម្ភទៅលើផ្នែកនេះដោយគិតលុយពេលដែលទេសចរប្រើប្រាស់សេវានេះ។

**ការបណ្តុះបណ្តាលផ្នែកម្ហូបអាហារ** ប្រសិនបើមន្ទីរទេសចរណ៍ ឬស្ថាប័នដែលជាប់ពាក់ព័ន្ធមិនមានអ្នកជំនាញបណ្តុះបណ្តាលផ្នែកម្ហូបអាហារទេ គួរតែទាក់ទងទៅអង្គការ ឬឯកជនណាមួយតាមសណ្ឋាគារឲ្យជួយបង្រៀនដល់អាជីវករដែលប្រកបរបរនៅទីនោះ ឲ្យមានជំនាញច្បាស់លាស់ក្នុងការច្នៃប្រឌិតអាហារឲ្យមានភាពទាក់ទាញដល់ទេសចរជាតិ និងអន្តរជាតិ។

**ការបណ្តុះបណ្តាលផ្នែកមគ្គុទេសក៍** តាមការចុះអង្កេតនៅរមណីយដ្ឋាន គឺគ្មានមគ្គុទេសក៍ដែលមានជំនាញច្បាស់លាស់ទ មានតែក្មេងៗនៅទីនោះទេដែលធ្វើជាមគ្គុទេសក៍ និងនាំផ្លូវភ្ញៀវចូលទស្សនានៅតាមល្អាងនីមួយៗ ក៏ដូចជានិយាយរៀបរាប់ពីប្រវត្តិនៃល្អាងផងដែរ។ ដូច្នេះបើខាង

មន្ទីរទេសចរណ៍មិនមានមគ្គុទេសក៏ក្នុងតំបន់នោះទេ គួរតែទាក់ទងទៅផ្នែកឯកជនណាមួយឲ្យមកបណ្តុះបណ្តាលក្មេងៗបន្ថែមទៀត ឬក៏រកមគ្គុទេសក៏មួយនៅប្រចាំតំបន់នោះតែម្តង។

## ៣.៦ បង្កើនការផ្សព្វផ្សាយ

ការផ្សព្វផ្សាយមានសារៈប្រយោជន៍ ក្នុងការទាក់ទាញទេសចរឲ្យស្គាល់ពីរមណីយដ្ឋាននេះ ហើយយើងអាចបង្ហាញពីសក្តានុពល និងផលិតផលនៃរមណីយដ្ឋានបាន។ ដោយយោងទៅតាមជំពូក ទី១ និយាយពីបទពិសោធន៍បរទេសក្នុងការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៅក្នុងនោះមានប្រទេសឥណ្ឌា ម៉ាឡេស៊ី និងប្រទេសហ្វីលីពីន គេបានលើកកម្ពស់លើការផ្សព្វផ្សាយ ដើម្បីទាក់ទាញទេសចរឲ្យស្គាល់ពីតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រជាច្រើនដូច្នេះយើងឃើញថាការផ្សព្វផ្សាយពិតជាមានសារៈប្រយោជន៍ណាស់។

ក្រាហ្វិកទី១១. បណ្តាញដែលទេសចរស្គាល់រមណីយដ្ឋាន




យោងតាមការសម្ភាស និងការសាកសួរពីទេសចរដែលស្គាល់រមណីយដ្ឋានភ្នំកំពង់ត្រាចគឺភាគច្រើនស្គាល់តាមរយៈមិត្តភក្តិ រីឯការផ្សព្វផ្សាយរបស់ក្រសួងដែលពាក់ព័ន្ធមិនសូវមានប្រសិទ្ធភាពទេ។ ដូច្នេះហើយ សូមខាងស្ថាប័នក្រសួងមន្ទីរទេសចរណ៍ និងផ្នែកដែលជាប់ពាក់ព័ន្ធទាំងអស់គួរតែបង្កើនការផ្សព្វផ្សាយឲ្យបានច្រើន និងកាន់តែខ្លាំងជាងនេះទៀត ដើម្បីឲ្យមានកំណើនទេសចរមកកម្សាន្តនៅរមណីយដ្ឋាននេះ។ ក្នុងនោះយើងអាចធ្វើការផ្សព្វផ្សាយតាមរយៈប្រព័ន្ធដូចខាងក្រោម៖

**ទស្សនាវដ្តី** ជាផ្នែកមួយដែលសំខាន់សម្រាប់អ្នកដែលអ្នកចូលចិត្តអានទស្សនាវដ្តីច្រើន គ្រាន់តែសរសេរជាអត្ថបទខ្លីៗនិយាយពីភាពទាក់ទាញ ការបម្រើសេវាកម្ម និងរូបភាពកន្លែងរមណីយដ្ឋាន។

**ទូរទស្សន៍** មនុស្សគ្រប់គ្នាតែងតែមើលទូរទស្សន៍នៅពេលទំនេរ ដូច្នេះយើងអាចរៀបចំជាពាណិជ្ជកម្មខ្លីៗ និយាយរៀបរាប់ពីសេវាកម្ម និងផលិតផលដែលរមណីយដ្ឋានមាន។

**សណ្ឋាគារ** ជាកន្លែងដែលទេសចរចូលច្រើន ដូច្នេះខាងមន្ទីរទេសចរណ៍ ឬស្ថាប័នដែលពាក់ព័ន្ធអាចរៀបចំជាសៀវភៅឯកសារតូចមួយដែលនិយាយពីផលិតផល និងសេវាកម្មក្នុងរមណីយដ្ឋានទុកនៅតាមសណ្ឋាគារបាន។

**ក្រុមហ៊ុនទេសចរណ៍** ជាកន្លែងដែលលក់នូវកញ្ចប់សេវាកម្មទេសចរណ៍ទៅកាន់ទេសចរជាតិ និងអន្តរជាតិ ដូច្នេះមន្ទីរទេសចរណ៍ក៏ដូចជាផ្នែកពាក់ព័ន្ធអាចធ្វើការទាក់ទងទៅក្រុមហ៊ុនទេសចរណ៍ប្រាប់ពីភាពទាក់ទាញព្រមទាំងផលិតផល និងសេវាកម្មដែលមាននៅក្នុងរមណីយដ្ឋានផងដែរ។

**ប្រព័ន្ធអ៊ីនធើណិត** ជាប្រព័ន្ធមួយដែលសព្វថ្ងៃនេះ គេនិយមប្រើរាល់ថ្ងៃក្នុងប្រទេសកម្ពុជាគឺបណ្តាញសង្គម Facebook។ ប្រព័ន្ធនេះអាចធ្វើការចែកចាយពត៌មានថ្មីភ្លាមៗបាន ដូច្នេះនៅពេលមានព្រឹត្តការណ៍ទេសចរណ៍ ឬកម្មវិធីដែលបានរៀបចំឡើងក្នុងតំបន់ទេសចរណ៍ យើងអាចដាក់បញ្ចូលតាមប្រព័ន្ធនេះបានយ៉ាងងាយស្រួល។ យើងអាចរៀបចំនូវពត៌មានថ្មីៗដែលជាសារៈប្រយោជន៍ដល់រមណីយដ្ឋាននេះជាឯកសារវីដេអូ កម្រងរូបភាព អំពីសេវាកម្ម ភាពទាក់ទាញ និងផលិតផលផ្សេងទៀតតាមរយៈគេហទំព័រ Facebook ឬប្រព័ន្ធវេបសាយរបស់ក្រសួងទេសចរណ៍។

ម្យ៉ាងវិញទៀត ខាងមន្ទីរទេសចរណ៍គួរដាក់បញ្ចូលអំពីភាពទាក់ទាញនៃរមណីយដ្ឋាននេះទៅក្នុងខិតប័ណ្ណផ្សព្វផ្សាយ នៅពេលមានព្រឹត្តិការណ៍បុណ្យសំខាន់ៗដូចជា បុណ្យសមុទ្រ បុណ្យទន្លេជាដើម។ រាល់ការផ្សព្វផ្សាយទាំងអស់ សុទ្ធតែមានសារៈប្រយោជន៍ដល់ការអភិវឌ្ឍទេសចរណ៍នៅក្នុងតំបន់ និងជួយបង្កើនការងារដល់ប្រជាពលរដ្ឋផងដែរ។

## ៣.៧ ការរៀបចំព្រឹត្តិការណ៍ និងសេវាកម្មទេសចរណ៍

យោងតាមការសង្កេតឃើញជាក់ស្តែង នៅរមណីយដ្ឋានភ្នំកំពង់ត្រាចមានភាពទាក់ទាញដែលបម្រើដល់វិស័យទេសចរណ៍ជាច្រើនដូចជាការចូលទស្សនាក្នុងរូងភ្នំ ការស្វែងយល់ពីប្រវត្តិនៃភ្នំ និងរូងភ្នំនីមួយៗ មើលសត្វស្វា អង្គុយលេងក្រោមដើមឈើ និងមានសេវាបម្រើម្ហូបអាហារខ្លះផងដែរ។ ប៉ុន្តែវានៅមិនទាន់គ្រប់គ្រាន់នៅឡើយទេសម្រាប់បំពេញសេចក្តីត្រូវការរបស់ទេសចរ។

ដូច្នេះយើងគួរគប្បីបង្កើតជាព្រឹត្តិការណ៍ផ្សេងៗ និងសេវាកម្មថ្មីៗបន្ថែមទៀតដើម្បីជាភាពទាក់ទាញ បង្កើននូវកំណើនទេសចរ ហើយប្រជាជននឹងមានការងារ មានប្រាក់ចំណូលនោះជីវភាពរបស់ពួកគាត់កាន់តែធូរធារជាងមុន ។ យើងត្រូវរៀបចំបង្កើតឲ្យមានព្រឹត្តិការណ៍ និងសេវាកម្មដូចជា៖

**បុណ្យពិសាខបូជា និងបុណ្យមាឃបូជា** តាមការស្រាវជ្រាវក៏ដូចជាការចុះអង្កេត និងសម្ភាសជាមួយទេសចរ អាជីវករ និងអាជ្ញាធរដែនដី ពួកគាត់ក៏មានការចាប់អារម្មណ៍ដែរ ប្រសិនបើមន្ទីរទេសចរណ៍ និងស្ថាប័នដែលពាក់ព័ន្ធបានរៀបចំឲ្យមានព្រឹត្តិការណ៍ផ្សេងៗ ដើម្បីបង្កើនភាពទាក់ទាញនោះនឹងមានទេសចរកាន់តែច្រើនមកកម្សាន្តកាន់តែច្រើន ដែលធ្វើឲ្យប្រជាពលរដ្ឋទទួលបានចំណូលបន្ថែមទៀត។

**ការជិះកង់** គឺជាសកម្មភាពទេសចរណ៍មួយដែលធ្វើឲ្យមានសុខភាពល្អប្រៀបបានដូចជាការហាត់ប្រាណ ហើយកង់ដែលជារបស់ប្រជាពលរដ្ឋ ឬអាជីវករ ពួកគាត់អាចយកមកជួលឲ្យទេសចរជិះកម្សាន្តបាន។

**សិប្បកម្មធ្វើវត្ថុអនុស្សាវរីយ៍** គួរតែបង្កើតជាការបណ្តុះបណ្តាលដល់ប្រជាពលរដ្ឋពីរបៀបធ្វើវត្ថុអនុស្សាវរីយ៍ផ្សេងៗ ដែលអាចជួយឲ្យពួកគាត់មានមុខរបរ និងទទួលបានប្រាក់កម្រៃបន្ថែមទៀតព្រមទាំងគួរបង្កើតជាសហគមន៍សិប្បកម្មមួយផងដែរ។

**ផ្ទះស្នាក់ទេសចរណ៍** គួរតែរៀបចំឲ្យមានផ្ទះស្នាក់នេះឡើងនៅតាមផ្ទះរបស់ប្រជាពលរដ្ឋដែលវាជាផ្នែកមួយទាក់ទាញទេសចរអន្តរជាតិឲ្យមកស្នាក់នៅ ដោយសារតែទេសចរអន្តរជាតិភាគច្រើនចង់ដឹងពីការរស់នៅ វប្បធម៌ និងទំនៀមទម្លាប់ប្រពៃណីរបស់ប្រជាជនក្នុងតំបន់ដែលគេបានទៅដល់។ ទេសចរអាចស្នាក់នៅ ហើយរៀនសូត្រពីការធ្វើកសិកម្ម និងអ្វីផ្សេងៗទៀត។ ក្នុងនោះក៏អាចជួយផ្តល់ជាមុខរបរ រកប្រាក់ចំណូល និងការច្នៃប្រឌិតបន្ថែមទៀតក្នុងការរៀបចំផ្ទះសម្បែងឲ្យកាន់តែមានភាពទាក់ទាញ។

ម្យ៉ាងវិញទៀត **ការឡើងភ្នំ** ក៏ជាសកម្មភាពទេសចរណ៍បែបកីឡាដែលមានប្រជាប្រិយភាពក្នុងពិភពលោកនាពេលបច្ចុប្បន្ននេះ ដូចនេះគួរតែមានការរៀបចំ និងសហការណ៍ជាមួយផ្នែកជំនាញ ឬបើកឲ្យអ្នកវិនិយោគធ្វើការចំណាយ និងរៀបចំទៅលើសេវាកម្មទេសចរណ៍បែបកីឡាមួយនេះ ដើម្បីជាភាពទាក់ទាញមួយផ្នែកទៀតដល់ទេសចរ។

# សេចក្តីសន្និដ្ឋាន
# និងការផ្តល់អនុសាសន៍

# សេចក្ដីសន្និដ្ឋាន និងការផ្ដល់អនុសាសន៍

ឆ្លងតាមការសិក្សាស្រាវជ្រាវ យ៉ាងយកចិត្តទុកដាក់ទៅលើការរំលឹកទ្រឹស្ដី ជាពិសេសការចុះដោយផ្ទាល់ទៅតំបន់រមណីយដ្ឋានភ្នំកំពង់ត្រាច ដើម្បីស្រាវជ្រាវរកពត៌មានមួយចំនួនដែលជាប់ពាក់ព័ន្ធទៅនឹងប្រធានបទដែនកំណត់នៃការស្រាវជ្រាវ ដោយសិក្សាទៅលើធនធានទេសចរណ៍ក្នុងតំបន់ការអភិវឌ្ឍលើផ្នែកហេដ្ឋារចនាសម្ព័ន្ធ សេវាកម្មសាធារណៈ បរិស្ថាន ទីផ្សារទេសចរ ការផ្សព្វផ្សាយ សន្តិសុខ និងសុវត្ថិភាពក្នុងតំបន់។ ការបង្ហាញជូនពីស្ថានភាពទូទៅនៃរមណីយដ្ឋានភ្នំកំពង់ត្រាចនៅក្នុងជំពូកទី២ និងទស្សនទានក្នុងការអភិវឌ្ឍរមណីយដ្ឋានភ្នំកំពង់ត្រាច ខេត្តកំពត ក្រោយមកយើងបានធ្វើការវិភាគទៅលើផ្នែកបរិមាណវិស័យ និងគុណវិស័យ ដើម្បីឆ្លុះបញ្ចាំងលើអំណះអំណាង។

រមណីយដ្ឋានភ្នំកំពង់ត្រាច ជារមណីយដ្ឋានដែលសម្បូរទៅដោយធនធានធម្មជាតិ វប្បធម៌ និងប្រវត្តិសាស្ត្រជាច្រើនដែលបម្រើឲ្យវិស័យទេសចរណ៍ ដើម្បីទាក់ទាញទាំងភ្ញៀវជាតិ និងអន្តរជាតិក៏ដូចជាអ្នកវិនិយោគធ្វើការអភិវឌ្ឍរមណីយដ្ឋាននេះឲ្យមានភាពរីកចម្រើន។ យ៉ាងណាមិញ ការអភិវឌ្ឍគឺផ្ដោតទៅលើការយកចិត្តទុកដាក់ដែលប្រកបដោយនិរន្តរភាព ក៏ដូចជាធ្វើឲ្យជីវភាពប្រជាពលរដ្ឋមានការកើនឡើង។ យើងឃើញថា សកម្មភាពនៃការអភិវឌ្ឍទេសចរណ៍នៅក្នុងរមណីយដ្ឋានភ្នំកំពង់ត្រាច បាននាំមកនូវអត្ថប្រយោជន៍ជាច្រើនជូនប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ ការផ្ដល់នូវចំណេះដឹងជំនាញថ្មីៗ ឱកាសការងារនៅក្នុងវិស័យទេសចរណ៍ដែលមានដូចជាការលក់ម្ហូបអាហារ និងការណែនាំភ្ញៀវឲ្យដឹងពីប្រវត្តិនៃភ្នំកំពង់ត្រាច ហើយគួរលើកទឹកចិត្តប្រជាពលរដ្ឋឲ្យមានការធ្វើសិប្បកម្មដោយដៃសម្រាប់លក់ជាវត្ថុអនុស្សាវរីយ៍។ បើទោះបីជាធនធានធម្មជាតិមួយចំនួនដូចជា ដើមឈើកំពុងតែមានការប្រឈមទៅនឹងការបំផ្លាញដោយប្រជាពលរដ្ឋក៏ដោយ ខាងប្រធានសហគមន៍ព្រៃឈើកំពុងតែធ្វើការយកចិត្តទុកដាក់ទៅលើការអភិរក្ស ដូច្នេះរមណីយដ្ឋាននេះ នៅតែមានឱកាសច្រើនក្នុងការអភិវឌ្ឍឲ្យទៅជាតំបន់ដែលមានសកម្មភាពទេសចរណ៍។ ប៉ុន្តែដោយសារតែមានការខ្វះចន្លោះនៅក្នុងតំបន់ដែលមិនមាននូវសេវាស្នាក់នៅ និងព្រឹត្តិការណ៍ទេសចរណ៍ផ្សេងៗ ជាហេតុធ្វើឲ្យផលប្រយោជន៍ដែលប្រជាជនទទួលបានពីទេសចរនៅមានកម្រិតដោយសារតែការកម្សាន្តរបស់ទេសចរមានរយៈពេលខ្លី។

## ១. សេចក្តីសន្និដ្ឋាន

សរុបមក ទោះបីជារមណីយដ្ឋានភ្នំកំពង់ត្រាចនេះមានភាពទាក់ទាញភ្ញៀវជាតិ និងអន្តរជាតិមកទស្សនាច្រើនក៏ដោយ ក៏តំបន់នេះត្រូវការពង្រឹង និងអភិវឌ្ឍន៍បន្ថែមទៅលើចំណុចខ្វះខាតមួយចំនួនដូចជាសេវាហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈ ការបណ្តុះបណ្តាលផ្នែកសេវាម្ហូបអាហារ និងភេសជ្ជៈ គ្រប់គ្រងបរិស្ថាន និងអនាម័យ ពង្រឹងផ្នែកសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ ការលើកទឹកចិត្តពីឯកជន និងអង្គការក្រៅរដ្ឋាភិបាល បង្កើនការផ្សព្វផ្សាយ និងបង្កើតផលិតផលទេសចរណ៍ក៏ដូចជាព្រឹត្តិការណ៍ទេសចរណ៍ ដើម្បីឲ្យមានចំនួនទេសចរកាន់តែកើនឡើង។ ម្យ៉ាងទៀត តំបន់នេះត្រូវរៀបចំឲ្យបានប្រសើរលើផ្នែកអប់រំនិងមណ្ឌលសុខភាពនៅក្នុងតំបន់ផ្ទាល់ ដើម្បីសម្រួលដល់ទេសចរក៏ដូចជាលើកស្ទួយនូវស្តង់ដានៃការរស់នៅរបស់ប្រជាជនឲ្យមានគុណភាព និងផាសុកភាព។ លើសពីនេះទៅទៀត ការរៀបចំអភិវឌ្ឍន៍ទេសចរណ៍នៅរមណីយដ្ឋានភ្នំកំពង់ត្រាចប្រកបដោយនិរន្តរភាព គឺត្រូវធានាឲ្យបាននូវនិរន្តរភាព បរិស្ថានធនធានធម្មជាតិ និងធនធានផ្សេងៗដោយជៀសវាងផលអវិជ្ជមានទៅលើធនធានទាំងនោះដែលធ្វើឲ្យបាត់បង់ធនធានធម្មជាតិ វប្បធម៌ និងប្រវត្តិសាស្ត្រដោយសារការប្រើប្រាស់ធនធានលើសកម្រិត។

## ២. ការផ្តល់អនុសាសន៍

ការផ្តល់អនុសាសន៍ខាងក្រោមនេះ គឺគ្រាន់តែជាការចូលរួមចំណែកក្នុងការផ្តល់ជាមតិមួយចំនួនបន្ទាប់ពីបានធ្វើការស្រាវជ្រាវជាមួយនឹងអាជីវករ មន្ទីរទេសចរណ៍ខេត្តកំពត និងប្រធានសហគមន៍ទេសចរណ៍ ស្រុកកំពង់ត្រាចលើផ្នែកអភិវឌ្ឍន៍ទេសចរណ៍វប្បធម៌ និងប្រវត្តិសាស្ត្រនៅរមណីយដ្ឋានភ្នំកំពង់ត្រាចក្នុងជំពូកទី៣ ហើយសង្ឃឹមថាវាជាទុនមួយក្នុងការរួមចំណែកកែលម្អនូវបញ្ហាប្រឈមមួយចំនួនក្នុងសកម្មភាពអភិវឌ្ឍន៍រមណីយដ្ឋានភ្នំកំពង់ត្រាច ខេត្តកំពតប្រកបដោយនិរន្តរភាព។

- ផ្លូវចូលទៅកាន់រមណីយដ្ឋាន គួរតែផ្តល់ឲ្យផ្នែកឯកជនណាមួយធ្វើការអភិវឌ្ឍជាបន្ទាន់ដើម្បីជាភាពងាយស្រួលសម្រាប់ទេសចរដែលទៅកម្សាន្តនៅទីនោះ
- ក្រសួងទេសចរណ៍ និងស្ថាប័នពាក់ព័ន្ធ គួរតែចូលរួមបណ្តុះបណ្តាលអាជីវករក្នុងតំបន់ឲ្យបានញឹកញាប់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ទេសចរ និងក្នុងខេត្តទាំងមូល ក៏ដូចជាយកចិត្តទុកដាក់គិតគូរដល់ការអប់រំបណ្តុះបណ្តាលជំនាញមគ្គុទេសក៍ទេសចរណ៍ ផ្នែកម្ហូបអាហារ និងលើកកម្ពស់គុណភាពសេវាកម្មទេសចរណ៍នៅតំបន់នោះឲ្យបានល្អ

- ក្រសួងបរិស្ថាន និអាជ្ញាធរដែនដី គួរតែចាត់វិធានការណ៍ណែនាំអប់រំអាជីវករក្នុងតំបន់ ឲ្យយល់ពីការថែរក្សាអនាម័យ និងទុបស្កាត់ការបោះចោលសំរាម កាកសំណល់នានានៅតាមទីបរិវេណរមណីយដ្ឋានដែលជាហេតុធ្វើឲ្យខូចបរិស្ថាន និងមានក្លិនមិនល្អ។

# ឯកសារយោង

# ឯកសារយោង

❖ **ឯកសារយោងជាភាសាខ្មែរ**


ក្រសួងទេសចរណ៍, *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ ២០១២-២០២០*, ថ្ងៃទី២០ កក្កដា ២០១២, ១៣

វចនានុក្រម "Oxford Learner's Pocket Dictionary"

ហុង វណ្ណៈ ជា ស៊ីថា និងសហការី ,សេចក្តីផ្តើមទេសចរណ៍ (ភ្នំពេញ:១០ តុលា ២០១៤), ៥៥

ក្រសួងទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា ,ច្បាប់ស្តីពីទេសចរណ៍ (ក្នុងឧបសម្ព័ន), ៣១

ហុង វណ្ណៈ ជា ស៊ីថា និងសហការី ,សេចក្តីផ្តើមទេសចរណ៍ (ភ្នំពេញ:០១ តុលា ២០១៤), ៨៧

ហុង វណ្ណៈ ជា ស៊ីថា និងសហការី ,សេចក្តីផ្តើមទេសចរណ៍, (ភ្នំពេញះ០១ តុលា ២០១៤), ៩១

ហុង វណ្ណៈ ជា ស៊ីថា និងសហការី ,សេចក្តីផ្តើមទេសចរណ៍, (ភ្នំពេញះ០១ តុលា ២០១៤), ៩៣

ហុង វណ្ណៈ និងឈឹម ផាន់ណា, ការអភិវឌ្ឍ និងផែនការទេសចរណ៍,(ភ្នំពេញះ ឆ្នាំ២០១៦), ៩

វចនានុក្រម សម្តេចសង្ឃរាជ ជួន ណាត), ឆ្នាំ២០០៩

ហុង វណ្ណៈ និងឈុន ពហុ, អេកូទេសចរណ៍, ឯកសាបង្រៀននៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ,(ភ្នំពេញ), ២០១៤, ៨០

ហុង វណ្ណៈ និងឈឹម ផាន់ណា "ការអភិវឌ្ឍ និងផែនការទេសចរណ៍",ភ្នំពេញ, ៨

សួន វ៉ានី និងហុង វណ្ណៈ "និរន្តភាពការអភិវឌ្ឍទេសចរណ៍" ទំព័រ ៨៥

ហុង វណ្ណៈ និងឈឹម ផាន់ណា "ការអភិវឌ្ឍ និងផែនការទេសចរណ៍" ទំព័រ១៤៨

មន្ទីរទេសចរណ៍ខេត្តកំពត, *ប្រវត្តិសង្ខេបខេត្តកំពត* (កំពតះ មន្ទីរទេសចរណ៍ខេត្តកំពត, ២០១៧), ១៦

មន្ទីរទេសចរណ៍ខេត្តកំពត, *ប្រវត្តិសង្ខេបខេត្តកំពត* (កំពតះ មន្ទីរទេសចរណ៍ខេត្តកំពត, ២០១៧), ១៥

ក្រសួងទេសចរណ៍កម្ពុជា, *ទស្សនាខេត្តទាំង ៤នៃដែនសមុទ្រ* (កំពតះ ២០១៦), ៣៥

ក្រសួងទេសចរណ៍កម្ពុជា, *ទស្សនាខេត្តទាំង ៤នៃដែនសមុទ្រ* (កំពតះ ២០១៦), ៣០

មន្ទីរទេសចរណ៍ខេត្តកំពត, *ប្រវត្តិ និងលក្ខណៈភូមិសាស្ត្ររមណីយដ្ឋានទេសចរណ៍ភ្នំកំពង់ត្រាច* (កំពតះ មន្ទីរទេសចរណ៍ខេត្តកំពត, ២០១៧), ១

មន្ទីរទេសចរណ៍ខេត្តកំពត, *ប្រវត្តិ និងលក្ខណៈភូមិសាស្ត្ររមណីយដ្ឋានទេសចរណ៍ភ្នំកំពង់ត្រាច* (កំពត៖ មន្ទីរទេសចរណ៍ខេត្តកំពត, ២០១៧), ៣

- **ឯកសារយោងជាភាសាបរទេស**

http://statistics.unwto.org/publication/yearbook-tourism-statistics-2017-edition ចូលទស្សនាថ្ងៃទី១២ កក្កដា ឆ្នាំ២០១៧

http://www.tourismcambodia.org/mot/index.php?view=statistic_report ចូលទស្សនាថ្ងៃទី២២ ឧសភា ឆ្នាំ២០១៧

https://www.slideshare.net/GlyGly1/domestic-tourism-64202191 ចូលទស្សនាថ្ងៃទី២៥ មិថុនា ឆ្នាំ២០១៧

www.sesric.org/imgs/news/File/1050-presentations/sudan.pdf ចូលទស្សនាថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៧

http://www.stat.fi/meta/kas/ulkommatkailu_en.html ចូលទស្សនាថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០១៧

https://www.slideshare.net/sabinjoseph2/tourism-43551540 ចូលទស្សនាថ្ងៃទី ២១ ឧសភា ឆ្នាំ ២០១៧

http://www.shtourism.eu/social-tourism.html ចូលទស្សនាថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៧

http://dictionary.cambridge.org/dictionary/english/development ចូលទស្សនាថ្ងៃទី២០ ឧសភា ២០១៧

United National World Tourism Organization "Sustainable Tourism Development", ២០

John H. Stubbs, Robert G. Thomson, Architectural Conservation in Asia: National Experiences and Practice (India៖ India, ២០១៦), ៣៦៦, https://books.google.com/books?isbn=1317406192 (ចូលទស្សនាថ្ងៃទី១០ ឧសភា ២០១៧)

Peter Gould, K. Anne Pyburn ,Collision or Collaboration: Archaeology Encounters Economic Development (Philippines៖ Philippines, ២០១៦), ៩៣ ៩៥ , https://books.google.com/books?isbn=3319445154 (ចូលទស្សនាថ្ងៃទី១៣ ឧសភា ឆ្នាំ២០១៧)

https://en.wikipedia.org/wiki/Batu_Caves ចូលទស្សនាថ្ងៃទី១៧ កក្កដា ឆ្នាំ២០១៧

http://kampot.cambodia.gov.kh ចូលទស្សនាថ្ងៃទី១៣ ឧសភា ឆ្នាំ២០១៧

http://kampot.cambodia.gov.kh/linedepartment/ ចូលទស្សនាថ្ងៃទី៣ កក្កដា ឆ្នាំ២០១៧

https://en.wikipedia.org/wiki/Bokor_Hill_Station ចូលទស្សនាថ្ងៃទី១៣ ឧសភា ឆ្នាំ២០១៧

http://www.tourismcambodia.com/activities/community-based-tourism-cbt/prek-thnout-community-based-ecotourism-site.htm ចូលទស្សនាថ្ងៃទី១៨ ឧសភា ឆ្នាំ២០១៧

http://www.natayaresort.com/resort-overview ចូលទស្សនាថ្ងៃទី១៨ ឧសភា ឆ្នាំ២០១៧

https://www.realestate.com.kh/news/kampot/ ចូលទស្សនាថ្ងៃទី២០ កក្កដា ឆ្នាំ២០១៧

http://mekongcrane.com/accommodation/ ចូលទស្សនាថ្ងៃទី១៥ កក្កដា ឆ្នាំ២០១៧

http://www.terrafirmatourist.com/caves-of-kampong-trach-kampot-caves/ ចូលទស្សនាថ្ងៃទី១៥ កក្កដា ឆ្នាំ២០១៧

Johannessburg, ***Tourism and Sustainability***, 2002, USA, P3 ចូលទស្សនាថ្ងៃទី១២ ខែកក្កដា ឆ្នាំ ២០១៧

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១ ៖ កម្រងសំណួរ

## កម្រងសំណួរសម្រាប់ទេសចរ

ស្ដីអំពី ការអភិវឌ្ឍរមណីយដ្ឋានទេសចរណ៍ប្រកបដោយនិរន្តរភាព

ករណីសិក្សារមណីយដ្ឋានភ្នំកំពង់ត្រាច (ខេត្តកំពត)

យើងខ្ញុំទាំងអស់គ្នា សូមជម្រាបសួរអស់លោក លោកស្រី អ្នកនាង កញ្ញាជាទីរាប់អាន។ ក្នុងនាមខ្ញុំជាក្រុមសិក្សាស្រាវជ្រាវទាំងពីរនាក់ជានិស្សិតផ្នែកថ្នាក់បរិញ្ញាបត្រ ឆ្នាំទី៤ ជំនាន់ទី ៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ថ្ងៃនេះយើងខ្ញុំសុំការអនុញ្ញាតពីលោក លោកស្រី អ្នកនាង កញ្ញា មេត្តាជួយចំណាយពេលវេលាដ៏មានតម្លៃរបស់លោកអ្នក ដើម្បីឆ្លើយនឹងសំណួររបស់យើងខ្ញុំ ក្នុងគោលបំណងយកពត៌មានដែលប្រមូលបានមកសរសេរជាសារណាបញ្ចប់ការសិក្សា។

យើងខ្ញុំសង្ឃឹមថាលោកអ្នកទាំងអស់គ្នា និងផ្ដល់ឱកាសក្នុងការចូលរួមឆ្លើយនឹងកម្រងសំណួរនេះ។

១. ចូរលោកអ្នកគូសសញ្ញា ✓ ក្នុងប្រអប់ ជាចំលើយរបស់លោកអ្នក។

២. សូមបំពេញបន្ថែមត្រង់....................តាមគំនិតរបស់អ្នក។

**ក. ព័ត៌មានផ្ទាល់ខ្លួន**

១. សញ្ជាតិ .........................

២. ភេទ ☐ ប្រុស ☐ ស្រី

៣. មុខរបរ ☐ សិស្ស និងនិស្សិត ☐ មន្ត្រីរាជការ ☐ អាជីវករ ☐ បុគ្គលិកក្រុមហ៊ុនផ្សេងៗ

**ខ. ការសម្ភាសជាមួយទេសចរ**

៤. តើអ្នកមកទស្សនាកម្សាន្តរមណីយដ្ឋានភ្នំកំពង់ត្រាចបានប៉ុន្មានដងហើយ?

☐ មួយដង ☐ ពីរដង ☐ បីដង ☐ លើសពីបីដង

៥. តើអ្នកអញ្ជើញមកទស្សនារមណីយដ្ឋាននេះក្នុងគោលបំណងអ្វី?ទស្សនាកម្សាន្ត?

☐ ជួបជុំមិត្តភក្តិ ☐ គ្រួសារ ☐ ទស្សនៈកិច្ច ☐ ស្រាវជ្រាវ

៦. តើអ្នកស្គាល់រមណីយដ្ឋាននេះតាមរយៈអ្វី?

☐ ទូរទស្សន៍ ☐ កាសែត ☐ ទស្សនាវដ្ដី ☐ មិត្តភក្តិ

៧. តើអ្នកយល់យ៉ាងណាចំពោះការទុកដាក់កាកសំណល់របស់អាជីវករ?

☐ ល្អ ☐ មធ្យម ☐ មិនល្អ

៨. តើអ្នកគិតថារមណីយដ្ឋាននេះមានបង្គន់ប្រើប្រាស់គ្រប់គ្រាន់ហើយ ឬនៅ?

☐ គ្រប់គ្រាន់ ☐ មិនទាន់គ្រប់គ្រាន់

៩. តើអ្នកសង្កេតឃើញមានធុងសំរាមគ្រប់គ្រាន់ដែរ ឬទេក្នុងរមណីយដ្ឋាននេះ?

☐ គ្រប់គ្រាន់ ☐ មិនទាន់គ្រប់គ្រាន់

១០. តើការបម្រើសេវាកម្មទេសចរណ៍ចំពោះទេសចររបស់អាជីវកម្មមានលក្ខណៈបែបណា?

☐ គ្រប់គ្រាន់ ☐ មិនទាន់គ្រប់គ្រាន់

១១. តើការផ្គត់ផ្គង់ម្ហូបអាហារសម្រាប់ទេសចរគ្រប់គ្រន់សម្រាប់តម្រូវការដែរ ឬទេ?

☐ គ្រប់គ្រាន់ ☐ សមរម្យ ☐ មិនទាន់គ្រប់គ្រាន់

១២. តើការរៀបចំអាហាររបស់អាជីវករមានលក្ខណៈបែបណា?

☐ ល្អ ☐ មធ្យម ☐ មិនល្អ

១៣. តើអ្នកយល់យ៉ាងណាចំពោះសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ក្នុងរមណីយដ្ឋាននេះ?

☐ ល្អ ☐ មធ្យម ☐ មិនល្អ ☐ គួរពង្រឹងបន្ថែម

១៤. តើអ្នកយល់ថា គួរអភិវឌ្ឍន៍អ្វីខ្លះក្នុងរមណីយដ្ឋានភ្នំកំពង់ត្រាច? (ចម្លើយអាចលើសពីមួយ)

☐ ហេដ្ឋារចនាសម្ព័ន្ធ ☐ សេវាសាធារណៈ ☐ បរិស្ថាន អនាម័យ

☐ សេវាកម្មម្ហូបអាហារ ☐ សន្តិសុខ សណ្តាប់ធ្នាប់ ☐ ទាំងអស់ខាងលើ

**គ. ព័ត៌មានទាក់ទងនឹងអាជីវករក្នុងតំបន់**

១៥. តើក្នុងតំបន់រមណីដ្ឋាននេះមានប្រព័ន្ធទឹកស្អាតប្រើប្រាស់គ្រប់គ្រាន់ដែរ ឬទេ?

☐ គ្រប់គ្រាន់ ☐ មិនទាន់គ្រប់គ្រាន់

១៦. តើក្នុងតំបន់រមណីយដ្ឋាននេះមានប្រព័ន្ធអគ្គីសនីប្រើប្រាស់គ្រប់គ្រាន់ដែរ ឬទេ?

☐ គ្រប់គ្រាន់ ☐ មិនគ្រប់គ្រាន់ទេ

១៧. តើអ្នកចេះពីរបៀបចម្អិនអាហារតាមរយៈអ្វី?

☐ តាមរយៈគ្រួសារ ☐ តាមរយៈការបណ្តុះបណ្តាល

១៨. តើគ្រឿងផ្សំដែលអ្នកយកមកប្រើប្រាស់ក្នុងការធ្វើម្ហូបមានប្រភពកមពីណា?

☐ ទិញមកពីផ្សារ ☐ ផលិតខ្លួនឯង ☐ ផលិតនៅក្នុងភូមិ

១៩. តើស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមានដែលចុះធ្វើការបណ្តុះបណ្តាលអំពីសេវាកម្មទេសចរណ៍ក្នុងតំបន់រមណីយដ្ឋានដែរ ឬទេ?

☐ ចុះមកញឹកញាប់ ☐ មិនសូវមានទេ ☐ មិនដែលចុះមកទេ

២០. តើអ្នកចង់ឲ្យមានការអភិវឌ្ឍទៅលើផ្នែកណាខ្លះនៅក្នុងតំបន់រមណីយដ្ឋានភ្នំកំពង់ត្រាចនេះ?

☐ ហេដ្ឋារចនាសម្ព័ន្ធ ☐ សេវាសាធារណៈ ☐ បរិស្ថាន អនាម័យ

☐ សេវាកម្មម្ហូបអាហារ ☐ សន្តិសុខ សណ្តាប់ធ្នាប់ ☐ ទាំងអស់ខាងលើ

**ឃ. ព័ត៌មានសម្ភាសន៍ជាមួយអាជ្ញាធរ**

២១. តើក្រសួងពាក់ព័ន្ធនានា និងអាជ្ញាធរបានគិតគូររៀបចំក្នុងការអភិវឌ្ឍក្នុងរមណីយដ្ឋានដែរ ឬទេ?

☐ បានគិតគូរ ☐ មិនបានគិតគូរ

២២. តើធ្លាប់មានខាងអង្គការក្រៅរដ្ឋាភិបាល និងផ្នែកឯកជនណាបានចូលរួមក្នុងការអភិវឌ្ឍតំបន់រមណីយដ្ឋានភ្នំកំពង់ត្រាចដែរ ឬទេ?

☐ ធ្លាប់មាន ☐ មិនធ្លាប់មាន

## ឧបសម្ព័ន្ធទី២ ៖ រូបភាពដែលផ្ដិតយកនៅរមណីយដ្ឋានភ្នំកំពង់ត្រាច




រូបទី១ ស្លាកសញ្ញាបង្ហាញផ្លូវចូលរមណីយដ្ឋានភ្នំកំពង់ត្រាច



រូបទី២ ស្ថានភាពផ្លូវចូល




រូបទី៣ ស្លាកសញ្ញាបង្ហាញពីផ្លូវទៅកាន់វត្តគិរិសិលា និងល្អាងព្រះអាទិត្យ



រូបទី៤ ទីធ្លាក្នុងរមណីយដ្ឋាន



រូបទី៥ ច្រកចូលរូងភ្នំកំពង់ត្រាច



រូបទី៦ ព្រះវិហារដែលកំពុងសាងសង់



រូបទី៧ កញ្ចុះអង្គុយលេងដែលនៅខាងក្រៅភ្នំ



រូបទី ៨ ផ្ទះផលិតទឹកស្អាត



រូបទី៩. ទេសភាពផ្លូវរថភ្លើងនៅក្រោយភ្នំ



រូបទី១០. ផ្លូវចូលខាងក្រោយរូងភ្នំ



រូបទី១១. ល្អាងកុមារពេជ្រ កុមារទេព